# សូមប្រសិទ្ធពរបវរមហាប្រសើរជូន



## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## អនុប្រធានគណបក្សប្រជាជនកម្ពុជា
## ជាទីគោរពដ៏ខ្ពង់ខ្ពស់

### ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៦៣ ឈានចូល ៦៤ វស្សារបស់សម្តេច

*យើងខ្ញុំសូមលំអោនកាយគោរពដោយក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះសម្តេច ដែលជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមរបស់ប្រជាជនកម្ពុជា បានលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណ ដើម្បីដឹកនាំមាតុភូមិកម្ពុជាសម្រេចបានជោគជ័យដ៏ធំធេងជាប្រវត្តិសាស្ត្រ ជូនជាតិ និង ប្រជាជន តាំងពីដំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ រហូតមកដល់ដំណាក់កាលសន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍នាបច្ចុប្បន្ននេះ ។សូមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី និង វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកព្រមទាំងតេជៈបារមី នៃវិញ្ញាណក្ខន្ធរបស់បុព្វវិរបុរសខ្មែរគ្រប់ៗជំនាន់ សូមតាមជួយប្រោះព្រំគាំពារថែរក្សា សម្តេច និងលោកជំទាវ សូមបានប្រកបដោយសុខភាពល្អបរិបូរ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លា ដើម្បីដឹកនាំប្រទេសជាតិសម្រេចបានជោគជ័យធំៗថ្មីៗទៀត ឆ្ពោះទៅរកអនាគតដ៏រុងរឿង ។*

**គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត**

**ទស្សនាវដ្តីប្រជាជន**

# សួស្តីឆ្នាំថ្មី

## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

## ឆ្នាំមមី ឆស័ក ពុទ្ធសករាជ ២៥៥៨



*សូមប្រសិទ្ធពរបវរសួស្តី សិរីមង្គល មហាប្រសើរ ថ្វាយ និងជូនសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងនគរបាលជាតិ ជនរួមជាតិនៅគ្រប់ទិសទី ព្រមទាំងអង្គទូតនិងអង្គការអន្តរជាតិនានាដែលកំពុងបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា សូមបានប្រកប នូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

**គោរពជូនពី**

**ទស្សនាវដ្តីប្រជាជន**

## HAPPY KHMER NEW YEAR

## *On the Occasion of the Khmer New Year, the Year of Horse in the Buddhist Year 2558*

*Would like to wish Samdechs, Your Royal Highnesses, Excellencies, Lok Chumteav, Lok Okhna, Government Officials, National Police, Armed Forces, Combatants, Compatriots, Heads of Diplomatic Missions, Diplomats, Country Representatives of the International Organizations, Private Sectors and Civil Societies the four Gems of Buddhist Blessings : Longevity , Nobility, Health And Strength .*

FROM THE PRACHEACHUN MAGAZINE

EDITORIAL

# ឆន្ទៈរបស់ប្រជាជនគឺស្ថិតនៅក្នុងសន្លឹកឆ្នោត មិនមែននៅតាមដងផ្លូវទេ

# People's Will Expressed in Ballots, not in Street

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ កាលពីថ្ងៃទី ២៨ខែកក្កដា ឆ្នាំ២០១៣ បានប្រព្រឹត្តទៅក្នុងបរិយាកាសប្រកបដោយសន្តិភាព និងមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។ ដំណើរការនៃការបោះឆ្នោតនេះបានទទួលការវាយតម្លៃយ៉ាងខ្ពស់ពីសំណាក់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិថា បានប្រព្រឹត្តទៅប្រកបដោយភាពវិជ្ជមានក្រៃលែងនៅក្នុងក្របខណ្ឌនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ ។ ប៉ុន្តែគណបក្សប្រឆាំងដែលចាញ់ឆ្នោតបានបដិសេធមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតនេះ មិនព្រមចូលប្រជុំរដ្ឋសភា ហើយខិតខំកេណ្ឌប្រមូលអ្នកគាំទ្រខ្លួនឱ្យធ្វើបាតុកម្មតវ៉ាតាមដងផ្លូវក្រោមលេសថា "ធ្វើតាមឆន្ទៈរបស់ប្រជាជន" ។

តើឆន្ទៈរបស់ប្រជាជនកម្ពុជានៅឯណា? ពិតប្រាកដណាស់ថា ឆន្ទៈរបស់ប្រជាជនគឺស្ថិតនៅក្នុងសន្លឹកឆ្នោត មិនមែនស្ថិតនៅតាមដងផ្លូវតាមបែបអនាធិបតេយ្យនោះទេ ។ ប្រជាជនបានបង្ហាញពីឆន្ទៈរបស់ខ្លួនយ៉ាងច្បាស់លាស់រួចហើយតាមរយៈសន្លឹកឆ្នោតកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ ដែលពេលនោះប្រជាជនបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាឱ្យទទួលបាន ៦៨ អាសនៈ និងគណបក្សសង្គ្រោះជាតិទទួលបានចំនួន ៥៥ អាសនៈ ។ ដូច្នេះឆន្ទៈរបស់ប្រជាជនគឺគាំទ្រឱ្យគណបក្សប្រជាជនកម្ពុជាបន្តដឹកនាំប្រទេសសម្រាប់នីតិកាលទី ៥ នេះ ឯគណបក្សសង្គ្រោះជាតិត្រូវបន្តនៅជាគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ។ ឆន្ទៈរបស់ប្រជាជនគឺចង់ឃើញការ សាមគ្គីឯកភាពជាតិចង់ឃើញការអភិវឌ្ឍប្រទេសជាតិបន្តទៀត មិនមែនចង់ឃើញប្រទេសជាតិមានអស្ថិរភាព មានការបែកបាក់ប្រេះឆាគ្នា និងត្រូវបំផ្លិចបំផ្លាញនោះឡើយ ។ ប្រជាជនមិនចង់ឃើញអ្នកនយោបាយគ្មានគុណធម៌ នាំគ្នាយកឆន្ទៈរបស់គាត់ទៅបំភ្លៃកាឡៃប្រើជាមធ្យោបាយ ដើម្បីសម្រេចមហិច្ឆតាលោភលន់អំណាចរបស់ខ្លួននោះទេ ។ មកដល់ពេលនេះប្រជាជនកម្ពុជាទូទាំងប្រទេសទាំងអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា ទាំងអ្នកគាំទ្រគណបក្សប្រឆាំងអាចបានឃើញច្បាស់ទាំងអស់គ្នាហើយថា ឆន្ទៈរបស់ខ្លួនកំពុងត្រូវក្រុមអ្នកដឹកនាំនៃគណបក្សប្រឆាំងប្រមាថជាន់ឈ្លីយ៉ាងធ្ងន់ធ្ងរបំផុត ។

ក្រោយការបោះឆ្នោត រដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ ត្រូវបានបង្កើតឡើងស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ រាល់ស្ថាប័នរដ្ឋគ្រប់ថ្នាក់កំពុងដំណើរការជាធម្មតា ។ រាជរដ្ឋាភិបាលកំពុងតែអនុវត្តនូវកម្មវិធីនយោបាយរបស់ខ្លួនដើម្បីធានានូវកិច្ចការពារជាតិ ការពារសន្តិភាព ស្ថិរភាព សន្តិសុខ

The fifth legislative term of the National Assembly elections on 28 July 2013 proceeded in a peaceful, free, fair and juts atmosphere. The election procedure has enjoyed high evaluation from national and international observers on its positive undertaking in the framework of democracy in action. However, losing in the lections, the opposition party denies the election results, refrain from taking part in the National Assembly sesscion, while mobilizaing supporters to demonstrate what they call "people's will" in the street.

Where is the true will of the Cambodian people? Certainly, the people's will is the one expressed in their ballots, not the one expressed in anarchic demonstration in the street. The people clearly showed their wills in their ballots on 28 July 2013 already. They voted 68 seats for the Cambodian People's Party (CPP) and 55 seats for the Cambodian National Rescue Party (CNRP). Hence, the people's will is to support the Cambodian People's Party to continue to lead the country for the fifth term, while the opposition will continue to be opposition party in the National Assembly.

The people's will is to see solidarity, national unity and the country further developed. They do not want to see their country in instability, division or destruction. They do not wish to see politicians of no vitue mislead their will to realize their political ambitions. As of the moment, the people of Cambodia in the whole country, both those who support it and those who support the opposition party, can see clearly that their wills have been seriously insulted and crushed.

After the elections, the fifth legislative term of the National Assembly and Royal Government are created in accordance with the Constitution and laws of the Kingdom of Cambodia. Every state institutions are functioning normally. The Royal Government is implementing its political platform to guarantee national defence, peace, stability, security, social order and promoting development in all fields for further achievements. The Royal Government of Cambodia, under the leadership of Samdech Techo Hun Sen, received warm greetings from foreign countries in all continents. Exchange of top state visits with other countries take place onn after another, while bilateral and multilateral cooperations have been strengthened and expanded. International organizations and institutions continue in normalcy with their missions in Cambodia. Sicial life has not been obstructed. This means that the elections-winning Cambodian People's Party is fulfilling its supreme mission according to the will and aspiration of the people in general.

On the contrary, leaders of the opposition party acted in contradition to the will of their supporters by declaring that they do not recognize the results of the elections. This position of theirs had been declared since before the elections. They use propaganda to falsify the legetimacy of the fifth legislative term National Assembly and the Royal Government of Cambodia. They go all the way to demanding a re-election. To bolster their demands, they led anarchi demonstrations in the streets and factories in violation of law, and gave deaf ears to instructions of authorities. They altered those actions into violent strikes, closed down public streets, caused damages to state and private properties, while inflicted wounds on numerous competent authorities' officials.

The opposition party aims to obstruct every sector, to cause turmoil and to turn the country upside down. The economy could

សណ្តាប់ធ្នាប់សង្គមនិងជំរុញការអភិវឌ្ឍលើគ្រប់វិស័យឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗទៀតជាបន្តបន្ទាប់ ។ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** បានទទួលការសាទរយ៉ាងកក់ក្តៅពីបណ្តាប្រទេសនៅគ្រប់ទ្វីប ការផ្លាស់ប្តូរទស្សនកិច្ចផ្លូវរដ្ឋថ្នាក់កំពូលជាមួយបណ្តាប្រទេសបានប្រព្រឹត្តទៅជាបន្តបន្ទាប់ កិច្ចសហប្រតិបត្តិការទាំងទ្វេភាគីនិងពហុភាគីក៏កំពុងត្រូវបានបន្តពង្រឹងនិងពង្រីក ។ បណ្តាអង្គការ និងស្ថាប័នអន្តរជាតិនានាកំពុងតែបន្តបំពេញបេសកកម្មរបស់ខ្លួនជាធម្មតានៅលើទឹកដីកម្ពុជា ។ ជីវភាពសង្គមមានប្រក្រតីភាពដោយមិនមានការរាំងស្ទះណាមួយឡើយ ។ មានន័យថា គណបក្សប្រជាជនកម្ពុជាដែលបានទទួលជ័យជម្នះនៅក្នុងការបោះឆ្នោតកន្លងមកនេះ កំពុងបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួនយ៉ាងល្អស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជនទូទៅ ។

ផ្ទុយទៅវិញក្រុមអ្នកដឹកនាំនៃគណបក្សប្រឆាំងបានប្រព្រឹត្តផ្ទុយពីឆន្ទៈរបស់អ្នកគាំទ្រខ្លួន ដោយប្រកាសមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដែលជំហរបែបនេះត្រូវបានប្រកាសជាចំហតាំងពីមុនពេលបោះឆ្នោតម្ល៉េះ ពួកគេឃោសនាមួលបង្កាច់លើភាពស្របច្បាប់នៃរដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥ នេះ រហូតទាមទារឱ្យធ្វើការបោះឆ្នោតជាថ្មីឡើងវិញថែមទៀត ។ ដើម្បីពង្រឹងការទាមទាររបស់ខ្លួន ពួកគេបានដឹកនាំធ្វើបាតុកម្មយ៉ាងអនាធិបតេយ្យនៅតាមដងផ្លូវ នៅតាមរោងចក្រនានា ដោយបំពានលើច្បាប់ មិនស្តាប់ការណែនាំរបស់អាជ្ញាធរ រហូតប្រែក្លាយជាកុប្បកម្មដោយហិង្សា បិទផ្លូវសាធារណៈ វាយកម្ទេចទ្រព្យសម្បត្តិរដ្ឋ និងឯកជន ព្រមទាំងបង្ករបួសស្នាមមកលើសមត្ថកិច្ចជាច្រើននាក់ថែមទៀត ។ គោលដៅរបស់គណបក្សប្រឆាំងគឺធ្វើឱ្យរាំងស្ទះគ្រប់វិស័យទាំងអស់ សង្គមច្របូកច្របល់ក្រឡាប់ចាក់ សេដ្ឋកិច្ចត្រូវបំផ្លាញ រាជរដ្ឋាភិបាលត្រូវជាប់គាំងមិនអាចបំពេញតួនាទីរបស់ខ្លួនបាន ហើយចុងក្រោយត្រូវពួកគេផ្តួលរំលំដណ្តើមយកអំណាច ។ ឆ្លងតាមសភាពការណ៍នេះបានបង្ហាញច្បាស់ថា គណបក្សប្រឆាំងបាននាំអ្នកគាំទ្ររបស់ខ្លួនឱ្យដើរផ្ទុយពីលទ្ធិប្រជាធិបតេយ្យ មិនគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ហើយដែលតម្រូវឱ្យកម្លាំងមានសមត្ថកិច្ចត្រូវអនុវត្តវិធានការច្បាប់ ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គមឡើងវិញ ។ តើទង្វើទាំងអស់នេះរបស់ពួកប្រឆាំងធ្វើឡើងតាមឆន្ទៈប្រជាជនមែនឬ? តើប្រជាជនយើងសុខចិត្តឱ្យអ្នកនយោបាយគ្មានគុណធម៌ទាំងនោះយកឆន្ទៈរបស់ខ្លួនទៅជាន់ឈ្លីនៅតាមដងផ្លូវបែបនេះឬ ? ពិតប្រាកដណាស់ថា ប្រជាជនកម្ពុជាមិនអនុញ្ញាតឱ្យគេបន្តធ្វើដូច្នេះបានឡើយ ។

អស់រយៈពេល៩ខែហើយគិតពីក្រោយថ្ងៃបោះឆ្នោត មកដល់ពេលនេះ គណបក្សប្រឆាំងនៅតែមិនព្រមចូលប្រជុំសភា ដែលផ្ទុយទៅនឹងឆន្ទៈរបស់អ្នកគាំទ្រខ្លួនភាគច្រើនដែលចង់ឃើញគណបក្សមួយនេះការពារផលប្រយោជន៍របស់ខ្លួននៅក្នុងក្របខណ្ឌនៃរដ្ឋសភា ។ នៅក្នុងការចរចារវាងក្រុមការងារនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គណបក្សប្រឆាំងនៅតែមានកលល្បិចប្រកបដោយពុតត្បុតធ្វើឱ្យការចរចាមិនអាចលេច ចេញជាលទ្ធផលដុំកំភួនឡើយ ដោយពួកគេបានលើកឡើងនូវលក្ខខណ្ឌនានាដែលមិនស្របរដ្ឋធម្មនុញ្ញ មិនត្រូវនឹងការពិតជាក់ស្តែង រួចហើយរកលេសទម្លាក់កំហុសមកលើគណបក្សប្រជាជនកម្ពុជាវិញ ។ មិនតែប៉ុណ្ណោះមេដឹកនាំគណបក្សប្រឆាំងថែមទាំងប្រកាសគំរាមយ៉ាងគឃ្លើនម្តងហើយម្តងទៀតថា ឈប់បន្តការចរចា ហើយប្រកូកប្រកាសកៀរគរអ្នកគាំទ្រខ្លួនឱ្យធ្វើបាតុកម្មបន្តទៀត ដែលផ្ទុយទាំងស្រុងពីការចង់បានរបស់ប្រជាជនភាគច្រើនលើសលប់ និងសហគមន៍អន្តរជាតិ ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី ក៏គណបក្សប្រជាជនកម្ពុជានៅតែប្រកាន់ជំហរ ស្មោះត្រង់ឥតងាករេ និងមានសុឆន្ទៈជានិច្ចក្នុងការបន្តការចរចានៅគ្រប់កម្រិត ដើម្បីដោះស្រាយបញ្ហារបស់ជាតិដោយសន្តិវិធី ស្របតាមបំណងប្រាថ្នារបស់ប្រជាជន ដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញ លទ្ធផលនៃការបោះឆ្នោត និងស្មារតីបង្រួបបង្រួមជាតិ ។/

ទស្សនាវដ្តីប្រជាជន

have been destroyed while the Royal Government would be in a stalemate position and could not perform its duty. In the end, they would topple it and take power. The situation clearly shows that the oppostion party led their supporters on the path that bypasses democracy, and disrecpect the Constitution and existing laws. Those actions obliged competent authority to carry out law enforcement for the sake of strengthening security and social order. Are these actions of the opposition against the will of the people or not? Would the people allow politicians of no virtue to hijack and crush their will in the street? It is clear that the Cambodian people do not allow them to continue to do so.

Over the past nine months after the elections, as of present, the opposition party continues to refrain from taking part in the National Assembly sessions. This action is in contradiction to the will of their supporters who want the party to defend their interest in the National Assembly. In negotiations conducted between the Cambodian People's Party and the Cambodian National Rescue Party, the opposition continue to subscribe to tricks and swindles leading the negotiations to unsubstantial result. They have raised numerous conditions that are not constitutional and not reflecting the reality, while at the same time blaming the Cambodian People's Party as the culprit.

Worse still, the opposition party made noise of threats again and again to plug off the negotiation and mobilize supporters to resort to continued demonstration that is entirely contradicting to the aspiration of the overwhelming majority of the people and international community. However, the Cambodian People's Party continues to adhere to faithful and unbending position, while nurturing the will always to continue to negotiate at all levels aimed at resolving national issues by peaceful means and according to the aspiration of the people based on the Constitution, results of the elections and national reconciliation spirit./.

THE PRACHEACHUN MAGAZINE

# តើអ្នកដឹកនាំនៃគណបក្សប្រឆាំងមានឆន្ទៈចង់ដោះស្រាយបញ្ហាក្រោយការបោះឆ្នោតនៅកម្ពុជាពិតប្រាកដដែរឬទេ ?

ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៤ តាមរយៈ Facebook របស់ខ្លួន លោក សម រង្ស៊ី បានលើកឡើងនូវការវាយតម្លៃផ្ទាល់របស់ខ្លួនចំពោះស្ថានការណ៍នយោបាយក្នុងប្រទេសកម្ពុជា នៅក្នុងអ្វីដែលលោកហៅថា របាយការណ៍ផ្ញើជូនសហគមន៍អន្តរជាតិ និងមិត្តភក្តិរបស់កម្ពុជា។ ទស្សនាវដ្ដីប្រជាជន សូមដកស្រង់ខ្លឹមសារ ដែលបានចុះផ្សាយនៅក្នុងទំព័រ Facebook របស់មន្ត្រីម្នាក់នៃគណបក្សប្រជាជនកម្ពុជា ទាក់ទងទៅនឹងចំណុចទាំង ៩ នៃរបាយការណ៍របស់លោក សម រង្ស៊ី ដូចខាងក្រោម៖

១-បញ្ហាទាំងឡាយដែលកើតមានក្រោយការបោះឆ្នោតថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ មកទល់បច្ចុប្បន្ន គឺសុទ្ធតែប្រឌិតឡើងដោយមេដឹកនាំគណបក្សសង្គ្រោះជាតិ ក្រោមលេសនៃរបស់ដែលហៅថា "ភាពមិនប្រក្រតីធ្ងន់ធ្ងរ" ដើម្បីបដិសេធមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដូចដែលលោក សម រង្ស៊ី ធ្លាប់បានប្រកាសកាលពីពេលមុនបោះឆ្នោតថា "គណបក្សសង្គ្រោះជាតិចូលរួមការបោះឆ្នោត ប៉ុន្តែពួកគេនឹងមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតទេ" ។ ការពិត សហគមន៍ជាតិ និងអន្តរជាតិ បានវាយតម្លៃត្រឹមត្រូវថា ការបោះឆ្នោតនៅកម្ពុជានាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ គឺបានប្រព្រឹត្តទៅដោយសន្តិភាព គ្មានអំពើហឹង្សា និងប្រកបដោយ លក្ខណៈប្រជាធិបតេយ្យ ត្រឹមត្រូវ សេរី និងយុត្តិធម៌ ហើយលទ្ធផលនៃការបោះឆ្នោតបានឆ្លុះបញ្ចាំងពិតប្រាកដពីឆន្ទៈរបស់ប្រជាពលរដ្ឋអ្នកបោះឆ្នោត ។

២-បណ្ដឹងតវ៉ា និងការទាមទារទាំងឡាយទៅលើអ្វីដែលគណបក្សសង្គ្រោះជាតិហៅថា "ភាពមិនប្រក្រតីដ៏ធ្ងន់ធ្ងរក្នុងការបោះឆ្នោត" ត្រូវបានធ្វើការពិនិត្យស្រាវជ្រាវ ស៊ើបអង្កេត និងដោះស្រាយយ៉ាងម៉ត់ចត់ ដោយស្ថាប័នមានសមត្ថកិច្ចលើការងារបោះឆ្នោត (គ.ជ.ប) ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សាធម្មនុញ្ញដែលជាស្ថាប័នកំពូលក្នុងការដោះស្រាយវិវាទនៃការបោះឆ្នោត ក៏បានធ្វើការពិនិត្យ និងវិនិច្ឆ័យតាមនីតិវិធីដែលកំណត់ ដោយច្បាប់ ហើយបានសម្រេចចាត់ទុកជាបានការនូវលទ្ធផលនៃការបោះឆ្នោតថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣។

៣-ប្រការដែលបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្ររបស់គណបក្សសង្គ្រោះជាតិមិនព្រមចូលប្រជុំសភានៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣ តាមការកោះអញ្ជើញរបស់ព្រះមហាក្សត្រនៃព្រះរាជា ណាចក្រកម្ពុជា ហើយបែរជាធ្វើការដឹកនាំចលនាបាតុកម្ម កុប្បកម្មខុសច្បាប់ គឺជាការបំពានលើរដ្ឋធម្មនុញ្ញ និងជាចេតនាចង់ឱ្យមានវិបត្តិនយោបាយក្រោយការបោះឆ្នោត បង្អាក់និរន្តភាពរបស់រដ្ឋ និងប៉ុនប៉ងធ្វើឱ្យសង្គមជាតិមានអស្ថិរភាព។ ពាក្យ "សភាឯកបក្ស" គឺបង្កើតឡើងដោយគណបក្សសង្គ្រោះជាតិដើម្បីជាលេសបោកបញ្ឆោតសាធារណៈមតិ បិទបាំងសកម្មភាពអនាធិបតេយ្យរបស់ពួកគេនៅក្រៅស្ថាប័នស្របច្បាប់។

៤-រាជរដ្ឋាភិបាលបច្ចុប្បន្ន ដែលប្រសូតចេញពីការបោះឆ្នោតកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ ដែលជាការបោះឆ្នោតប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ត្រឹមត្រូវ សេរី និងយុត្តិធម៌ គឺជារដ្ឋាភិបាលស្របច្បាប់ បានទទួលការគាំទ្រយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋទូទាំងប្រទេស និងត្រូវបានទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋានអន្តរជាតិ។ រាជរដ្ឋាភិបាលបានបន្តបេសកកម្មដឹកនាំកំណែទម្រង់តាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ធ្វើឱ្យសង្គមជាតិបន្តមានសុខ សន្តិភាព និងការអភិវឌ្ឍជាលំដាប់។

៥-សិទ្ធិ សេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្ដុំ និងការជួបប្រជុំ សិទ្ធិធ្វើកូដកម្មនិងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានធានាយ៉ាងពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែអំពើញុះញង់ឱ្យមានកុប្បកម្ម បង្កចលាចល ប៉ះពាល់សន្តិសុខ សណ្ដាប់ធ្នាប់សង្គម គឺត្រូវទទួលខុសត្រូវចំពោះ មុខច្បាប់។

៦-បច្ចុប្បន្នដំណើរជាតិកម្ពុជាបោះជំហានទៅមុខជាលំដាប់ ប្រក្រតីភាពរបស់រដ្ឋ បានបង្កលក្ខណៈ ងាយស្រួលដល់គ្រប់សកម្មភាព និងជីវភាពក្នុងសង្គម។ រដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច មានកាតព្វកិច្ចធានានូវសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ និងសង្គមជាតិ។

៧-ស្ថានការណ៍នយោបាយបច្ចុប្បន្ន គឺបង្កឡើងដោយគណបក្សសង្គ្រោះជាតិ។ ការទាមទារឱ្យមានការស៊ើបអង្កេតលើអ្វីដែលហៅថា "ភាពមិនប្រក្រតីធ្ងន់ធ្ងរនៃការបោះឆ្នោត" ត្រូវបានដោះស្រាយត្រឹមត្រូវតាមផ្លូវច្បាប់ចប់សព្វគ្រប់រួចហើយ។ ការទាមទារឱ្យមានការបោះឆ្នោតឡើងវិញមុនអាណត្តិ គឺខុសនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

៨-ជំហរឥតប្រែប្រួលរបស់គណបក្សប្រជាជនកម្ពុជា ចំពោះបញ្ហាទាំងឡាយដែលកើតមានឡើងក្រោយការបោះឆ្នោតនាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣ គឺដំណោះស្រាយដោយសន្តិវិធី តាមរយៈការចចារដែលជាជំរើសល្អបំផុតតែមួយគត់។ ជំរើសផ្សេងក្រៅពីនេះ គ្រាន់តែជាការស្រមើស្រមៃ ដើម្បីសម្រេចបំណងនយោបាយតែប៉ុណ្ណោះ។ កំណែទម្រង់នៃការបោះឆ្នោត គឺជាចំណែកមួយយ៉ាងសំខាន់នៃដំណោះស្រាយនៃបញ្ហានាពេលបច្ចុប្បន្ន ប៉ុន្តែយន្តការនៃកំណែទម្រង់ដ៏សំខាន់នេះ មិនអាចប្រព្រឹត្តទៅនៅក្រៅស្ថាប័នសភាបានឡើយ។

៩-សាធារណជនបានដឹងច្បាស់ពីជំហរ និងឆន្ទៈរបស់គណបក្សប្រជាជនកម្ពុជា ដែលធ្លាប់បានធ្វើការកែទម្រង់ការបោះឆ្នោតនៅកម្ពុជាជាបន្តបន្ទាប់ ហេតុនេះយើងពិតជាចង់ឱ្យមានកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខដោយពិតប្រាកដ និងចង់ឱ្យមានដំណោះស្រាយបញ្ហានាពេលបច្ចុប្បន្នដោយឆាប់រហ័សបំផុត ដើម្បីធានាឱ្យប្រទេសកម្ពុជាស្ថិតលើផ្លូវប្រជាធិបតេយ្យ និងអភិវឌ្ឍពិតប្រាកដ។/

# វេទិការាជរដ្ឋាភិបាល និងវិស័យឯកជនលើកទី ១៧ ក្រោមប្រធានបទ "សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ កាលានុវត្តភាព និងការប្រឈមចំពោះកម្ពុជា"





*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតីភាពក្នុងវេទិការាជរដ្ឋាភិបាល និងវិស័យឯកជនលើក ទី ១៧ នៅវិមានសន្តិភាព*

នៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១៤ វេទិការាជរដ្ឋាភិបាល ផ្នែកឯកជនលើក ទី ១៧ ដែលហៅថាជាកិច្ចប្រជុំពេញអង្គបើកទូលាយរបស់គណៈរដ្ឋមន្ត្រី បានប្រព្រឹត្តទៅនៅវិមានសន្តិភាព ក្រោមអធិបតីភាពសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមការងារវិស័យឯកជនចំនួន ១០ បាន ចូលរួមលើកជាសំណូមពរឱ្យមានការដោះស្រាយនៅក្នុងវេទិកានេះ ដែលរួមមានជាអាទិ៍ គឺ ១-ក្រុមការងារវិស័យឯកជនផ្នែកទេសចរណ៍ ២-ក្រុមការងារវិស័យឯកជនផ្នែកដឹកជញ្ជូន ៣-ក្រុមការងារ វិស័យឯកជនផ្នែកថាមពល និងធនធានរ៉ែ ៤-ក្រុមការងារវិស័យឯកជនផ្នែក ស្រូវ អង្ករ ៥-ក្រុមការងារវិស័យឯកជនផ្នែកផលិតកម្មកែច្នៃសម្រាប់ការនាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម ៦-ក្រុមការងារវិស័យឯកជនផ្នែកធនាគារ និងហិរញ្ញវត្ថុ ៧-ក្រុមការងារវិស័យឯកជនផ្នែកនីតិកម្មពន្ធដារនិងអភិបាលកិច្ច ៨-ក្រុមការងារវិស័យឯកជនផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម និងសេវាកម្ម ៩-ក្រុមការងារវិស័យឯកជនផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្ម និង ១០-ក្រុមការងារវិស័យឯកជនផ្នែកទំនាក់ទំនងវិជ្ជាជីវៈ។

នៅក្នុងសុន្ទរកថាគន្លឹះ សម្តេចតេជោបានមានប្រសាសន៍ថា ការចូលរួមរបស់វិស័យឯកជនជាមួយនឹងរាជរដ្ឋាភិបាល គឺពិតជាមានភាពចាំបាច់ខ្លាំងណាស់ដើម្បីឱ្យកម្ពុជាអាចត្រៀមខ្លួនចូលទៅក្នុងសមាហរកម្មសេដ្ឋកិច្ចអាស៊ាននាឆ្នាំ ២០១៥ ខាងមុខ។ សកម្មភាពរបស់យើងឆ្ពោះទៅសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ប្រៀបដូចជាសកម្មភាពប្រណាំងទូកង ដែលចាំបាច់អ្នកអុំត្រូវតែអុំឱ្យស្រុះគ្នា ហើយអ្នកកាច់ចង្កូតត្រូវតែតម្រង់ទិសឱ្យត្រង់។ ថ្វីត្បិតរាជរដ្ឋាភិបាលជាអ្នកកាច់ចង្កូតនៅកន្សៃ ប៉ុន្តែការចង្អុលទិសរបស់វិស័យឯកជនដែលជាអ្នកអុំនៅផ្នែកខាងមុខគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ តាមរយៈនេះ រាជរដ្ឋាភិបាលចង់ឃើញសកម្មភាពបន្ថែមទៀតរបស់វិស័យឯកជន ក្នុងការរួមចំណែកដោះស្រាយបញ្ហាប្រឈមរបស់កម្ពុជាជារួម និងវិស័យឯកជនដោយឡែក ដើម្បីឈានឆ្ពោះទៅរកភាពជោគជ័យទាំងអស់គ្នា។

ក្នុងសុន្ទរកថាគន្លឹះនេះដែរ សម្តេចតេជោ **ហ៊ុន សែន** បានលើកបង្ហាញថា "រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងបានផ្តល់ភាពអនុគ្រោះជាច្រើនដើម្បីទាក់ទាញវិនិយោគ និងបង្កើតឱកាសការងារជូនប្រជាពលរដ្ឋ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយស្តីពីការការពារសិទ្ធិរបស់កម្មករ និយោជិត ដោយចាត់ទុកដូចជាការអនុវត្តសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជាផងដែរ។ គោលនយោបាយនេះគឺត្រឹមត្រូវ ដោយបានបង្កើតរោងចក្រ សហគ្រាសជាច្រើនបានផ្តល់ការងាររាប់លានកន្លែង និងង្កើតមុខរបរថ្មីៗជូនប្រជាពលរដ្ឋដើម្បីកែលម្អជីវភាព។ ដោយឡែកវិស័យវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងនៅឆ្នាំ ២០១៣ តម្លៃនាំចេញមានរហូតដល់ជាង ៥ ពាន់លានដុល្លារអាមេរិក និងមានកម្មករ និយោជិតប្រមាណ ៦២ ម៉ឺននាក់ទទួលបានប្រាក់ឈ្នួលសរុបប្រមាណជាង ១ ពាន់លានដុល្លារ ក្នុង ១ ឆ្នាំ។ ប្រជាពលរដ្ឋប្រមាណជាង ២ លាននាក់ផ្សេងទៀតបានទទួលប្រយោជន៍ដោយប្រយោលពីវិស័យនេះតាមរយៈសេវាដឹកជញ្ជូន ឈ្នួលផ្ទះ ការលក់ដូរម្ហូបអាហារ និងការផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសាររបស់កម្មករនិយោជិត ។ល។ នេះគឺជាសមិទ្ធផលដ៏ធំធេងដែលរាជរដ្ឋាភិបាលសម្រេចបាន។ ប៉ុន្តែគណបក្សប្រឆាំង និងសហជីពរបស់គេបានប្រើប្រាស់នយោបាយប្រជាភិថុតិយកកម្មករ និយោជិត ធ្វើជាឈ្នាន់នយោបាយ ដោយញុះញង់ឱ្យធ្វើកូដកម្មបាតុកម្មខុសច្បាប់ ពិសេសការទាមទារប្រាក់ឈ្នួលអប្បរមាហួសហេតុក្នុងគោលដៅបំផ្លាញបរិយាកាសវិនិយោគ បំផ្លាញផលប្រយោជន៍កម្មករនិយោជិត និងបំផ្លាញឱកាសការងាររបស់យុវជន យុវនារី។ រហូតមកដល់ពេលនេះក្រុមជ្រុលនិយមទាំងនេះនៅមិនទាន់បញ្ឈប់សកម្មភាពនៅឡើយទេ ហើយមានមជ្ឈដ្ឋានខាងក្រៅមួយចំនួនបាន លើកទឹកចិត្តគាំទ្រសកម្មភាពបែបនេះ។

រាជរដ្ឋាភិបាលសូមបញ្ជាក់ជាថ្មីម្តងទៀតថា ការអនុវត្តសិទ្ធិសេរីភាព



*ទិដ្ឋភាពរួមនៃវេទិការាជរដ្ឋាភិបាល និងវិស័យឯកជនលើក ទី ១៧ នៅវិមានសន្តិភាព*

នៃការទាមទារទាំងឡាយត្រូវធ្វើឱ្យត្រឹមត្រូវតាមច្បាប់ អំពើល្មើសច្បាប់មិនអាចអត់ឱនតទៀតបានឡើយ ។ ខ្ញុំចង់គូសបញ្ជាក់បន្ថែមថា យើងនឹងធ្វើការងារឱ្យកាន់តែសកម្ម ប្រទាក់ប្រឡា និងបំពេញគ្នាដើម្បីធានាឱ្យប្រាកដថា សេដ្ឋកិច្ចរបស់យើងមានឧត្តមភាពប្រកួតប្រជែង មានផលិត-ភាពខ្ពស់ មានបន្ទុកចំណាយទាប និងមានការទាក់ទាញដល់ការវិនិយោគ ។ ប្រជាពលរដ្ឋ យុវជន យុវនារីត្រូវការវិនិយោគ ត្រូវការរោងចក្រដើម្បីការងារ និងជីវភាព ។ ក្នុងស្មារតីនេះរាជរដ្ឋាភិបាលនឹងកំណត់នូវគោលនយោ-បាយជាតិស្តីពីប្រាក់បៀវត្សដែលនឹងអាចធានាបាននូវកម្រិតជីវភាព និងស្ថានភាពការងារ ល្អដល់កូនៗកម្មករ កម្មការិនី ដើម្បីជំរុញផលិតភាពផង និងលើកកម្ពស់សុខុមាលភាពផង ប៉ុន្តែកិច្ចការនេះត្រូវការវិភាគ ថ្លឹងថ្លែងយ៉ាងល្អិតល្អន់ មានមូលដ្ឋានទិន្នន័យគ្រប់គ្រាន់ និងសមស្របទៅតាមស្ថានភាពនិងការវិវត្តនៃសេដ្ឋកិច្ចតំបន់និងពិភពលោក ។ការចូលរួមជាលក្ខណៈស្ថាបនា និងមានការទទួលខុសត្រូវខ្ពស់ពីសំណាក់ និយោជិត សហជីព និងនិយោជក និងដោយមានការពិគ្រោះយោបល់ និងការចរចារជាមួយគ្នាត្រង់ទៅត្រង់មក ជាកិច្ចការចាំបាច់ដើម្បីឈានទៅសម្រេចលទ្ធផលល្អនៅក្នុងទំនាក់ទំនងផ្នែកឧស្សាហកម្ម ផលិតភាព និងប្រាក់ឈ្នួលដែលបម្រើផលប្រយោជន៍ជាតិក្នុងទស្សនវិស័យវែងឆ្ងាយមួយ ។ ក្នុងចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ថា ខ្ញុំការពារដាច់ខាតចំពោះផលប្រយោជន៍យុវជន ប៉ុន្តែមិនគាំទ្រសកម្មភាពទាំងឡាយណាដែលយកអនាគតយុវជនកម្ពុជា ជាការសាកល្បង ជាល្បែងភ្នាល់ និងជាដើមទុនក្នុងការសម្រេចនូវមហិច្ឆតានយោបាយរបស់មនុស្សមួយក្រុមតូចណាមួយនោះទេ ។ រាជរដ្ឋាភិបាលដាច់ខាតមិនទុកឱ្យក្រុមណាមួយយកកម្មករនិយោជិតធ្វើជាឈ្នាន់នយោ-បាយ និងយករោងចក្រ សហគ្រាសធ្វើជាចំណាប់ខ្មាំងរបស់ក្រុមខ្លួនជាដាច់ខាត ពោលគឺរាជរដ្ឋាភិបាលត្រូវការពារផ្លែផ្កា គឺការងារសម្រាប់កម្មករនិយោជិតដែលបានមកពីការលះបង់ចំណូលថវិការដ្ឋដ៏ច្រើនសន្ធឹកសន្ធាប់ ។ ជាក់ស្តែងតាមរយៈការដាក់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋដែលជារបបផ្តល់ការលើកទឹកចិត្តស្ថិតក្រោមច្បាប់ស្តីពីវិនិយោគ រាជរដ្ឋាភិបាលបានលះបង់ចំណូលប្រមាណ ១ ៣០៤ លានដុល្លារអាមេរិកនៅឆ្នាំ ២០១៣ ។

ខ្ញុំយល់ថា ការបង្កើនប្រាក់ឈ្នួលប្រចាំខែ គឺត្រូវផ្សារភ្ជាប់នឹងសមត្ថភាពផលិតរបស់កូនៗកម្មករ និយោជិត ។ នៅពេលណាដែលរោងចក្រមានផលិតភាពខ្ពស់ លទ្ធភាពប្រកួតប្រជែងរបស់គេនៅលើទីផ្សារនឹងមានកាន់តែខ្លាំង ។ នៅពេលដែលផលិតផលរបស់រោងចក្រមានភាពប្រកួតប្រជែង ចំណូលរបស់ក្រុមហ៊ុននឹងមានកំណើន ។ ជាលទ្ធផលក្រុមហ៊ុននឹងមានលទ្ធភាពជូនប្រាក់ឈ្នួលខ្ពស់ដល់កម្មករ និយោជិត ។ ដូច្នេះការលើកកម្ពស់ផលិតភាពមិនគ្រាន់តែជួយកម្ពុជាឱ្យមានសមត្ថភាពប្រកួតប្រជែងក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ខាងមុខនេះទេ ក៏ប៉ុន្តែនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់កូនៗកម្មករ និយោជិត ។

ពេលនេះជាពេលវេលាដ៏សំខាន់បំផុតជាងពេលណាៗទាំងអស់ដែលយើងត្រូវធ្វើការងាររួមគ្នាដើម្បី សន្តិភាព ស្ថិរភាព ការអភិវឌ្ឍ និងវិបុល-ភាពនៅកម្ពុជាសម្រាប់ពេលបច្ចុប្បន្ន និងជាពិសេសកសាងអនាគតសង្គមកម្ពុជាបែបទំនើបមួយ ។

សម្តេចតេជោ **ហ៊ុន សែន** បានលើកឡើងប្រធានបទ ៣ ជាសំខាន់គឺ ទី១-ទាក់ទងបញ្ហាពន្ធដារ សម្តេចបានអះអាងយ៉ាងច្បាស់លាស់ថា ក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហាពន្ធដារគឺរដ្ឋពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬដំឡើងពន្ធបន្ថែមដល់ប្រជាជន និងធុរជនក្នុងគោលដៅបង្កើនចំណូលថវិកាជាតិនោះទេ ។រាជរដ្ឋាភិបាលផ្តោតទៅលើការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួចទាំងតាមវិធាន-ការរដ្ឋបាល និងវិធានការគោលនយោបាយ ទាំងសម្រាប់រយៈពេលខ្លី មធ្យម និងវែង ។ ជាពិសេស លើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយនិងផ្នែកពន្ធដារ ។ ទី២-ពាក់ព័ន្ធនឹងបញ្ហាថ្លៃអគ្គិសនី សម្តេចតេជោ **ហ៊ុន សែន** បានបញ្ជាក់ថា ការធ្វើឱ្យអគ្គិសនីមានតម្លៃទាបពិតជាសំខាន់ខ្លាំងណាស់ក្នុងការជំរុញឱ្យសហគ្រាសឧស្សាហកម្មនៅកម្ពុជាអាចប្រកួតប្រជែងជាមួយទំនិញនាំចូលពីប្រទេសដទៃ ។ ប៉ុន្តែការធ្វើឱ្យមានអគ្គិសនីសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ និងមានបណ្តាញផ្គត់ផ្គង់ទៅគ្រប់ទីកន្លែងនៅទូទាំងប្រទេសរឹតតែសំខាន់ជាងថ្លៃអគ្គិសនីទៅទៀត តាមរយៈគោលការណ៍សមធម៌ក្នុងសង្គម ។ សម្តេចតេជោបានសង្កត់ធ្ងន់ថា ពិតមែនតែថ្លៃអគ្គិសនីរបស់យើងពុំអាចចុះថ្លៃឱ្យដល់កម្រិតចង់បានរបស់ផ្នែកឯកជនក៏ពិតមែនប៉ុន្តែ ថ្លៃអគ្គិសនីរបស់កម្ពុជាពុំបានឡើងដូចនៅបណ្តាប្រទេសជិតខាងទេ ។ សម្តេចបានបញ្ជាក់យ៉ាងច្បាស់ថា កម្ពុជានឹងខិតខំផលិតអគ្គិសនីដែលមានប្រភពមកពីវារី-អគ្គិសនីកាន់តែច្រើន ដូច្នេះតម្លៃអគ្គិសនីនឹងអាចចុះថ្លៃថោក ។ ទី៣-ទាក់ទងបញ្ហាទំនាក់ទំនងវិជ្ជាជីវៈ សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងបានផ្តល់នូវភាពអនុគ្រោះជាច្រើនដើម្បីទាក់ទាញវិនិយោគ និងបង្កើតឱកាសការងារជូនប្រជាជន ។តាមរយៈនេះ ការអនុវត្តសិទ្ធិសេរីភាពនៃការទាម-

ទារទាំងឡាយ ត្រូវធ្វើឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ ។ អំពើល្មើសច្បាប់មិនអាចអត់ឱនទៀតបានឡើយ ។ រាជរដ្ឋាភិបាលនឹងធ្វើការងារឱ្យកាន់តែសកម្មប្រទាក់ក្រឡា និងបំពេញគ្នាដើម្បីធានាឱ្យប្រាកដថា សេដ្ឋកិច្ចរបស់យើងមានឧត្តមភាពប្រកួតប្រជែង មានផលិតភាពខ្ពស់ មានបន្ទុកចំណាយទាប និងមានការទាក់ទាញដល់ការវិនិយោគ ពិសេសប្រជាជន យុវជន យុវនារីត្រូវការវិនិយោគ ត្រូវការរោងចក្រដើម្បីការងារ និងជីវភាព ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងកំណត់នូវគោលនយោបាយជាតិស្ដីពីប្រាក់បៀវត្សដែលអាចធានាបាននូវកម្រិតជីវភាព និងស្ថានភាព ការងារល្អដល់កម្មករ កម្មការិនី ដើម្បីជំរុញផលិតភាពផង និងសុខមាលភាពផង ដែលកិច្ចការនោះត្រូវតែវិភាគថ្លឹងថ្លែងយ៉ាងល្អិតល្អន់ និងមានមូលដ្ឋានទិន្នន័យគ្រប់គ្រាន់សមស្របទៅតាមស្ថានភាពនៃការវិវត្តសេដ្ឋកិច្ចតំបន់ និងពិភពលោក ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីក៏បានដោះស្រាយ និងឆ្លើយតបទៅនឹងសំណូមពរមួយចំនួនដែលផ្នែកឯកជនបានលើកឡើងតាមរយៈក្រុមការងារដែលមានជាអាទិ៍ ការអនុវត្តច្បាប់ស្ដីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (FATCA) ។ វិស័យឯកជនតំណាងឱ្យសេវាធនាគារ និងហិរញ្ញវត្ថុ បានស្នើសុំរាជរដ្ឋាភិបាលធ្វើការសម្រេចចិត្តក្នុងការជ្រើសយកជំរើសសម្រាប់អនុវត្ត(FATCA)ដែលជាច្បាប់ពន្ធថ្មីរបស់អាមេរិក ។ សម្ដេចតេជោថ្លែងថា ដោយសារការងារនេះមានលក្ខណៈបន្ទាន់ហើយមានភាពស្មុគស្មាញច្រើនខ្ញុំយល់ថាគួរបង្កើតក្រុមការងារមួយដឹកនាំដោយធនាគារជាតិនៃកម្ពុជាដោយមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីរួមគ្នាពិនិត្យ និងដោះស្រាយ ។

សំណើសុំដាក់អាករលើតម្លៃបន្ថែមមក 0% លើការផ្គត់ផ្គង់ក្នុងស្រុកផ្ដល់ជូននូវលក្ខណសម្បត្តិជាសហគ្រាសដែលប្រមូលទិញស្រូវមកធ្វើការកែច្នៃជាអង្ករសម្រាប់ផ្គត់ផ្គង់បន្តឱ្យអ្នកនាំចេញដូចគ្នានឹងវិស័យកាត់ដេរដែរ ។ បញ្ហានេះ សម្ដេចតេជោតម្រូវឱ្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រមួយចំនួនដូចជាកិច្ចសន្យាផ្គត់ផ្គង់អង្ករ និងប្រតិវេទន៍គយជាដើម ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំប្រកាសដាក់ឱ្យអនុវត្ត ។ សំណើសុំបន្តដាក់បន្ទុកនូវអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់អង្កាម និងកន្ទក់ក្នុងស្រុក សម្ដេចយល់ព្រមផ្ដល់ជូននូវការដាក់ជាបន្ទុករដ្ឋនូវអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ និងកន្ទក់ក្នុងស្រុក ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុនឹងរៀបចំប្រកាសដាក់ឱ្យអនុវត្ត ។ សំណើសុំបន្តដាក់បន្ទុកនូវអាករលើតម្លៃបន្ថែមសម្រាប់ការនាំចូលសរសៃសូត សម្ដេចផ្ដល់ជូនការលើកទឹកចិត្តនេះ សម្រាប់រយៈពេល ២ ឆ្នាំបន្ថែមទៀតរហូតដល់ដំណាច់ឆ្នាំ ២០១៥ តែម្ដង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំប្រកាសដាក់ឱ្យអនុវត្ត ។ រួចបញ្ជាក់ថា ពន្ធលើការនាំចូលសរសៃសូតគឺត្រូវអនុវត្តតាមអត្រា 0% ចាប់ពី ៣ ឆ្នាំមុនរួចហើយ ។ សំណើសុំការលើកទឹកចិត្តចំពោះការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មបម្រើឱ្យការនាំចេញកាបូប កាបូបយួរដៃ និងមួក ផ្ដល់ជូននូវការលើកទឹកចិត្តចំពោះការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្ម បម្រើឱ្យការនាំចេញកាបូប កាបូបយួរដៃ និងមួកព្រមទាំងផលិតផលប្រហាក់ប្រហែលមួយចំនួនទៀតដូចគ្នានឹងវិស័យកាត់ដេរ និងស្បែកជើង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំប្រកាសដាក់ឱ្យអនុវត្ត ។

សំណើសុំបញ្ចុះកម្រៃម៉ាស៊ីនស្កែនសម្ដេចតេជោសម្រេចបញ្ចុះតម្លៃម៉ាស៊ីនស្កែនចំនួន ២% បន្ថែមទៀត ដោយក្នុងនោះកម្រៃម៉ាស៊ីនស្កែនសម្រាប់កុងតឺន័រ ៤0 ហ្វីតនឹងបញ្ចុះពី ៤0 មក ៣២ ដុល្លារអាមេរិក សម្រាប់កុងតឺន័រ ២0 ហ្វីត នឹងត្រូវបញ្ចុះពី ២៥ មក ២0 ដុល្លារអាមេរិក ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំប្រកាសដាក់ឱ្យអនុវត្តពីថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៤ នេះតទៅ ។

ការផ្ដត់ផ្គង់សិទ្ធិជាប្រតិបត្តិករសេដ្ឋកិច្ច សម្ដេចតេជោបានណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យចាប់ផ្ដើមធ្វើការអញ្ជើញចុះរជនដែលមានអនុលោមភាពខ្ពស់ និងមានកិត្តិនាមល្បីៗដើម្បីផ្ដល់ជូននូវសិទ្ធិជាប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាតនេះតែម្ដងឱ្យបានមុនថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៤ ។

សម្ដេចតេជោថ្លែងថា ក្រសួងទេសចរណ៍ និងស្នងការនគរបាលជាតិត្រូវខិតខំរកគ្រប់មធ្យោបាយគ្រប់បែបយ៉ាងដើម្បីបន្ថែមបញ្ជូរនគរបាលអន្តោប្រវេសន៍នៅច្រកអន្តរជាតិប៉ោយប៉ែតដើម្បីសម្រួលដល់កំណើនភ្ញៀវទេសចរដែលឆ្លងកាត់តាមច្រកនេះ ។ ត្រូវខិតខំរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខ នៅតាមទីប្រជុំជន និងតំបន់ដែលមានទេសចរច្រើន ។ ពាក់ព័ន្ធនឹងសុវត្ថិភាពចរាចរណ៍ រាជរដ្ឋាភិបាលទើបអនុម័តគោលនយោបាយស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកកាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០១៤ ។ ម្យ៉ាងវិញទៀតក្រសួងសាធារណការ និងដឹកជញ្ជូនបានរៀបចំសេចក្ដីព្រាងច្បាប់ចរាចរណ៍ផ្លូវគោកថ្មីដែលកំពុងឆ្លងក្រុមប្រឹក្សាអ្នកច្បាប់ ។

សម្ដេចនាយករដ្ឋមន្ត្រីថ្លែងថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវតាមដានការអនុវត្តជាក់ស្ដែងរបស់បណ្ដាក្រុមហ៊ុនវិនិយោគលើកោះឆ្នេរដែលបានចុះហត្ថលេខារួចហើយ ដើម្បីធានាឱ្យបានការអនុវត្តស្របតាមគោលការណ៍កំណត់ ។ ចំពោះក្រុមហ៊ុនណាដែលពុំបានអនុវត្តគម្រោងតាមខ្លឹមសារកិច្ចសន្យាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការវិនិយោគកម្ពុជាត្រូវលើកសំណើសុំលុបកិច្ចសន្យាវិញ ។

វេទិការាជរដ្ឋាភិបាល និងផ្នែកឯកជនបានបញ្ចប់ទៅដោយជោគជ័យ ដោយផ្នែកក្រុមការងារឯកជននៃវិស័យទាំង ១0 បានសម្ដែងការអបអរសាទរចំពោះដំណោះស្រាយនានាដែលសម្ដេចតេជោ **ហ៊ុន សែន** បានលើកឡើង ហើយវេទិកានេះក៏បានដោះស្រាយនូវបញ្ហាជាគន្លឹះប្រឈមធំៗសម្រាប់សមាជិកភាពរបស់កម្ពុជាក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ខាងមុខនេះ ។/

# សម្តេចតេជោ

## ❉ ការនិយាយរបស់នាយករដ្ឋមន្ត្រីក្នុងតំណែង ខុសពីនាយករដ្ឋមន្ត្រីខ្មៅអាវហាណ៍
## ❉ ទន្រ្ទាំជើងនៅតែមួយកន្លែងជាសត្រូវរបស់វប្បធម៌





*សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញជាអធិបតីក្នុងទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ឆ្នាំ ២០១៤ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ*

ក្នុងខែមីនា ឆ្នាំ២០១៤ នេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញសម្ពោធសមិទ្ធផលធំៗមួយចំនួន ដែលក្នុងនោះមានការសម្ពោធផ្លូវជាតិលេខ ៥៧ បេ ប្រវែងជាង ១០០ គ.ម សម្ពោធដាក់ឱ្យប្រើប្រាស់វារីអគ្គិសនីស្ទឹងអាតៃ ព្រមទាំងចូលរួមក្នុងវិស័យវប្បធម៌ និងអប់រំ ។នៅគ្រប់ទីកន្លែងដែលសម្តេចបានចូលរួម សម្តេចបានណែនាំដល់បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរអំពីការងារៗសំខាន់ៗជាច្រើន ។

❉ ថ្ងៃទី ៣ ខែមីនា សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ឆ្នាំ ២០១៤ ដែលរៀបចំឡើងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅសាលសន្និសីទចតុមុខរាជធានីភ្នំពេញ ក្រោមប្រធានបទ "អ្វីៗទាំងអស់ដើម្បីសុខដុមភាពវប្បធម៌ជាតិ" ។ ក្នុងពិធីនោះក្រៅពីការផ្តល់អនុសាសន៍មួយចំនួនទាក់ទងទៅនឹងវិស័យវប្បធម៌នោះ សម្តេចក៏បានចាប់អារម្មណ៍លើការអភិរក្ស និងអភិវឌ្ឍម្ហូបខ្មែរដែលជាផ្នែកមួយនៃវប្បធម៌ផងដែរ ។

សម្តេចតេជោបានលើកឡើងថា ចំណុចនេះយើងមិនត្រូវមើលរំលងទេ បណ្តាប្រទេសនិមួយៗគេបានខិតខំណាស់ នៅពេលដែលយើងបានទៅដល់ប្រទេសគេៗក៏ចាប់ផ្តើមដាក់ម្ហូបជាប្រពៃណីរបស់គេមកទទួលយើង ។ដូចនេះពេលជប់លៀងម្តងៗ យើងក៏អាចបង្ហាញម្ហូបរបស់យើងដែរ ដើម្បីឱ្យគេឃើញពីម្ហូបរបស់យើងដែលមាន ត្រសក់ចាវ ម៉ុំាល្ហុង ត្រីឆ្អើរ ជា ដើម ។ ប្រទេសខ្លះដូចជាប្រទេសកូរ៉េ ក្រៅពីជាម្ហូបប្រពៃណីរបស់គេដែលបរិភោគក្នុងស្រុក ហើយបច្ចុប្បន្នគេបានបញ្ជូនចេញមកក្រៅប្រទេសទៀតដូចជានៅកម្ពុជាបច្ចុប្បន្ន "គីមជី" ត្រូវបានគេដាក់លក់នៅតាមហាង និងភោជនីយដ្ឋានមួយចំនួន ដូចនេះយើងក៏ត្រូវគិតគូពីបញ្ហានេះផងដែរ ។ បើមិនដូច្នេះទេគេនឹងចាត់ទុកថាម្ហូបហួសសម័យដែលធ្វើឱ្យបាត់បង់នូវស្ថានភាពរសជាតិម្ហូបរបស់ខ្មែរ ។

សម្តេចតេជោបានបញ្ជាក់ទៀតថា ភាពទន្រ្ទាំជើងមួយកន្លែងនៅស្ងៀមទ្រឹងនេះគឺជាសត្រូវរបស់វប្បធម៌ ហើយក៏អាចនាំឱ្យវប្បធម៌ស្លាប់បានដែរ ។ ដូចនេះត្រូវតែមានការអភិវឌ្ឍទើបអាចបំពេញ និងបម្រើឱ្យភាពចាំបាច់នៃសេចក្តីត្រូវការរបស់សង្គម និងមហាជនបាន ។

ទាក់ទងទៅនឹងទិវាវប្បធម៌៣មីនានេះ សម្តេចតេជោបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី ៣ ខែមីនា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវាវប្បធម៌ជាតិនេះនៅទូទាំងប្រទេស ក្នុងគោលបំណងបំផុសមនសិការស្នេហាជាតិ ស្មារតីស្រឡាញ់សម្បត្តិវប្បធម៌ដ៏សម្បូណ៌បែបរបស់ជាតិដល់ប្រជាជាតិខ្មែរពីគ្រប់មជ្ឈដ្ឋានទាំងនៅក្នុង និងក្រៅប្រទេស ។

សម្តេចក៏បានផ្តល់នូវអនុសាសន៍មួយចំនួនដូចជា ត្រូវយកចិត្តទុកដាក់លើកម្លាំងសកម្មរបស់សង្គម គឺកម្លាំងយុវជនដែលជាអ្នកបន្តវេន ។ ក្នុងនោះដែរក្រុមកុមារក៏ជាចំណែកដ៏ធំមួយដែលមិនគួរមើលរំលងនោះឡើយ ។ ក្រសួងវប្បធម៌ត្រូវចេះរៀបចំសកម្មភាព និងរំលេចនូវខ្លឹមសារផ្សេងៗ ដើម្បីជាការរំញ្ញកបម្រើឱ្យទិវាវប្បធម៌ជាតិ ៣ មីនានេះ តាមរយៈព្រឹត្តិការណ៍នានាឱ្យបានជាប្រចាំក្នុងពេលជាបន្តបន្ទាប់ ដើម្បីដាស់រំញ្ញកស្មារតីស្នេហាជាតិ ស្នេហាវប្បធម៌ជាតិឱ្យកាន់តែមោះមុតក្នុងអារម្មណ៍របស់ពលរដ្ឋខ្មែរម្នាក់ៗ ។

"កម្ពុជា ព្រះរាជាណាចក្រនៃវប្បធម៌" ដូចនេះត្រូវយល់ថារាជាណាចក្រនៃវប្បធម៌គឺជារាជាណាចក្រនៃចំណេះដឹងនិងការអភិវឌ្ឍ ។បើគ្មានចំណេះដឹងនិងគ្មានការអភិវឌ្ឍទេនោះ ក៏គ្មានព្រះរាជាណាចក្រនៃវប្បធម៌នោះដែរ ។ ចំណុចនេះសម្តេចចង់បញ្ជាក់ថា សិល្បៈរបស់យើងមិនអាចទន្រ្ទាំជើងមួយកន្លែងបានឡើយ ពីព្រោះការនៅស្ងៀមទ្រឹងនេះគឺជាសត្រូវរបស់សិល្បៈ ហើយក៏អាចនាំឱ្យសិល្បៈស្លាប់បានដែរ ។ ដូច្នេះ សិល្បៈចាំបាច់ត្រូវមានការអភិវឌ្ឍទើបអាចបំពេញ និងបម្រើឱ្យភាពចាំបាច់នៃសេចក្តីត្រូវការរបស់មហាជនបាន ។

ត្រូវខិតខំបង្កើតផលិតផលវប្បធម៌ថ្មីឱ្យបានច្រើន ដែលនឹងបម្រើឱ្យផលប្រយោជន៍ច្រើនថែមទៀតដល់សង្គមជាតិនិងប្រជាជន ។ ប៉ុន្តែដាច់ខាត មិនអាចអភិវឌ្ឍវប្បធម៌សិល្បៈដែលប្រាសចាកពីទម្រង់នៃវប្បធម៌ជាតិ ប្រាសចាកពីសេចក្តីថ្លៃថ្នូរនិងគុណធម៌របស់មនុស្សជាតិបានឡើយ ។ វប្បធម៌ជាតិពុំមែនមានតែវប្បធម៌ខ្មែរមួយនោះទេ គឺនៅមានវប្បធម៌របស់បណ្តាជនជាតិនិងជនជាតិភាគតិចជាច្រើនទៀតគួបផ្សំ ហើយដែលយើងនៅមិនទាន់បានសិក្សាស្រាវជ្រាវនិងប្រមូលផ្តុំបានអស់នៅឡើយ ។ ក្រសួងវប្បធម៌ត្រូវចេះកៀងគរនិងសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាដៃគូឯកជនដែលកំពុងប្រតិបត្តិការលើ

វិស័យសិល្បៈវប្បធម៌ ដើម្បីកៀរគរ ប្រមូលទុនពីខាងក្រៅមករួមចំណែកក្នុងការកសាង និងអភិវឌ្ឍជាតិឱ្យកាន់តែល្អប្រសើរឡើង ។

ថ្ងៃទី ១០ ខែមីនា សម្ដេចតេជោបានអញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវជាតិលេខ៥៧បេ ដែលតភ្ជាប់ពីស្រុកបវេល ខេត្តបាត់ដំបង ទៅតំបន់ព្រំដែនកម្ពុជា-ថៃ ។ នៅទីនោះសម្ដេចបានបញ្ជាក់ថា គណបក្សប្រជាជនកម្ពុជាមិនមាននយោបាយប្រជាភិថុតិណាមួយទេ ។

សម្ដេចមានប្រសាសន៍ថា យើងមិនមាននយោបាយប្រជាភិថុតិណាមួយនោះទេ ។ នយោបាយរបស់យើងជានយោបាយជាក់ស្ដែង ហើយនយោបាយហេដ្ឋារចនាសម្ព័ន្ធដែលយើងបាននិងកំពុងធ្វើនៅតែជានយោបាយអាទិភាពរបស់គណបក្សប្រជាជនកម្ពុជា។ ទន្ទឹមនឹងការយកចិត្តទុកដាក់ទៅលើវិស័យសង្គមនិងវិស័យដទៃទៀតដែលទាក់ទងទៅនឹងការកសាង ប្រទេស បើគ្មានផ្លូវ គ្មានស្ពាន គ្មានប្រឡាយទឹក គ្មានអគ្គិសនី និងគ្មានធនធានមនុស្សទេ យើងក៏មិនអាចធ្វើអ្វីបានដែរ ។ ចំពោះអ្នកបោកប្រាសធ្វើយ៉ាងណាជានយោបាយរបស់គេដោយឡែក។ នយោបាយអាទិភាពនេះជាការចង់បានរបស់ប្រជាជននៅក្នុងប្រទេស ក៏ដូចជាការចង់បាននៃសហគមន៍អនុតំបន់មេគង្គ និងតំបន់អាស៊ានដែលកំពុងតែធ្វើការតភ្ជាប់ ។ពាក់ព័ន្ធនឹងការសម្ពោធផ្លូវលេខ៥៧បេសម្ដេចក៏បានរំឭកអំពីទំនាក់ទំនងសហប្រតិបត្តិការរវាងកម្ពុជា ចិន ដែលបានឈានដល់ទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ។ សម្ដេចបញ្ជាក់ថា កម្ពុជានៅតែត្រូវការទុនវិនិយោគក៏ដូចជាជំនួយឥតសំណង និងកម្ចីពីប្រទេសចិនដើម្បីបន្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។

គួរបញ្ជាក់ថាផ្លូវជាតិលេខ ៥៧ បេ មានប្រវែងសរុប ១៧៦,៣៥ គីឡូ-ម៉ែត្រ។ មានទទឹង ១១ ម៉ែត្រ ភ្ជាប់ពីកំណាត់ផ្លូវជាតិលេខ ៥ ត្រង់ចំណុចទីរួមស្រុកថ្មគោលក្នុងខេត្តបាត់ដំបង ដោយចែកចេញជា ៣ ខ្នែងនិងមាន ៣ កំណាត់តភ្ជាប់ទៅព្រំដែនថៃទាំងអស់។ កំណាត់ទី ១ ថ្មគោល-បវេល-សំពៅលូន (ប្រវែង ៩០,២០ គីឡូ ម៉ែត្រ) ។ កំណាត់ទី ២ បវេល-ភូមិ សាមសិប-ភ្នំព្រឹក (ប្រវែង ៦៩,៧៥ គីឡូម៉ែត្រ) និងកំណាត់ទី ៣ ភូមិ សាមសិប កំរៀង-អូរដា (ប្រវែង១៦,៤០គីឡូម៉ែត្រ) ។ផ្លូវនេះត្រូវបានបើកការដ្ឋានកាលពីខែមីនា ឆ្នាំ ២០១១ និងបញ្ចប់នៅខែធ្នូ ឆ្នាំ ២០១៣ ដោយចំណាយថវិកាសរុបប្រមាណ ៨៩,៩៨ លានដុល្លារអាមេរិក ក្រោមកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគមួយចំនួនរបស់រាជរដ្ឋាភិបាលសម្រាប់ការដោះមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងដោះស្រាយផលប៉ះពាល់ ។ ការសាងសង់ត្រូវបានអនុវត្តដោយក្រុមហ៊ុនសាវជីវកម្មស្ពានថ្នល់ចិន និងត្រួតពិនិត្យបច្ចេកទេសដោយក្រុមហ៊ុនក្វាងចូវវ៉ាន់អាន។

ព្រឹកថ្ងៃទី១១ខែមីនាសម្ដេចតេជោបានអញ្ជើញចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជ័យលាភីដល់គរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ ។ នៅទីនោះសម្ដេចបានថ្លែងជាប្រយោលទៅរកអ្នកនយោបាយដែលពូកែខាងសន្យាឱ្យប្រាក់ខែប៉ុណ្ណេះ ឬប៉ុណ្ណោះ ដោយបានមានប្រសាសន៍ថា "រឿងអ្នកសន្យាគឺអត់លំបាកទេ ព្រោះរឿងគ្រាន់តែនិយាយ" ។ ប៉ុន្តែការធ្វើឱ្យបានមិនមែនគ្រាន់តែការនិយាយឱ្យតែចប់នោះទេ។ សម្ដេចនៅទីនេះមុននិយាយដាក់ចេញនូវកំណែទម្រង់ហើយត្រូវតែមានការបញ្ជាក់ជាមួយក្រសួងហិរញ្ញវត្ថុ បញ្ជាក់ជាមួយធនាគារជាតិឱ្យបានច្បាស់ថា ក្នុងពេលដែលយើងរុញមកឱ្យបើកប្រាក់ខែក្នុងខែតើមានសាច់ប្រាក់ពិតប្រាកដឬអត់? គឺត្រូវរៀបចំរំកិលសាច់ប្រាក់តាំងពីប៉ុន្មានខែមុន។

សម្ដេចបានបន្តទៀតថា ការដែលមកនិយាយនៅទីនេះក្នុងនាមជានាយក



*សម្ដេចតេជោ **ហ៊ុន សែន** កាត់ខ្សែបូសម្ពោធផ្លូវជាតិលេខ ៥៧ បេ ដែលតភ្ជាប់ពីស្រុកបវេល ខេត្តបាត់ដំបង ទៅតំបន់ព្រំដែន កម្ពុជា-ថៃ*

រដ្ឋមន្ត្រី តែបើនៅពេលអនុវត្តជាក់ស្ដែង ក្នុងរតនាគារមិនមានសាច់ប្រាក់នោះតើយើងធ្វើនាយករដ្ឋមន្ត្រីបែបណាទៅ? តែនាយករដ្ឋមន្ត្រីឧទាហរណ៍គ្មានបញ្ហាទាំងអស់ ព្រោះគ្រាន់តែឧទាហរណ៍ប៉ុណ្ណោះ។ បើខ្ញុំឈ្នះឱ្យប្រាក់ខែមួយលាន ហើយបើកទាន់ពេលទៀតបើកតាំងពីថ្ងៃទី ១។ ច្បាស់ណាស់ ព្រោះនេះជាការនិយាយជាឧទាហរណ៍ ប៉ុន្តែនាយករដ្ឋមន្ត្រីពិត គឺនិយាយត្រូវតែធ្វើ ។

សម្ដេចក៏បានរិះគន់ចំពោះពួកអ្នកនយោបាយប្រឆាំងថាអ្នកដែលនិយាយពីការដំឡើងប្រាក់ខែមួយលានរៀល ឬពីរលានរៀលគឺស្រេចតែចិត្តគេចង់ ប៉ុន្តែអ្នកនៅជាមួយខ្លួនវិញ អ្នកដាំបាយបានលុយតែ ២៥០ ០០០ រៀលប៉ុណ្ណោះ តែទៅដើរទាមទារដំឡើងប្រាក់ខែកម្មករមួយខែ ១៦០ ដុល្លារ ។

ព្រឹកថ្ងៃទី ១៧ ខែមីនា សម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមពិធីប្រគល់សញ្ញាបត្រដល់និស្សិតជ័យលាភីថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សរុបចំនួន ៧.៥៧១ នាក់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ។

នាឱកាសនោះសម្ដេចមានប្រសាសន៍ថា ចាប់តាំងពីថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩រហូតមកដល់បច្ចុប្បន្នយើងកសាងប្រទេសបានពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ ។មិនមែនមានន័យថាយើងមិនបានយកចិត្តទុកដាក់ទៅលើបញ្ហាធនធានមនុស្សនោះទេ ។ ប៉ុន្តែតាមដំណាក់កាលនីមួយៗ យើងបានឆ្លងកាត់នូវការលំបាករាប់មិនអស់ ហើយយើងក៏បានរិះរកគ្រប់វិធីទាំងអស់ដើម្បីបញ្ជូននិស្សិតរបស់យើងចេញទៅរៀននៅបរទេសនៅក្នុងដំណាក់កាលនៃការលំបាកទាំងនោះ។

សម្ដេចបានបន្តថា នៅក្នុងដំណាក់កាលមួយទសវត្សចុងក្រោយនេះកំណើនសេដ្ឋកិច្ចកម្ពុជាជាមធ្យមជាង ៨% ក្នុងមួយឆ្នាំ។ កំណើននេះមិនអាចកើតឡើងបានដោយសារការគ្រប់គ្រង និងដឹកនាំមិនច្បាស់លាស់នោះទេ ក៏ប៉ុន្តែគឺបានមកអាស្រ័យដោយការដឹកនាំ និងអាស្រ័យដោយកត្តាធនធានមនុស្សរបស់យើង ។ តែយ៉ាងណាក៏ដោយបញ្ហាធនធានមនុស្សនៅតែជាចំណោទធំសម្រាប់យើងដូចដែលវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន បានឆ្លុះបញ្ចាំងអំពីភាពពាក់ព័ន្ធគ្នារវាងម្ខាងគឺធនធានមនុស្សនិងម្ខាងទៀតការបណ្ដុះបណ្ដាលរបស់យើងមិនឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ។

សម្ដេចបន្តថា ឥឡូវនេះដំណាក់កាលនេះជាដំណាក់កាលនៃការធ្វើឯក-ទេសកម្ម។ នៅក្នុងការធ្វើឯកទេសកម្មនោះហើយដែលតែងតែឆ្លុះបញ្ចាំងថានិស្សិតដែលបានទទួលការងារធ្វើចំមុខជំនាញមានប៉ុន្មាន និងមិនចំមុខជំនាញមានប៉ុន្មាន ។ ឥឡូវនេះ ការបណ្ដុះបណ្ដាលធនធានមនុស្សរបស់យើងកាន់



*សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញប្រគល់សញ្ញាបត្រ ជ័យលាភីដល់គរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ*

តែមានតម្រូវការចាំបាច់ ដើម្បីបម្រើឱ្យទីផ្សារការងារនៅពេលដែលវិនិយោគបានមកដល់ដែលយើងត្រូវមានធនធានមនុស្សដើម្បីបម្រើការងារឱ្យគេ។ បម្រើឱ្យខ្សែសង្វាក់ផលិតកម្ម។ បើមិនដូច្នេះទេយើងនៅតែរត់មិនទាន់ដំណើរក្នុងស្រុករបស់យើង ក៏ដូចជាសមាហរណកម្មនៅក្នុងក្របខណ្ឌតំបន់ផងដែរ។ សម្តេចបញ្ជាក់ថា "ខ្ញុំក៏នៅតែបន្តអំពាវនាវដល់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ទាំងរដ្ឋ ទាំងឯកជន ត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាគុណភាពនៃការបណ្តុះបណ្តាល ដោយត្រូវធានាធ្វើយ៉ាងណាការបណ្តុះបណ្តាលទាំងអាហារូបករណ៍ ទាំងការសិក្សាបង់ថ្លៃនៅពេលបញ្ចប់ការសិក្សាត្រូវតែមានគុណភាព ដើម្បីបម្រើឱ្យទីផ្សារការងារ ។ ទាំងការងាររដ្ឋ ទាំងការងារឯកជនដែលជាតម្រូវការចាំបាច់ ហើយដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តការខិតខំធ្វើនូវកិច្ចការទាំងអស់នេះ" ។

តាមរបាយការណ៍របស់ក្រសួងអប់រំបានឱ្យដឹងថា បច្ចុប្បន្ននៅកម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាសរុបចំនួន ១០៤ ដែលក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋមានចំនួន ៣៩ និងឯកជនចំនួន ៦៥ និងមាននិស្សិតថ្នាក់បរិញ្ញាបត្ររងដល់បណ្ឌិតចំនួន ២២២.១៦៤ នាក់ ។ ជាមួយគ្នានេះក៏មានអន្តេវាសិកដ្ឋានចំនួន ៧ ខ្នង នៅរាជធានីភ្នំពេញ និងមាននិស្សិតកំពុងស្នាក់នៅប្រមាណ ៨០៤ នាក់ ក្នុងនោះស្រី ៥៧៣ នាក់ និងមាននិស្សិតបរទេស ១៤០ នាក់។

❀ រសៀលថ្ងៃទី ២១ ខែមីនា សម្តេចនាយករដ្ឋមន្ត្រីបានអញ្ជើញចូលរួមបិទសន្និបាតបូកសរុបការងារក្រសួងអប់រំយុវជន និងកីឡា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។ មានប្រសាសន៍នាពេលនោះសម្តេចបានបញ្ជាក់ថា នៅលើពិភពលោក មិនថាតែកម្ពុជាទេ ការកាត់បន្ថយគម្លាតរវាងអ្នកមានទ្រព្យសម្បត្តិ និងអ្នកគ្មានទ្រព្យសម្បត្តិ គឺជារឿងមិនអាចទៅរួចទេ ។ មានតែរបបប៉ុលពតមួយប៉ុណ្ណោះដែលអាចធ្វើបាន នោះគឺការបណ្តេញអ្នកមានចេញពីក្រុងភ្នំពេញ ហើយឱ្យរស់នៅរួមស៊ីរួម។ តែសម្រាប់រាជរដ្ឋាភិបាល គឺជាការលំបាកណាស់ ព្រោះយើងមិនអាចធ្វើដូច ប៉ុល ពត បានឡើយ យើងគួរទុកអ្នកមានទាំងនោះឱ្យគេយកធនធានរបស់គេមកវិនិយោគបង្កើតការងារសម្រាប់ពលរដ្ឋរបស់យើងវាប្រសើរជាង។ អ្វីដែលយើងធ្វើបាននៅពេលនេះគឺការកាត់បន្ថយគម្លាតខួរក្បាល"អ្នកឯងជាកូនអ្នកមានក៏ចូលរៀននៅបឋមសិក្សា ខ្ញុំជាកូនកម្មករក៏ចូលរៀននៅបឋមសិក្សាដូចគ្នាដែរ" ។កូនអ្នកមានរៀននៅវិទ្យាល័យរៀនបរិញ្ញាបត្រ រៀនបណ្ឌិត កូនអ្នកក្រក្មេងវត្តក៏អាចរៀនបានដូចគ្នា គ្រាន់តែស្ថានភាពជីវភាពខុសគ្នាតែប៉ុណ្ណោះ ។

សម្តេចបានបន្តថា ការកាត់បន្ថយគម្លាតផ្នែកខួរក្បាលគឺប្រសើរជាង និងងាយស្រួលជាងការកាត់បន្ថយគម្លាតផ្នែកទ្រព្យសម្បត្តិ ។ គោលនយោបាយពីមុនគឺឃុំមួយមានអនុវិទ្យាល័យមួយ ប៉ុន្តែគោលដៅបច្ចុប្បន្ន ឃុំមួយមានអនុវិទ្យាល័យច្រើន ហើយកូនអ្នកមាន កូនអ្នកក្រអាចចូលរៀនដូចគ្នាបាន។ ជាមួយគ្នានេះសម្តេចក៏បានឯកភាពជាមួយសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ ដែលស្នើឱ្យមានការដំឡើងកាំប្រាក់ជាស្វ័យប្រវត្តិ និងធ្វើការជ្រើសរើសគ្រូមកពីតំបន់ដែលខ្វះគ្រូ ហើយធ្វើការបណ្តុះបណ្តាលរួចបញ្ជូនទៅបង្រៀននៅតំបន់នោះវិញ ជៀសវាងការបញ្ជូនគ្រូពីតំបន់ផ្សេងទៅបង្រៀនតំបន់ផ្សេងមួយទៀតដែលធ្វើឱ្យគ្រូខ្លះត្រូវឈប់និងបោះបង់ចោលការបង្រៀនព្រោះតែកត្តាផ្សេងៗ ។

❀ ព្រឹកថ្ងៃទី ២៧ ខែមីនា សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមសម្ពោធដាក់ឱ្យប្រើប្រាស់នូវវារីអគ្គិសនីអាតៃដែលមានអានុភាព ១២០ មេហ្គាវ៉ាត់ និងអមដោយខ្សែបញ្ជូន ១៧៧ គីឡូម៉ែត្រ ពីអនុស្ថានីយរួមអូរសោមមកអនុស្ថានីយពោធិសាត់ ។ នៅទីនោះសម្តេចបានថ្លែងទាក់ទងទៅនឹងសិទ្ធិបញ្ចេញមតិ និងភាពរីកចម្រើននៃវិស័យអគ្គិសនីនៅកម្ពុជាពីពេលនេះរហូតទៅដល់ឆ្នាំ ២០១៨។

នៅចំពោះមុខអ្នកចូលរួមយ៉ាងច្រើនកុះករ សម្តេចតេជោបញ្ជាក់ថា សម្តេចគាំទ្ររាល់ការបញ្ចេញមតិ ប៉ុន្តែមិនមែនជាការបញ្ចេញមតិដែលនាំឱ្យប្រទេសជាតិមានសង្គ្រាមនោះទេ។ សូមបញ្ចេញមតិចុះ ប៉ុន្តែកុំនាំគ្នាបង្កើតសង្គ្រាម។ យើងបង្រួបបង្រួមជាតិនៅគ្រប់ពណ៌សម្បុរ កម្លាំងប្រដាប់អាវុធ ៤ ភាគីច្បាំងគ្នាមកនៅក្រោមរដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយ នីតិបញ្ញត្តិតែមួយ នីតិប្រតិបត្តិតែមួយ និងកម្លាំងប្រដាប់អាវុធតែមួយ ។ពីប្រទេសមួយតំបន់ត្រួតត្រាច្រើន ទៅជាប្រទេសមួយដែលមានតំបន់ត្រួតត្រាតែមួយ ដែលការណ៍នេះ មិនមែនជាការងាយស្រួលទេ" ។សម្តចបន្តថា "យើងបានយកជីវិតធ្វើដើមទុន ដើម្បីធ្វើឱ្យប្រទេសមានការបង្រួបបង្រួមគ្នា បែបនេះហើយការបង្រួបបង្រួម និងសន្តិភាពនោះហើយដែលផ្តល់ឱកាសឱ្យយើងបានអភិវឌ្ឍដូចសព្វថ្ងៃនេះ" ។

សម្តេចបានព្រមានថា "កុំនាំគ្នាបង្កើតសង្គ្រាម ព្រោះសង្គ្រាមតែកើតហើយមិនងាយនឹងរំលត់ទេ ។សង្គ្រាមធ្វើឱ្យវាកើតគឺងាយទេប៉ុន្តែរំលត់វាទើបជាការលំបាក" ។ ឥឡូវនេះទើបតែរំលងទៅប៉ុន្មានថ្ងៃប៉ុណ្ណោះ នៃខួប ៤៤ ឆ្នាំនៃរដ្ឋប្រហារទម្លាក់សម្តេច**ព្រះនរោត្តម សីហនុ ព្រះបិតាជាតិ**របស់យើង( ១៨ មីនា ១៩៧០-១៨ មីនា ២០១៤) ដែលបង្កើតឡើងនូវសង្គ្រាម ។ ការសម្រេចចិត្តតាមរបៀប លន់ នល់ , សិរិ មតៈ , ចេង ហេង , អ៊ិន តាំ ធ្វើតែមួយភ្លែត ប៉ុន្តែផលវិបាករបស់វាធ្វើឱ្យយើងដោះស្រាយមិនទាន់ចប់ទេ ដូចជាបញ្ហាមីនក្រោមដី ផលវិបាកនៃជនពិការ ស្ត្រីមេម៉ាយ និងកុមារកំព្រាជាដើម វាមិនទាន់ចប់ទេ ។

សម្តេចបានបន្តថា នៅពេលនេះនៅកម្ពុជាទោះជានរណានិយាយអីនិយាយទៅ ប៉ុន្តែពេលនេះកម្ពុជាមានស្ថិរភាពនយោបាយ និងស្ថិរភាពសង្គម ស្ថាប័នរដ្ឋគ្រប់ជាន់ថ្នាក់នៅដំណើរការធម្មតា ហើយសាលារៀន និងមន្ទីរពេទ្យជាដើមក៏ដំណើរការជាធម្មតា។ ដំណើរការនៃនយោបាយ សង្គម មានភាពជា

តនៅទំព័រទី ១៤

# សម្ដេចចក្រី ហេង សំរិន អញ្ជើញទៅបំពេញទស្សនកិច្ច នៅប្រទេសម៉ារ៉ុក និងប្រទេសកូឌីវ័រ




*សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ក្នុងឱកាសអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការ និងជាមិត្តភាពនៅប្រទេសម៉ារ៉ុក និងប្រទេសកូឌីវ័រ*

គណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា បានអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការ និងជាមិត្តភាពនៅប្រទេសម៉ារ៉ុក និងប្រទេសកូឌីវ័រ ក្នុងគោលបំណងពង្រឹង និងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា-ម៉ារ៉ុក និងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា-កូឌីវ័រ ឱ្យកាន់តែល្អប្រសើរថែមទៀត។

នៅក្នុងអំឡុងពេលបំពេញទស្សនកិច្ចជាផ្លូវការ និងមិត្តភាពនៅប្រទេសម៉ារ៉ុក និងប្រទេសកូឌីវ័រពីថ្ងៃទី ៣ ដល់ថ្ងៃទី ៩ ខែមីនា ឆ្នាំ ២០១៤ គណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាបានជួបសវនាការ និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងពីរ ជាអាទិ៍ ជាមួយឯកឧត្ដមប្រធានាធិបតី ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀត។

មានប្រសាសន៍ប្រាប់ក្រុមអ្នកសារព័ត៌មាននៅយប់ថ្ងៃទី ១០ មីនា នាអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងឱកាសអញ្ជើញវិលត្រឡប់ពីដំណើរទស្សនកិច្ចនៅប្រទេសទាំងពីរនោះ លោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការសាធារណការដឹកជញ្ជូនទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានមានប្រសាសន៍ថា ក្នុងដំណើរបំពេញទស្សនកិច្ចជាផ្លូវការរបស់គណៈប្រតិភូរដ្ឋសភាកម្ពុជាដឹកនាំដោយសម្ដេចពញាចក្រី **ហេង សំរិន** ទៅកាន់ប្រទេសម៉ារ៉ុក នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រម៉ារ៉ុកបានស្នើតាមរយៈសម្ដេចប្រធានរដ្ឋសភាកម្ពុជាដើម្បីឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរធ្វើការពង្រឹងកិច្ចសហប្រតិបត្តិការផ្លាស់ប្ដូរព័ត៌មានស្ដីអំពីស្ថានភាពសេដ្ឋកិច្ចនៃប្រទេសទាំងពីរ ក្នុងន័យស្វែងយល់ពីគ្នាទៅវិញទៅមក ដើម្បីពង្រឹងនូវកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច-សង្គម រវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ ភាគីម៉ារ៉ុកក៏បានស្នើផងដែរដល់ភាគីកម្ពុជាឱ្យមានការផ្លាស់ប្ដូរព័ត៌មានជុំវិញវិស័យទេសចរណ៍របស់ប្រទេសទាំងពីរ។ សម្ដេចពញាចក្រី **ហេង សំរិន** ក៏បានលើកឡើងពីគោលបំណងចង់ឱ្យប្រជាពលរដ្ឋម៉ារ៉ុកធ្វើដំណើរមកលេងប្រទេសកម្ពុជាឱ្យបានច្រើន ពីព្រោះកម្ពុជាជាប្រទេសដែលសំបូរទៅដោយតំបន់ទេសចរណ៍វប្បធម៌ធម្មជាតិ។ លោកជំទាវបន្តទៀតថា ក្នុងដំណើរទស្សនកិច្ចនេះផងដែរ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា-ម៉ារ៉ុក ក៏បានប្រកាសអំពីការបង្កើត ក្រុមមិត្តភាពរដ្ឋសភានៃប្រទេសទាំងពីរ ដែលខាងកម្ពុជា មានឯកឧត្ដម **ម៉ុក ម៉ារ៉េត** ប្រធានគណៈកម្មការផែនការវិនិយោគកសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក ជាប្រធានក្រុមមិត្តភាពរដ្ឋសភាកម្ពុជា។

ដោយឡែកនៅក្នុងឱកាសបំពេញទស្សនកិច្ចក្នុងប្រទេសកូឌីវ័រ សម្ដេចចក្រី **ហេង សំរិន** និងប្រតិភូអមដំណើរបានចូលជួបសម្ដែងការគួរសមជាមួយឯកឧត្ដម **អាឡាសាណេ អួរតារា** ប្រធានាធិបតីនៃសាធារណរដ្ឋកូឌីវ័រ នៅភូមិគ្រឹះក្នុងទីក្រុងអាប៊ីហ្សង់។

ក្នុងជំនួបនោះ ឯកឧត្ដម **អួរតារា** បានសម្ដែងការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះសម្ដេចចក្រី **ហេង សំរិន** និងប្រតិភូដែលបានមកបំពេញទស្សនកិច្ចនៅកូឌីវ័រ ហើយឯកឧត្ដមប្រធានាធិបតីបានចាត់ទុកដំណើរទស្សនកិច្ចនេះថាជាស្ពានមួយដ៏សំខាន់ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងសាធារណរដ្ឋកូឌីវ័រ និងព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្ដមប្រធានាធិបតីនៃសាធារណរដ្ឋកូឌីវ័របានសម្ដែងការកោតសរសើរ និងគាំទ្រចំពោះគំនិតផ្ដួចផ្ដើមរបស់រដ្ឋសភាកូឌីវ័រ ក្នុងការចាប់ផ្ដើមឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងប្រទេសទាំងពីរ។

លោកជំទាវ **និន សាផុន** បានបញ្ជាក់ថា ដំណើរទស្សនកិច្ចនេះបាននាំមកនូវជំហានថ្មីក្នុងការពង្រឹងនូវកិច្ចសហប្រតិបត្តិការ ពង្រឹងនូវមិត្តភាពសាមគ្គីភាពរវាងកម្ពុជា-ម៉ារ៉ុក និងកម្ពុជា-កូឌីវ័រ ឱ្យកាន់តែល្អប្រសើរឡើងថែមទៀត ដើម្បីផលប្រយោជន៍របស់ប្រជាជននៃ ប្រទេសទាំងពីរ។/

# ឯកឧត្តម សាយ ឈុំ ជួបសន្ទនាការជាមួយគណៈប្រតិភូសភាសហភាពអឺរ៉ុប



*ឯកឧត្តម **សាយ ឈុំ** ទទួលជួបសវនការជាមួយ*
*ឯកឧត្តម LANGEN WERNER ប្រធានគណៈប្រតិភូសភាសហភាពអឺរ៉ុប*

ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៤ ឯកឧត្តម **សាយ ឈុំ** ប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ១ ព្រឹទ្ធសភា បានទទួលជួបសវនការជាមួយ ឯកឧត្តម LANGEN WERNER ដែលបានដឹកនាំគណៈប្រតិភូសភា សហភាពអឺរ៉ុបចំនួន ១២ រូប ( ក្នុងនោះមាន សមាជិកសភា ៧ រូប ) មកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដែលជាគោលដៅចុងក្រោយនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅតំបន់អាស៊ី ។ពិធីនេះបានប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា ។

ឯកឧត្តមLANGEN WERNER ប្រធានគណៈប្រតិភូសភាសហភាពអឺរ៉ុប បានសម្តែងអំណរគុណចំពោះឯកឧត្តមប្រធានគណៈប្រចាំការដែលបានទទួលជួបធ្វើសវនការ ហើយបានបញ្ជាក់ពីគោលបំណងនៃគណៈប្រតិភូមកកម្ពុជា គឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីសភាពការណ៍នៅកម្ពុជាផង និងពង្រឹងទំនាក់ទំនងសហប្រតិបត្តិការរវាងសហភាពអឺរ៉ុប និងកម្ពុជាផង រួមទាំងទំនាក់ទំនងជាមួយរដ្ឋសភាកម្ពុជា ។ គណៈប្រតិភូបានស្នើឱ្យឯកឧត្តមប្រធានគណៈប្រចាំការពន្យល់បញ្ជាក់អំពីបញ្ហាមួយចំនួន ជាអាទិ៍អំពីសភាពការណ៍នយោបាយក្រោយពេលបោះឆ្នោត អំពីការអនុវត្តនូវសិទ្ធិសេរីភាពនៅកម្ពុជា ការប្រឆាំងអំពើពុករលួយ រចនាសម្ព័ន្ធចាត់តាំងរបស់គណបក្សប្រជាជនកម្ពុជា ការជ្រើសតាំងបេក្ខជនឈរឈ្មោះបោះឆ្នោត ទំនាក់ទំនងរវាងគណបក្សជាមួយរដ្ឋាភិបាល ការចូលរួមរបស់ស្ត្រីក្នុងនយោបាយ ព្រមទាំងការងារជាអាទិភាពរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ប៉ុន្មានឆ្នាំខាងមុខនេះទៀត ។

ឯកឧត្តម **សាយ ឈុំ** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូ ហើយបានសម្តែងនូវការសប្បាយរីករាយ និងមោទនភាពចំពោះទំនាក់ទំនងដ៏ល្អរវាងសហភាពអឺរ៉ុប និងកម្ពុជា ។ ឯកឧត្តមក៏បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសហភាពអឺរ៉ុបដែលបានសរសើរដល់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នៅកម្ពុជាកន្លងមកថាបានប្រព្រឹត្តទៅប្រកបដោយសន្តិភាព មានភាពស្ងប់ស្ងាត់ ។ ទាក់ទងទៅនឹងសំណួរផ្សេងៗរបស់គណៈប្រតិភូ ឯកឧត្តមបានមានប្រសាសន៍ថា ក្នុងការបោះឆ្នោតកន្លងមកនេះ គណបក្សប្រជាជនកម្ពុជាបានទទួលជោគជ័យ តែមានការថយចុះអាសនៈចំនួន ២២ ឯ គណបក្សប្រឆាំងបានកើនអាសនៈច្រើន ។ នេះជាលទ្ធផលគួរឱ្យភ្ញាក់ផ្អើល តែគណបក្សប្រជាជនកម្ពុជាបានទទួលយកលទ្ធផលនេះ ហើយបានកំណត់ច្បាស់ថា ការឈ្នះ ឬចាញ់ ការកើន ឬថយអាសនៈ ការកើន ឬថយសំឡេងគាំទ្រ គឺជារឿងធម្មតានៃការបោះឆ្នោតតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ប្រកបដោយលក្ខណៈសេរី និងយុត្តិធម៌ ។ ផ្ទុយទៅវិញគណបក្សប្រឆាំងបានប្រកាសថាខ្លួនជាអ្នកឈ្នះឆ្នោត ហើយបានចោទប្រកាន់អំពីការលួចបន្លំក្នុងការបោះឆ្នោត ។ ឯកឧត្តមបានស្នើឱ្យគណៈប្រតិភូពិចារណាលើចំណុចពីរវិញដើម្បីយល់ការពិត : បើគណបក្សប្រជាជនកម្ពុជាលួចបន្លំ ហេតុអ្វីមិនបន្លំឱ្យឈ្នះតែម្តង ម្តេចក៏ឱ្យថយចុះ ២២ អាសនៈទៅវិញ ម្យ៉ាងទៀតនៅពេលបោះឆ្នោត នៅគ្រប់ការិយាល័យបោះឆ្នោត គណបក្សប្រឆាំងសុទ្ធតែមានភ្នាក់ងារអង្កេតការណ៍របស់ខ្លួនដែលបានតាមពិនិត្យមើលដំណើរការបោះឆ្នោតតាំងពីដើមដល់ចប់ និងបានចុះហត្ថលេខាទទួលស្គាល់លើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតទាំងអស់គ្នា ។

អំពីការអនុវត្តសិទ្ធិសេរីភាពនៅកម្ពុជាឯកឧត្តមបញ្ជាក់ថានៅកម្ពុជាមានការគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃកម្ពុជា និងសេចក្តីថ្លែងការណ៍ជាសកលរបស់អង្គការសហប្រជាជាតិ ព្រមទាំងកតិកា និងអនុសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស តែទោះយ៉ាងណាក៏នៅមានការខ្វះចន្លោះ មិនទាន់បានល្អ ១០០% ឡើយ ។ អំពីអំពើពុករលួយ ឯកឧត្តមបានធ្វើការកត់សម្គាល់ថាពិតជានៅមានមន្ត្រីខ្លះបានប្រព្រឹត្តអំពើពុករលួយ ប៉ុន្តែវាមិនអាក្រក់ដូចបុគ្គលខ្លះបាននិយាយនោះទេ ។ ចំណុចនេះបានបង្ហាញច្បាស់ក្នុងលទ្ធផលនៃការបោះឆ្នោតជាបន្តបន្ទាប់កន្លងមក ទាំងការបោះឆ្នោតថ្នាក់ជាតិ និងក្រោមជាតិ ប្រសិនបើវាអាក្រក់ដូចគេនិយាយនោះ ប្រជាជនពិតជាមិនបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជាទេ ។ ចំពោះទំនាក់ទំនងរវាងគណបក្ស និងរដ្ឋាភិបាល លើមូលដ្ឋានដែលគណបក្សប្រជាជនកម្ពុជាបានឈ្នះឆ្នោត កម្មវិធីនយោបាយរបស់គណបក្សបានប្រែក្លាយជាកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ហើយដែលកំពុងតែត្រូវបានអនុវត្ត ។ នៅក្នុងគណបក្ស គណៈអចិន្ត្រៃយ៍ធ្វើសេចក្តីសម្រេចធំៗដូចជាការចរចាជាមួយគណបក្សប្រឆាំងជាដើម គឺត្រូវមានការពិភាក្សាក្នុងគណៈអចិន្ត្រៃយ៍ ។ អំពីការចូលរួមរបស់ស្ត្រីក្នុងនយោបាយ ឯកឧត្តមបានបញ្ជាក់ថា គណបក្សប្រជាជនមានគោលនយោបាយជំរុញឱ្យស្ត្រីចូលរួមមានសមាមាត្រពី ៣០% ឡើង ប៉ុន្តែបច្ចុប្បន្ននៅពុំទាន់អនុវត្តបាននៅឡើយ ។ ក្នុងចំណុចនេះឯកឧត្តមប្រធានគណៈប្រតិភូបានបញ្ជាក់ថា ក្នុងសភាសហភាពអឺរ៉ុបក៏ទើបតែមានស្ត្រីពី ៣០-៣៥% ប៉ុណ្ណោះ ។

ឆ្លើយតបនឹងសំណួរថា គណបក្សប្រជាជនមានសមាជិកជាង ៥ លាននាក់ តែបានទទួលសំឡេងគាំទ្រជាង ៣,២ លាននាក់ តើគណបក្សប្រជាជនកម្ពុជាមានយុទ្ធសាស្ត្រដូចម្តេច ដើម្បីឱ្យសមាជិកបោះឆ្នោតគាំទ្រនៅពេលខាងមុខទៀត ? ឯកឧត្តមបានបញ្ជាក់ថា ការបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ គឺជាសិទ្ធិ សេរីភាព របស់ប្រជាពលរដ្ឋ គណបក្សប្រជាជនកម្ពុជាគោរពនូវសិទ្ធិ សេរីភាពរបស់ប្រជាជន ។ ដូច្នេះអ្នកពេញចិត្តកម្មវិធីនយោបាយគណបក្ស គេបោះឱ្យគណបក្ស តែក៏មានសមាជិកមិនពេញចិត្តដោយប្រការណាមួយ គេមិនបោះឆ្នោតឱ្យគណបក្សដែរ ។ តទៅមុខទៀតគណបក្សប្រជាជន



*ទិដ្ឋភាពរួមនៃកិច្ចសន្ទនាការជាមួយគណៈប្រតិភូសភាសហភាពអឺរ៉ុប*

កម្ពុជានឹងបន្តពង្រឹងសមាជិកគណបក្សទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ។

ចំពោះអាទិភាពនយោបាយក្នុងពេលទៅមុខទៀតនេះ គណបក្សប្រជាជនកម្ពុជានឹងផ្តោតលើការធានាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការធានាការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

ឯកឧត្តម LANGEN WERNER បានថ្លែងអំណរគុណចំពោះឯកឧត្តមប្រធានគណៈប្រចាំការដែលបានផ្តល់នូវខ្លឹមសារដ៏ល្អ និងបានលើកសំណួរបន្ថែមថា តើគណបក្សប្រជាជនកម្ពុជាមានអ្វីចង់បញ្ជូនទៅគណបក្សប្រឆាំងតាមរយៈគណៈប្រតិភូ? ឯកឧត្តមប្រធានគណៈប្រចាំការបានបង្ហាញនូវទស្ស-នៈផ្ទាល់ថា មានតែការចរចាទេទើបអាចដោះស្រាយបញ្ហាបានពិតប្រាកដ បើខ្មែរនិងខ្មែរមិនត្រូវគ្នាទេ គ្មានអ្នកណាអាចមកត្រូវគ្នាជួសខ្មែរបានឡើយ ។

កិច្ចសន្ទនាការបានបញ្ចប់ក្នុងបរិយាកាសដ៏រីករាយស្និទ្ធស្នាលនិងកក់ក្តៅ ។/

តមកពីទំព័រទី ១១

ធម្មតាដូចនេះអ្វីៗក៏ធម្មតា ។ប៉ុន្តែការធ្វើសកម្មភាពអ្វីក៏ដោយត្រូវគោរពច្បាប់ ហើយសូមកុំឱ្យហួសពីក្របខណ្ឌច្បាប់នោះ ។សម្តេចក៏បានអំពាវនាវដល់ពល-រដ្ឋខ្មែរទាំងអស់ត្រូវរួបរួមឯកភាពជាតិ ពិសេសអ្នកនៅមូលដ្ឋានកុំឱ្យមានទំនាស់នឹងគ្នា ដោយសារតែការបែងចែកគណបក្សនយោបាយនៅក្រោយការបោះឆ្នោត ។

សម្តេចក៏បានធ្វើការឆ្លុះបញ្ចាំងពីស្ថានភាពនយោបាយនៅកម្ពុជានារយៈពេលចុងក្រោយនេះដែរដោយបញ្ជាក់ថា នៅក្នុងប្រទេសយើងឥឡូវមានមនុស្សតែ ២ ក្រុមទេ គឺក្រុមដើរបន្ទុចបង្អាក់ដល់រាល់កិច្ចដំណើរការអភិវឌ្ឍន៍ប្រទេសជាតិរបស់រាជរដ្ឋាភិបាល ដើរបំផុសផ្សព្វផ្សាយឱ្យបរទេសផ្តាច់ជំនួយកម្ពុជាកុំឱ្យមានវិនិយោគិនមកវិនិយោគនៅកម្ពុជា បរិហារកេរ្តិ៍រាជរដ្ឋាភិបាល និងឱ្យបរទេសមើលងាយជាតិសាសន៍ខ្លួនឯងជាដើម និងក្រុមមួយទៀតជាក្រុមដែលខិតខំស្វះស្វែងកៀងគររកជំនួយ និងវិនិយោគិនបរទេសឱ្យមកជួយវិនិយោគនៅក្នុងប្រទេស ឱ្យមានការរីកចម្រើន មានកំណើនសេដ្ឋកិច្ចប្រជាពលរដ្ឋរួចចាកផុតពីភាពក្រីក្រ ។ បើតាមសម្តេចពន្យល់ក្នុងចំណោមក្រុមទាំង ២ នេះ គឺក្រុមដែលខិតខំកៀងគរវិនិយោគបរទេសឱ្យមករកស៊ីនៅកម្ពុជាគឺជាអ្នកទទួលបានជោគជ័យ ។

ទន្ទឹមនេះសម្តេចតេជោក៏បានព្រមានផងដែរ កម្ពុជាជាប្រទេសរបស់ប្រជាជនកម្ពុជា មិនមែនជាប្រទេសរបស់អ្នកណាម្នាក់ទេ ហើយចាប់ប្រទេសធ្វើជាចំណាប់ខ្មាំងក៏អត់បានដែរ ។ ការពិតអ្នកដែលសម្លាប់ប្រជាជនមិនមែនរាជរដ្ឋាភិបាលទេ ព្រោះរាជរដ្ឋាភិបាលបាននិងកំពុងប្រឹងប្រែងដើម្បីធ្វើយ៉ាងណាដោះស្រាយបញ្ហាទឹក បញ្ហាផ្លូវ បញ្ហាភ្លើង បញ្ហាមនុស្ស បញ្ហាសន្តិភាពនិងបញ្ហាស្ថិរ-ភាពនយោបាយ ។

ទាក់ទងនឹងវិស័យអគ្គិសនី សម្តេចបានចាត់ទុកសមិទ្ធផលដែលសម្ពោធនាថ្ងៃនេះ (វារីអគ្គិសនីអាតៃ) នឹងដោះស្រាយបាននូវកង្វះអគ្គិសនីនៅក្នុងរាជ-ធានីភ្នំពេញ ដែលកាលពីឆ្នាំមុនមានការខ្វះខាត និងតំបន់មួយចំនួនទៀត ហើយក៏នឹងពង្រីកវិសាលភាពនៅក្នុងការផ្គត់ផ្គង់អគ្គិសនីសម្រាប់ក្របខណ្ឌនៅទូទាំងប្រទេស ។ សម្តេចបន្តថា "យើងនឹងចេញដំណើរជាបន្តបន្ទាប់នូវអគ្គិសនីរបស់យើង ហើយបើយោងតាមការព្យាករណ៍ពីពេលនេះដល់ឆ្នាំ ២០១៨ នឹងមិនមានការខ្វះអគ្គិសនីនោះទេ ជាមួយនឹងការផលិត បូកជាមួយនឹងការរៀបចំបណ្តាញចែកចាយបន្តបន្ទាប់ រួមនឹងការជំរុញទៅកាន់តំបន់ដែលកំពុងប្រើប្រាស់អគ្គិសនីដែលក្រុមហ៊ុនឯកជនផលិតដើម្បីទាក់ថ្លក់ខ្សែបណ្តាញអគ្គិសនីរបស់រដ្ឋឱ្យទៅដល់តំបន់នោះ ហើយធ្វើឱ្យតម្លៃភ្លើងធ្លាក់ចុះ ។ បើទោះជាមិនតាមបំណងដែលចង់បាន ក៏យ៉ាងហោចណាស់អាចទម្លាក់តម្លៃភ្លើងអគ្គិសនីឱ្យបានទាបជាងពេលមុនដែរ ។ សម្តេចនាយករដ្ឋមន្ត្រីបានចាត់ទុកការវិនិយោគនេះជាសមិទ្ធផលដ៏ធំមួយដែលរាជរដ្ឋាភិបាលទទួលជោគជ័យនៅក្នុងការទាក់ទាញផ្នែកឯកជនចូលរួមក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។

ទាក់ទងនឹងវារីអគ្គិសនីអាតៃនេះ ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលបានឱ្យដឹងថា គម្រោងនេះវិនិយោគដោយក្រុមហ៊ុនមកពីប្រទេសចិន ក្នុងនោះមានក្រុមហ៊ុន China Datang Corporation វិនិយោគវារីអគ្គិសនីស្ទឹងអាតៃ ចំណែកក្រុមហ៊ុន CHD Cambodia Hydropower Co., Ltd ។ អនុ-វត្តការ សាងសង់ខ្សែបណ្តាញ ។ ការវិយោគកើនគម្រោងវារីអគ្គិសនីស្ទឹងអាតៃមានទំហំទឹកប្រាក់វិនិយោគ ២៥៥ លាន ៣ សែន ដុល្លាអាមេរិក ដែលវិនិយោគតាមរូបភាពសាងសង់ ដំណើរការផ្ទេរ (BOT) និងតាមរូបភាពសាងសង់ ផ្ទេរ (BT) សម្រាប់អនុស្ថានីយរួមអូរសោម និងខ្សែបណ្តាញបញ្ជូនទៅអនុស្ថានីយពោធិ៍សាត់ ១៧៥ គីឡូម៉ែត្រ ។ បរិមាណផលិតបានជាមធ្យមប្រចាំឆ្នាំ ៤៦៥ លានគីឡូវ៉ាត់ម៉ោងក្នុងមួយឆ្នាំ ថ្លៃថាមពលអគ្គិសនីមូលដ្ឋាន ៧,១៤ សេនដុល្លារអាមេរិក ក្នុងមួយគីឡូវ៉ាត់ម៉ោង ក្នុងនោះ ៥,៨ សេនដុល្លារ គឺជាថ្លៃផលិតដោយវារីអគ្គិសនីស្ទឹងអាតៃ និង ១,៣៤ សេនដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោង គឺជាថ្លៃរំលស់លើការវិនិយោគខ្សែបណ្តាញបញ្ជូនភ្ជាប់មកអនុស្ថានីយពោធិ៍-សាត់ ។ ឯគម្រោងទីពីរខ្សែបណ្តាញបញ្ជូនភ្នំពេញ-កំពង់ឆ្នាំង-ពោធិ៍សាត់-បាត់ដំបង ដែលមានប្រវែង ៣០២ គីឡូម៉ែត្រ មានទំហំទឹកប្រាក់វិនិយោគ ១១៣ លាន៣សែន ៩ ម៉ឺនដុល្លារ វិនិយោគតាមរូបភាពសាងសង់ ដំណើរការផ្ទេរ (BOT) ដែលមានរយៈពេលសម្បទាន ២៧ ឆ្នាំ ក្នុងនោះ ២ ឆ្នាំសម្រាប់ការសាងសង់ និង ២៥ ឆ្នាំ សម្រាប់ធ្វើអាជីវកម្ម ។

គួបញ្ជាក់ថា គម្រោងវារីអគ្គិសនីអាតៃគឺជាគម្រោងមួយស្ថិតនៅក្នុងតំបន់ត្រីកោណខេត្តកំពង់ស្ពឺ ខេត្តកោះកុង និងខេត្តពោធិសាត់ ដែលមានស្ថានីយក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិសាត់ មានចម្ងាយប្រមាណ ១៧៥ គីឡូ-ម៉ែត្រ ពីទីរួមខេត្តពោធិសាត់ ។ ជារៀងរាល់ឆ្នាំស្ទឹងអាតៃដែលមានផ្ទៃរងទឹកភ្លៀង ៥៩០ គីឡូម៉ែត្រក្រឡា បានត្រងយកទឹកភ្លៀងបានប្រមាណ ៥១០ លានម៉ែត្រត្រីគុណ ហើយនាពេលកន្លងមក បរិមាណទឹកនេះបានហូរចូលក្នុងទឹកសមុទ្រ ដោយពុំមានការប្រើប្រាស់អ្វីទេ ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៤ ឯកឧត្តមបណ្ឌិត **ឃួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ១ រដ្ឋសភា ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យពុទ្ធាភិសេកឆ្លងសមិទ្ធផលនានាក្នុងវត្តមង្គលវ៉ែន ហៅវត្តជ្រង ស្ថិតក្នុងឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ដោយឡែកនៅថ្ងៃទី ២២ ខែ ឆ្នាំដដែល ឯកឧត្តមបណ្ឌិត **ឃួន ញឹល** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យបញ្ចុះខ័ណ្ឌសីមាព្រះវិហារវត្តនិរន្តកោសីយ៍ ហៅវត្តអន្លង់លោក ស្ថិតក្នុងឃុំព្រៃគុយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ក្នុងឱកាសអញ្ជើញជាអធិបតីទាំងពីរកន្លែងបន្ទាប់ពីបានបំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាជូនមន្ត្រីរាជការ និងសប្បុរសជនដែលបានរួមចំណែកកសាង និងអភិវឌ្ឍន៍មូលដ្ឋាន និងទីអារាមឱ្យមានការរីកចម្រើនរួចមក ឯកឧត្តមបណ្ឌិត **ឃួន ញឹល** បានប្រគេនបច្ច័យ សម្ភារៈ សម្រាប់កសាងសមិទ្ធផលនានាក្នុងវត្តទាំងពីរ ប្រគេនព្រះមេគណខេត្តកំពង់ធំ ប្រគេនព្រះអនុគណស្រុកបារាយណ៍ ប្រគេនចៅអធិការវត្ត នូវទេយ្យទាន និងបច្ច័យ ជូនចាស់សីលវតី លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ឧបត្ថម្ភសាលាស្រុកបារាយណ៍ និងសាលាឃុំឈូកខ្សាច់ សាលាស្រុកកំពង់ស្វាយ ព្រមទាំងឧបត្ថម្ភក្មួយៗកាន់ខ្សែបូ និងក្រុមភ្លេងពិណពាទ្យ ដែលសរុបថវិកាទាំងអស់ចំនួន ៦៨.៤៦៥.00 រៀល ។



*ថ្ងៃទី ១៣ មីនា ឆ្នាំ ២០១៤ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការ កណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រួមដំណើរដោយមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលជាច្រើនរូបទៀត បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ទីស្នាក់ការថ្មីរបស់សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តតាកែវ ។*

*ថ្លែងនៅក្នុងពិធីសម្ពោធ ឯកឧត្តម **សុខ អាន** បានធ្វើការកត់សំគាល់ថា នេះគឺជាសមិទ្ធផលថ្មីដ៏សំខាន់មួយទៀតរបស់សហភាពសហព័ន្ធយុវជនកម្ពុជា ជាពិសេសសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តតាកែវ ។ នេះជាមោទនភាព និង សេចក្តីរំភើបរីករាយនៅពេលឃើញយុវជនកម្ពុជាបំពេញសកម្មភាពសង្គមយ៉ាងផុលផុសក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួនដើម្បីចូលរួមអភិវឌ្ឍប្រទេសដូចជាការបរិច្ចាគឈាមការពិនិត្យសុខភាពជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ការចុះសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយអគ្គិភ័យ ចុះជួយសង់ផ្ទះជូនប្រជាពលរដ្ឋរងគ្រោះដោយខ្យល់ព្យុះ ការជ្រើសរើសសិស្សពូកែ ការផ្តល់អាហារូបករណ៍ថ្នាក់ឧត្តមសិក្សា ការបញ្ជូនសិស្សនិស្សិតទៅចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការតម្រង់ទិសយុវជនក្រោយបញ្ចប់មធ្យមសិក្សាទុតិយភូមិ ការរៀបចំការប្រកួតកីឡា ការរៀបចំពិធីដាំកូនឈើ ទស្សនកិច្ចសិក្សាស្វែងយល់ពីសាលាក្តីខ្មែរក្រហម និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកជាដើម ។*



ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៤ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានាក្នុងវត្តសីមាសុវណ្ណគិរី ស្ថិតក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ។ សមិទ្ធផលទាំងនោះរួមមាន ព្រះវិហារ ខ្លោងទ្វាររបង និងជងទង់ ១ គូ ។ ក្នុងឱកាសនោះ លោកជំទាវ **ម៉ែន សំអន** បានបំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាជូនមន្ត្រីរាជការ និងសប្បុរសជនដែលបានរួមចំណែកកសាង និងអភិវឌ្ឍន៍មូលដ្ឋាន និងទីអារាមឱ្យមានការរីកចម្រើន និងប្រគេនបច្ច័យចំនួន ២០ លានរៀល រួមទាំង ២២១០ ដុល្លារអាមេរិក សម្រាប់រួមចំណែកកសាងទីអារាម សីមាសុវណ្ណគិរី ព្រមទាំងបានជូនអំណោយអនុស្សាវរីយ៍ជូនដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ ចាស់សីលវតី ប្រជាពលរដ្ឋ និងកម្លាំងការពារផងដែរ ។



*ក្នុងខែមីនានេះដែរ ឯកឧត្តម **កែ គឹមយ៉ាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន បានអញ្ជើញចូលរួមបញ្ចុះខ័ណ្ឌសីមា និងឆ្លងសិមិទ្ធិនានានៅវត្តចម្ការខ្នុរ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៤ លោក ជំទាវ **ឃួន សុដារី** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជាអនុប្រធានទី២នៃរដ្ឋសភា អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់សមិទ្ធិផលនានាក្នុង វត្តមណិរតនារាម ហៅវត្តពាមរាំងក្រោម ស្ថិតក្នុងឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្ដាល។

ក្នុងពិធីនោះលោកជំទាវ **ឃួន សុដារី** បានប្រគេនបច្ច័យកសាងវត្តចំនួន១៣លាន៤សែនរៀលដល់ព្រះចៅអធិការវត្តមណិរតនារាមប្រគេនបច្ច័យព្រះសង្ឃ៦អង្គ លោកគ្រូអ្នកគ្រូ៦២នាក់ យុវជនកាកបាទក្រហមកម្ពុជា និងសិស្សកាយរិទ្ធ១០០នាក់ សិស្សានុសិស្សចំនួន១០០នាក់ សាលាឃុំពាមរាំង ក្រុមការងារ វេទិកា ស្ត្រីយ៉ៗនារី កាន់ខ្សែបូ ៥នាក់កងកម្លាំងការពារ ២០នាក់ និងតាជីយាយជី៥០នាក់និងបានវេទេយ្យទាន ប្រគេនព្រះសង្ឃ មានអង្ករ ១៥០គីឡូក្រាម ទឹកក្រូច៤កេស ទឹកសុទ្ធ៦កេស និង ម្សៅសាប៊ូមួយចំនួនដល់ព្រះសង្ឃផងដែរ។ បន្ទាប់មកនៅព្រឹកថ្ងៃដដែលលោកជំទាវ **ឃួន សុដារី** បានអញ្ជើញចូលរួមក្នុងពិធីបុណ្យផ្កាសាមគ្គីនៅវត្តព្រែកទម្លាប់ ឃុំព្រែកទម្លាប់ ស្រុកលើកដែក ខេត្តកណ្ដាល ដោយបាននាំយកអង្ករ១០០គីឡូក្រាម ទឹកក្រូច ៤កេស ទឹកសុទ្ធ៦កេសនិងបច្ច័យ៦លាន៨សែនរៀលចូលរួមក្នុងពិធីបុណ្យផ្កាសាមគ្គី និងបានប្រគេនបច្ច័យព្រះគ្រូចៅអធិការវត្តចំនួន១០ម៉ឺនរៀល សាដក១និងព្រះសង្ឃ៦អង្គក្នុង១អង្គៗ សាដក១បច្ច័យ៥ម៉ឺនរៀល ។



*ថ្ងៃទី ២៤ ខែមីនា ឯកឧត្ដម **អ៊ឹម ឈុនលឹម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានអញ្ជើញសម្ពោធឆ្លងឧបដ្ឋានសាលានៅវត្តគីរីវនារាមនៃភូមិដូក្រូចឃុំថ្ម អណ្ដើក ស្រុកចិត្របុរី ខេត្តក្រចេះ ។ ឧបដ្ឋានសាលានេះមានបណ្ដោយ ៣០ ម៉ែត្រ និងទទឹង ១៨ ម៉ែត្រ ដោយចំណាយថវិកា ១៨០ លានរៀល ដែលបានមកពីលោកទេសរដ្ឋមន្ត្រីផ្ទាល់ និង ពីមន្ត្រីក្រុមការងារថ្នាក់ក្រសួង ព្រមទាំងសប្បុរសជនគ្រប់ទិសទី ។*



ថ្ងៃទី ២០ ខែមីនា ឯកឧត្ដម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា និងជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា បានអញ្ជើញជួបសំណេះសំណាល និងសម្ពោធអគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ ដែលមានកម្ពស់ ២ ជាន់កន្លះ ស្ថិតនៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។



*ថ្ងៃទី ១៥ ខែមីនា ឯកឧត្ដម **វង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលោកជំទាវ តំណាងដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា បានអញ្ជើញសម្ពោធឧបដ្ឋានសាលា និងសមិទ្ធផលនានាក្នុងវត្តសាមគ្គីសុខារាម ហៅវត្តច្រករំដេង នៅភូមិច្រករំដេង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី ២៤ ខែមីនា ឯកឧត្តម **ត្រាំ អ៊ីវតឹក** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងអ្នកជំនាញ បានអញ្ជើញពិនិត្យគម្រោងស្ថាបនាផ្លូវជាតិលេខ ៥០ សេ តភ្ជាប់ពីខេត្តកំពង់ឆ្នាំងទៅខេត្តកំពង់ធំ ។ ផ្លូវជាតិនេះត្រូវស្ថាបនាថ្មីទាំងស្រុងមានប្រវែងជាង ៦០ គីឡូម៉ែត្រ ដោយតភ្ជាប់ពីភូមិស្រយ៉ូវ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ មកកាន់ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។



ថ្ងៃទី ១៣ ខែមីនា ឯកឧត្តម **គោស៊ុំ សារឿត** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ បានអញ្ជើញផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនពលរដ្ឋកាន់កាប់ចុងក្រោយបង្អស់នៅភូមិបឹងស្នោរ ឃុំស្លក្រាម ស្រុកស្វាយចេក ។

*ថ្ងៃទី១១ខែមីនាឯកឧត្តម **ជា សុផារ៉ា** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឯកឧត្តម **វង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម **ប្រាជ្ញ ចន្ទ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា និងមន្ត្រីសំខាន់ៗមួយចំនួនទៀតបានអញ្ជើញចូលរួមក្នុងវេទិកាសាធារណៈដែលរៀបចំឡើងនៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។*



*ថ្ងៃទី ២២ ខែមីនា ឯកឧត្តម **លូ គឹមឈុន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានអញ្ជើញសម្ពោធមហាឧបដ្ឋានសាលា និងសមិទ្ធផលនានានៅវត្តប្រាសាទវត្តី ហៅវត្តត្បូង ក្នុងឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ មហាឧបដ្ឋានសាលាមានបណ្ដោយ ៤៥ម៉ែត្រទទឹង២៥ម៉ែត្រ ខ្លោងទ្វារវត្តផ្លូវបេតុងនិងសមិទ្ធផលមួយចំនួនទៀតដែលបានកសាងចាប់ពីឆ្នាំ ២០០៨-២០១៤ ដោយចំណាយថវិកាចំនួន ៥២២.២៥០ ដុល្លារ ។*



# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

**ចំណូលពន្ធដារ៣ខែដើមឆ្នាំ២០១៤ :**

អគ្គនាយកដ្ឋានពន្ធដារបានឱ្យដឹងថា លទ្ធផលចំណូលពន្ធដារនៅត្រីមាសទីមួយដើមឆ្នាំ ២០១៤ នេះ គិតត្រឹមសប្តាហ៍ ទី ៣ នៃខែមីនា ពន្ធដាររកបានចំណូលពន្ធប្រមាណ ៧៦៧,៧ ពាន់លានរៀល ឬប្រមាណជិត ១៩២ លានដុល្លារ ។ ចំណូលនេះសម្រេចបានស្មើនឹង ១៩,៣% នៃផែនការឆ្នាំ ២០១៤ ។ ប្រាក់ចំណូលនេះមិនទាន់បានគិតបញ្ចូលពន្ធនៃប្រាក់ចំណេញដែលមិនទាន់បានបិទបញ្ជីនៅឡើយទេ ។ គេរំពឹងថាចំណូលពន្ធនឹងមានការកើនឡើងក្រោយពីថ្ងៃបិទបញ្ចប់នៃការប្រមូលពន្ធលើប្រាក់ចំណេញនេះនៅដំណាច់ខែមីនានេះ ។

**គ្រឿងយន្តកសិកម្ម :**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានឱ្យដឹងថា នៅក្នុងរដូវបង្កបង្កើនផលស្រូវវស្សាឆ្នាំ ២០១៣-២០១៤ នេះ គឺមានផ្ទៃដីសរុបប្រមាណ ៣ ២៧៤ ៧៥៨ ហ.ត នៅក្នុងនោះការភ្ជួរដោយសត្វគោ និងក្របីមានចំនួនប្រមាណ ៩៦០ ៦៨៩ ហ.ត ពោលគឺតិចជាងឆ្នាំមុនប្រមាណ ២១៣ ៣០៤ ហ.ត ។ នេះដោយសារកំណើននៃគ្រឿងយន្តកសិកម្ម ។

នៅទូទាំងប្រទេសសព្វថ្ងៃ(គិតត្រឹមខែកុម្ភៈឆ្នាំ២០១៤) មាន គ្រឿងចក្រជាត្រាក់ទ័រកសិកម្មចំនួន៦២៣២គ្រឿងនិងគោយន្តចំនួនប្រមាណ១០៣០០៩គ្រឿងខណៈដែលសត្វពាហនៈពិសេសគឺសត្វ គោនិងក្របីដែលជាកម្លាំងអូសទាញប្រពៃណីរបស់កសិករមាន ប្រមាណ៤,០៥ លានក្បាល ។ ក្រៅពីត្រាក់ទ័រ និងគោយន្ត មានការប្រើប្រាស់ម៉ាស៊ីនបូមទឹកចំនួន ២៣៩ ៦៧៦ គ្រឿងម៉ាស៊ីនច្រូតចំនួន៤០៤៨គ្រឿង ម៉ាស៊ីនបោក និងបូតស្រូវចំនួន ១១ ៨០៩ គ្រឿង ម៉ាស៊ីនសម្ទូតមានចំនួន៥៦ គ្រឿង និងម៉ាស៊ីនកិនស្រូវ ទាំងតូចទាំង ធំប្រមាណ ៤១ ៦០៥ គ្រឿង ។

**ការផ្គត់ផ្គង់សាច់ :**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់ថា នៅក្នុងមួយឆ្នាំកម្ពុជាអាចមានសមត្ថភាពផលិតសាច់សម្រាប់ផ្គត់ផ្គង់ទីផ្សារនៅក្នុងស្រុកប្រមាណ ២៦២០០០តោន ។ផលិតផលសាច់សត្វទាំងនេះគឺបានមកពីអាជីវកម្មចិញ្ចឹមសត្វជាកសិដ្ឋាន និងគ្រួសាររបស់អ្នកវិនិយោគ និងកសិករតាមគ្រួសារនៅក្នុងប្រទេស ។ នៅក្នុងឆ្នាំកន្លងទៅ ការធ្វើសត្តឃាតកម្មជាអាហារមានប្រមាណ ៦៣៧ ០០០ ក្បាល និងនាំចេញប្រមាណ ១៩ ៧០៨ ក្បាល ។ ក្រៅពីសត្វគោ និងក្របី មានជ្រូកប្រមាណ ២,៤ លានក្បាល សម្រាប់ផ្គត់ផ្គង់ទីផ្សារ និងនាំចេញបានប្រមាណ ១២ ១០២ ក្បាល ។ ក្រៅពីនេះមានការចិញ្ចឹមបក្សីសរុបប្រមាណ ២៧ លានក្បាល ។ ទោះបីជានៅកម្ពុជា អាជីវកម្មចិញ្ចឹមសត្វមានការរីកចម្រើន តែនៅមានបញ្ហាប្រឈមនឹងកង្វះខាតរោងចក្រផលិតចំណីសត្វនៅឡើយ ។កម្ពុជាទើបតែមានរោងចក្រផលិតចំណីសត្វចំនួនត្រឹមតែ ៧ កន្លែង ដែលមានសមត្ថភាពផលិតចំណីសត្វបានប្រមាណមួយលានតោនតែប៉ុណ្ណោះ ។

ម្យ៉ាងទៀតថ្វីត្បិតកម្ពុជាមានសមត្ថភាពផ្គត់ផ្គង់សាច់បានដូចខាងលើក្តី តែកម្ពុជានៅមិនទាន់អាចធានាតម្រូវការបានទាំងស្រុងនៅឡើយទេ ដោយសាច់មួយចំនួននៅតែត្រូវនាំចូលពីប្រទេសជិតខាង ជាពិសេសគឺ ថៃ វៀតណាម និងប្រទេសមួយចំនួនទៀត ដូចជាអូស្ត្រាលី និងញូវសេឡង់ជាដើម ។

**ទំនិញកម្ពុជាដែលនាំចេញទៅទីផ្សារសហភាពអឺរ៉ុប :**

សហភាពអឺរ៉ុបបានបញ្ជាក់ថា នៅក្នុងមួយឆ្នាំៗកម្ពុជានាំទំនិញធំៗចំនួន ៥ ប្រភេទចេញទៅកាន់ទីផ្សាររបស់ខ្លួន ក្នុងនោះរួមមាន សម្លៀក បំពាក់ ស្បែកជើង កង់ អង្ករ និងស្ករ ។ ទំនិញដែលកម្ពុជានាំចេញទៅកាន់ទីផ្សារនោះត្រូវបានធ្វើឡើងក្រោមលក្ខខណ្ឌ " អ្វីៗទាំងអស់លើកលែងតែអាវុធ " ។

ក្នុងឆ្នាំ ២០១៣ កន្លងទៅ ទំនិញដែលកម្ពុជានាំចេញទៅសហភាពអឺរ៉ុប គឺសម្លៀកបំពាក់មាន ៦៨,៨% ស្បែកជើង ១២,៩% កង់ ១០,៣% អង្ករ ៥,២% និងស្ករស ១៦% ។ ទំនិញដែលកម្ពុជានាំចេញទាំងអស់នេះ មានតម្លៃសរុបប្រមាណ២,៤ពាន់លានយូរ៉ូ ឬប្រមាណ ៣,៣៤ ពាន់លានដុល្លារអាមេរិក ។ ក្រសួងពាណិជ្ជកម្មកម្ពុជាក៏បានឱ្យដឹងថា ក្រៅពីទំនិញទាំង ៥ ខាងលើ កម្ពុជាបាននាំចេញផលិតផលមួយចំនួនទៀតដូចជា ម្រេច ស្ករត្នោត ជាដើម ប៉ុន្តែបរិមាណនៃការនាំចេញគឺនៅតិចតួច ។

សហភាពអឺរ៉ុបគឺជាអង្គការតំបន់មួយដែលមានសមាជិកចំនួន ២៨ ប្រទេស ដែលមានប្រជាពលរដ្ឋប្រមាណ ៥០០ លាននាក់ ។ សហភាពអឺរ៉ុបគឺជាដៃគូពាណិជ្ជកម្មនាំចេញកម្ពុជាធំទីពីរបន្ទាប់ពីអាមេរិក ។

**ពាណិជ្ជកម្មកម្ពុជា-អាស៊ាន :**

ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា ទំនាក់ទំនងពាណិជ្ជកម្មកម្ពុជាជាមួយអាស៊ាននាឆ្នាំ ២០១៣ កន្លងទៅមានទំហំទឹកប្រាក់ធំជាងជាមួយនឹងសហគមន៍អឺរ៉ុប ប៉ុន្តែខុសត្រង់ថា ទៅទីផ្សារសហភាពអឺរ៉ុប កម្ពុជានាំចេញច្រើនជាងនាំចូលតែជាមួយអាស៊ាន គឺកម្ពុជានាំចូលច្រើនជាងនាំចេញ ។ ពាណិជ្ជកម្មកម្ពុជាជាមួយនឹងបណ្តាប្រទេសនៅអាស៊ានមានតម្លៃប្រមាណ ៤,១៦ ពាន់លានដុល្លារ ។ ទំហំពាណិជ្ជកម្មនេះមានការកើនឡើងប្រមាណ ១២% បើធៀបនឹងទឹកប្រាក់ចំនួន ៣,៧១ ពាន់លានដុល្លារនាឆ្នាំ ២០១២ ។

គួរបញ្ជាក់ថា ក្នុងឆ្នាំ ២០១៣ នោះការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអាស៊ានមានតម្លៃប្រមាណ ៤៨២ លានដុល្លារ កើន ៥១% តែអាស៊ាននាំចេញមកកាន់កម្ពុជាមានតម្លៃ ៣,៦៨ ពាន់លានដុល្លារ កើន ឡើងប្រមាណ ៨% ។ អាស៊ានមានសមាជិក ១០ ប្រទេស រួមទាំងប្រទេសកម្ពុជាផង ។

**ការនាំទៅអាមេរិក-ជប៉ុន ខែមករា :**

ការិយាល័យស្ថិតិពាណិជ្ជកម្មរបស់អាមេរិកបានឱ្យដឹងថាពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា និងអាមេរិក នៅក្នុងខែមករា ឆ្នាំ២០១៤នេះ មានតម្លៃ ២៥៤,៣ លានដុល្លារ-អាមេរិក បើធៀបនឹងឆ្នាំ ២០១៣ ក្នុងរយៈពេលដូចគ្នាគឺកើនឡើង ១,២៣% ។ ខែមករា ឆ្នាំ ២០១៣ ទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរមានចំនួន ២៥១,២ លានដុល្លារ ។

នៅក្នុងរង្វង់រយៈពេលមួយខែដើមឆ្នាំនេះ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអាមេ-រិកមានតម្លៃប្រមាណ២២៩,៩លានដុល្លារ ខណៈដែលកាលពីខែមករា ឆ្នាំ២០១៣គឺមានតម្លៃ ២៣៣,១ លានដុល្លារ ពោលគឺមានការថយចុះប្រមាណ ១,៣៧% ។ ប៉ុន្តែសម្រាប់ទំនិញដែលកម្ពុជានាំចូលពីអាមេរិកវិញ នៅក្នុងខែមករានេះមានការកើនឡើង ពោលគឺមានតម្លៃ ២៤,៤ លានដុល្លារ បើធៀបនឹងខែមករា ឆ្នាំ ២០១៣ មានចំនួន ១៨,១ លាន ដុល្លារ ។ ដូចនេះឆ្នាំនេះមានការកើនឡើងប្រមាណ ៣៤,៨% ។

គួរបញ្ជាក់ថា ថ្វីត្បិតការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអាមេរិកមានការថយចុះបន្តិចមែន ប៉ុន្តែបើធៀបនឹងការនាំចេញទៅប្រទេសផ្សេងៗទៀតគឺមានការកើនឡើង ជាពិសេសគឺទីផ្សារនៅជប៉ុន ។ ស្ថិតិពីការិយាល័យនៃអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុនបានឱ្យដឹងថា ក្នុងខែមករា ឆ្នាំ ២០១៤ នេះ កម្ពុជាបាននាំចេញទៅកាន់ ទៅផ្សារជប៉ុនមានតម្លៃ ៤៩,៦ លានដុល្លារ បើធៀបនឹងរយៈពេល ដដែលឆ្នាំ ២០១៣ គឺកើនឡើងជាង ២៤% ។ ដោយឡែកទំនិញដែលកម្ពុជានាំចូលពីជប៉ុនមកវិញមានតម្លៃប្រមាណ ១២,៨ លានដុល្លារ ដោយបានថយចុះប្រមាណ ១៩,៤ លានដុល្លារ ។

ទំនិញដែលកម្ពុជានាំចេញទៅកាន់ទីផ្សារធំៗទាំងពីរនេះ គឺមានផលិតផលពីឧស្សាហកម្មកាត់ដេរខោអាវ និងស្បែកជើង និងផលិតផលកសិកម្ម ដូចជា អង្ករ ម្រេច ជាដើម ។ ដោយឡែកទំនិញដែលកម្ពុជានាំចូលពីប្រទេសទាំងពីរនេះមកវិញនោះគឺមានដូចជា គ្រឿងម៉ាស៊ីនយាន-យន្ត អេឡិចត្រូនិច និងសម្ភារៈពេទ្យជាដើម ។

**ទេសចរណ៍ខែមករា ឆ្នាំ ២០១៤ :**

ទេសចរអន្តរជាតិមកទស្សនាកម្ពុជាក្នុងខែមករា ឆ្នាំ ២០១៤ មានចំនួន ៤៤២ ០៤៥ នាក់ កើនឡើង ៩,៤% ធៀបនឹងខែមករាឆ្នាំ ២០១៣ ។ ទីផ្សារទេសចរណ៍សំខាន់ៗមកកម្ពុជាក្នុងអំឡុងពេលនេះមាន កូរ៉េ ៧៧ ១៣៧ នាក់ ,ចិន ៥១ ២០០ នាក់ , វៀតណាម ៥១ ០១៣ នាក់ ឡាវ ៣៣ ៨៤០ នាក់ , រុស្ស៊ី ២២ ៧១៣ នាក់ , អាមេរិក ២២ ៥៤៨ នាក់ ,ជប៉ុន ២០ ៦៩៩ នាក់ , អូស្ត្រាលី ១៦ ៨៩៣ នាក់,បារាំង ១៦ ១៦៨ នាក់ និងថៃ ១៥ ៩៣៦ នាក់ ។

ដោយឡែកទេសចរកម្ពុជាចេញទៅក្រៅប្រទេសក្នុងខែមករា ឆ្នាំ ២០១៤ មានចំនួន ៦៨ ៦១៨ នាក់ ថយចុះ ៤.៣% ធៀបនឹងរយៈ ពេលដូចគ្នាឆ្នាំ ២០១៣ ។

**វិស័យអប់រំ ២០១៣ :**

គិតត្រឹមឆ្នាំសិក្សា ២០១២-២០១៣ ទូទាំងប្រទេសមានសាលាមត្តេយ្យសិក្សា និងចំណេះទូទៅទាំងរដ្ឋ និងឯកជនសរុបចំនួន ១៤ ៨៥៣ កន្លែង ក្នុងនោះសាលាមត្តេយ្យសិក្សា ៥ ៨០៧ កន្លែង (មត្តេយ្យសិក្សារដ្ឋចំនួន ៣ ១៨៤ ឯកជនចំនួន ៤០៣ និងមត្តេយ្យសិក្សាសហគមន៍ចំនួន ២ ២២០) ។

កុមារអាយុ ១ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសេវាអប់រំចំនួន ១៧,៥៩% កុមារអាយុពី ៣ ដល់ ៤ ឆ្នាំ ទទួលបានសេវាអប់រំចំនួន ២០,៥% និងកុមារអាយុ ៥ ឆ្នាំទទួលបានសេវាអប់រំចំនួន ៥៩,៩% ។

សាលាបឋមសិក្សាមានចំនួន ៧ ២៣៦ និងសិស្សចំនួន ២ ០៧៣ ៨១១ នាក់ ។ អនុវិទ្យា-ល័យចំនួន ១ ២៧៩ និងសិស្សចំនួន ៥៣៨ ៦២៦ នាក់ ។ វិទ្យាល័យចំនួន ៥៣១ និងសិស្សចំនួន ២៦៦ ២៩៣ នាក់ ។ គ្រឹះស្ថានឧត្តមសិក្សាមានចំនួន ១០៥ មានទីតាំងនៅតាមរាជធានីខេត្តចំនួន ១៩ ក្នុងនោះមានគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៣៩ និងឯកជនចំនួន ៦៦ មាននិស្សិតកំពុងសិក្សាចំនួន ២៥៣ ៧៦៤ នាក់ ។/

*អគ្គិសនីគឺជាថាមពលមិនអាចខ្វះបានក្នុងការបម្រើឱ្យវិស័យសេដ្ឋកិច្ច វប្បធម៌ សង្គម និង ជីវភាពរស់នៅរបស់ប្រជាជន។ បច្ចុប្បន្ន អគ្គិសនីកម្ពុជាបានបង្ហាញឱ្យឃើញពីភាពរីកចម្រើនគួរកត់សម្គាល់ ទាំងប្រភពអគ្គិសនី បណ្តាញអគ្គិសនីជាតិ និងតម្លៃប្រើប្រាស់ នៅតំបន់ដែលបានតភ្ជាប់ជាមួយនឹងបណ្តាញជាតិ ។ តាមរបាយការណ៍របស់អាជ្ញាធរអគ្គិសនីកម្ពុជាបានបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ ២០១៣ កន្លងទៅនេះ ថាមពលអគ្គិសនីប្រើប្រាស់នៅទូទាំងប្រទេសកម្ពុជាបានកើនឡើង ២២% ពី ៣ ៥២៧ លានគីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១២ ដល់ ៤ ២៩៧ លានគីឡូវ៉ាត់ម៉ោងនៅឆ្នាំ២០១៣ ។អនុភាពប្រភពអគ្គិសនីដែលកម្ពុជាមាន បានកើនឡើងដល់ទៅ៦៦,៧០% លើសពីឆ្នាំមុនគឺពី៨២២ ម៉េហ្គាវ៉ាត់ នៅឆ្នាំ ២០១២ ឡើងដល់ ១,៣៧០ ម៉េហ្គាវ៉ាត់នៅឆ្នាំ ២០១៣ ធ្វើឱ្យប្រភពអគ្គិសនីដែលកម្ពុជាមានអាចគ្របដណ្តប់បានទាំងស្រុងលើសេចក្តីត្រូវការប្រើប្រាស់ចំពោះមុខទាំងអស់បាន ។*

# វិស័យអគ្គិសនីកម្ពុជា
## បានបង្ហាញពីភាពរីកចម្រើនយ៉ាងរឹងមាំ
## ទាំងប្រភពអគ្គិសនី បណ្តាញអគ្គិសនី
## និងតម្លៃប្រើប្រាស់



*ស្ថានីយវារីអគ្គិសនីកំចាយ ក្នុងខេត្តកំពត*

តាមរបាយការណ៍បានឱ្យដឹងទៀតថានេះគឺជាលើកទីមួយដែលក្នុងរយៈពេល ៣០ ឆ្នាំកន្លងទៅនេះ ការអភិវឌ្ឍប្រភពអគ្គិសនីរបស់រាជរដ្ឋាភិបាលបានកើនឡើងទាន់កំណើននៃសេចក្តីត្រូវការអគ្គិសនីទូទាំងប្រទេស ហើយបើតាមស្ថានភាពនៃការសាងសង់រោងចក្រអគ្គិសនីក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងវិនិយោគដែលបានចុះហត្ថលេខារួច គេរំពឹងថា ចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៧ កម្ពុជានឹងមិនមានបញ្ហាខ្វះប្រភពអគ្គិសនីទេ ។ ជាក់ស្តែងនៅដើមឆ្នាំ ២០១៤ នេះ រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំដែលធំបំផុតនៅកម្ពុជានោះបានចាប់ផ្តើមដំណើរការដោយផលិតអគ្គិសនីរាប់លានគីឡូវ៉ាត់ម៉ោងលក់ទៅឱ្យអគ្គិសនីកម្ពុជា ។

គួរបញ្ជាក់ថាគម្រោងផលិតថាមពលវារីអគ្គិសនី៣៣៨មេហ្គាវ៉ាត់របស់ក្រុមហ៊ុនចិន China Huadian Corporation ដែលមានទីតាំងស្ថិតក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង បានផលិត និងចែកចាយអគ្គិសនីមករាជធានីភ្នំពេញកាលពីខែមុន ។ រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំនេះ ជាទំនប់វារីអគ្គិសនីធំ និងល្អបំផុតដែលបានបង្កើតឡើងនៅកម្ពុជា ។ រោងចក្រវារីអគ្គិសនីនេះមានតម្លៃជិត ៥០០ លានដុល្លារអាមេរិក ដែលជាការវិនិយោគមួយក្នុងចំណោមការវិនិយោគបរទេសដ៏ធំបំផុតនៅកម្ពុជា ហើយបានបញ្ចប់ដោយជោគជ័យការសាងសង់មុនកាលកំណត់កាលពីខែធ្នូ ឆ្នាំ ២០១៣ ដោយបានលក់ថាមពលអគ្គិសនី ១៩០០លានគីឡូវ៉ាត់ម៉ោងទៅឱ្យអគ្គិសនីកម្ពុជា ។វារីអគ្គិសនីនេះគ្របដណ្តប់លើផ្ទៃដីទំហំ ៣០០០ ហ.ត ហើយមានទំនប់ធំៗចំនួនពីរ និងមាន



*បង្គោលតភ្ជាប់បណ្តាញអគ្គិសនីពីស្ថានីយវារីអគ្គិសនីគិរីរម្យ មកកាន់រាជធានីភ្នំពេញ*

ម៉ាស៊ីនដំណើរការផលិតភ្លើងចំនួនបួនដែលអាចផលិតអគ្គិសនីនៅរដូវប្រាំងបាន ព្រោះថាទំនប់ខាងក្រោមអាចស្តុកទឹកបាន ១៨០០ ម៉ឺនម៉ែត្រគូប និងទំនប់ខាងលើបាន ៤០១៨ លានម៉ែត្រគូប ។ វារីអគ្គិសនីស្ទឹងឫស្សីជ្រុំ គឺជាគម្រោងទីបួន ក្នុងចំណោមគម្រោងវារីអគ្គិសនីចំនួន ៦



បណ្តាញបញ្ជូនអគ្គិសនីនៅខេត្តព្រះសីហនុ



ស្ថានីយវារីអគ្គិសនីឫស្សីជ្រុំ ក្រោមក្នុងខេត្តកោះកុង

ដែលសាងសង់ដោយក្រុមហ៊ុនចិន ។

ឯកឧត្តម **ឆី នរិន្ទ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជាបានឱ្យដឹងថា នៅក្នុងឆ្នាំ ២០១៣ កម្ពុជាបានដាក់ឱ្យដំណើរការអនុស្ថានីយ និង បណ្តាញបញ្ជូនថ្មីពីរកន្លែងទៀត គឺអនុស្ថានីយ និងបណ្តាញតភ្ជាប់ពីភ្នំ-ពេញទៅកំពង់ចាម ។ អនុស្ថានីយ និងបណ្តាញបញ្ជូនតភ្ជាប់ពីខេត្តកំពតទៅខេត្តព្រះសីហនុ ។ បណ្តាញជាតិបច្ចុប្បន្នមានប្រវែង ១ ៣០៤ គីឡូ-ម៉ែត្រ និងអនុស្ថានីយ ១៧ កន្លែង គ្របដណ្តប់លើខេត្តក្រុងចំនួន ១៣ និងកំពុងបន្តពង្រីកបណ្តាញជាតិពីខេត្តកំពង់ចាម ទៅក្រចេះ ស្ទឹងត្រែង និងពង្រីកបន្ថែមពីភ្នំពេញទៅខេត្តព្រះសីហនុដោយផ្ទាល់មួយខ្សែទៀត ដែលសរុបមានប្រវែង ៤៣៨ គីឡូម៉ែត្រ និងអនុស្ថានីយថ្មី ៣ កន្លែងទៀត ។

នៅក្នុងឆ្នាំ ២០១៣ អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាប័ណ្ណឱ្យអ្នកចែកចាយអគ្គិសនីកម្ពុជាចំនួន ៣១៧ អាជ្ញាប័ណ្ណ ដែលត្រូវធ្វើការចែកចាយគ្របដណ្តប់លើ ១១ ២១៨ ភូមិ ស្មើនឹង ៧៩,៧១% នៃភូមិទូទាំងប្រទេស តែអ្នកកាន់អាជ្ញាប័ណ្ណទើបធ្វើការអភិវឌ្ឍបណ្តាញចែកចាយគ្របដណ្តប់លើ ៧ ១៨៧ ភូមិ ស្មើ ៥១,០៧% នៃ ១១ ២១៨ ភូមិ និងភ្ជាប់ចរន្តឱ្យប្រជាពលរដ្ឋប្រើប្រាស់បាន ១ ១២៥ ៦៧៩ កន្លែង ស្មើប្រមាណជា ២ ២៦០ ០០០ ខ្នងផ្ទះ បានន័យថា មានគេហដ្ឋានជិត ៥០% ហើយដែលបានទទួលការផ្តល់សេវាអគ្គិសនីតាមរយៈបណ្តាញដែលបានអភិវឌ្ឍ ។

ឯកឧត្តម **ឆី នរិន្ទ** បានឱ្យដឹងទៀតថា ការអភិវឌ្ឍប្រភពអគ្គិស-នី អនុស្ថានីយ បណ្តាញបញ្ជូន បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយ បានធ្វើឱ្យអ្នកចែកចាយអគ្គិសនី ២៤៩ តំបន់ ដែលមានព្រំដែនចែកចាយគ្របដណ្តប់លើ ៩ ៥៣៩ ភូមិ បានតភ្ជាប់ជាមួយប្រភពអគ្គិសនីពីបណ្តាញជាតិ ជំនួសឱ្យការប្រើម៉ាស៊ីនដៀសែល ។ ការផ្លាស់ប្តូរពីម៉ាស៊ីនដៀសែលមកប្រភពបណ្តាញជាតិ បានធ្វើឱ្យថ្លៃលក់អគ្គិសនីនៅតំបន់ទាំងនោះថយចុះពីចន្លោះ៣០០០រៀល៣៦០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង មកនៅក្នុងចន្លោះពី ១ ០៥០ ទៅ ១ ៦០០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ។

ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានមានប្រសាសន៍នៅក្នុងឱកាសសន្និបាតប្រចាំឆ្នាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាថា ពេលនេះជាឱកាសមួយផ្តល់ឱ្យអ្នកពាក់ព័ន្ធក្នុងវិស័យអគ្គិសនីអាចធ្វើការពិភាក្សាជាមួយគ្នាដើម្បីពិនិត្យមើលឡើងវិញ អំពីការផ្គត់ផ្គង់អគ្គិសនីក្នុងឆ្នាំ ២០១៣កន្លងទៅ និងរកវិធីកែលម្អឱ្យកាន់តែប្រសើរកាន់តែមានប្រសិទ្ធភាព និងកាន់តែមានសុវត្ថិភាពឡើង ព្រមទាំងរកវិធីជំរុញការអភិវឌ្ឍវិស័យអគ្គិសនីរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ឱ្យកាន់តែមានការរីកចម្រើនថែមទៀត ។ ក្នុងឱកាសនោះឯកឧត្តមរដ្ឋ-មន្ត្រីក្រសួងរ៉ែ និងថាមពលបានបញ្ជាក់ថា សម្រាប់រយៈពេល ៥ ឆ្នាំ ២០១៣ ដល់ ២០១៨ ក្រសួងបានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ចំនួន ៥ ដែលរួមមាន ១-ត្រូវរក្សាឱ្យបានតុល្យភាពនៃការផ្គត់ផ្គង់ និងតម្រូវការថាមពលអគ្គិសនី ២-ពង្រីកទំហំ និងវិសាលភាពនៃសេវាផ្គត់ផ្គង់អគ្គិសនី ៣-លើកកម្ពស់សមធម៌ក្នុងការទទួលសេវាផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ៤-ពង្រីកស្ថិរភាព និងគុណភាពនៃសេវាផ្គត់ផ្គង់អគ្គិសនី និង ៥-ជំរុញកាត់បន្ថយគម្លាតតម្លៃអគ្គិសនី ។/



បង្គោលបណ្តាញតភ្ជាប់ចរន្តអគ្គិសនីពីប្រទេសថៃតាមផ្លូវជាតិលេខ ៦ ពីខេត្តបន្ទាយមានជ័យ មកកាន់ខេត្តសៀមរាប

# ការអភិវឌ្ឍវិស័យគមនាគមន៍នៅកម្ពុជាក្រោមគម្រោងជំនួយអន្តរជាតិ

*ក្នុងការអភិវឌ្ឍវិស័យគមនាគមន៍ និងដឹកជញ្ជូននៅកម្ពុជា ក្រៅពីការប្រើប្រាស់ថវិកាជាតិ រាជរដ្ឋាភិបាលកម្ពុជាក៏បាននិងកំពុងអនុវត្តនូវគម្រោងស្តារ និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន សំខាន់ៗជាច្រើន ដោយប្រើប្រាស់ថវិកាជំនួយអន្តរជាតិ ដែលមានប្រភពមកពីប្រទេសជាមិត្តមួយចំនួនដូចជាគម្រោងជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន ជប៉ុន កូរ៉េ ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រភពពីស្ថាប័នអន្តរជាតិមួយចំនួនទៀត គម្រោងទាំងនោះមានទាំងគម្រោងកំពុងអនុវត្ត និងគម្រោងកំពុងរៀបចំនឹងអនុវត្ត ។*

*ផ្អែកតាមរបាយការណ៍របស់ក្រសួងសាធារណការ និងដឹកជញ្ជូនបានបញ្ជាក់ឱ្យដឹងថា គិតមកត្រឹមដំណាច់ខែមករាឆ្នាំ ២០១៤ នេះ ការងារស្ពាន ថ្នល់ ដែលកំពុងអនុវត្តក្រោមគម្រោងធំៗក្នុងក្របខណ្ឌជំនួយអន្តរជាតិ បានសម្រេចលទ្ធផលជាផ្លែផ្កា ដែលក្នុងនោះគម្រោងមួយចំនួនកំពុងតែអនុវត្ត និងគម្រោងមួយចំនួនទៀតកំពុងតែរៀបចំ ដើម្បីនឹងអនុវត្ត ។ លទ្ធផលមានដូចខាងក្រោម :*



*ការដ្ឋានស្ថាបនាពង្រីកកំណាត់ផ្លូវជាតិលេខ ៥ ចាប់ពីរាជធានីភ្នំពេញដល់ព្រែកក្ដាមប្រវែង ៣០,១៤៥ គ.ម*



*ការដ្ឋានស្ថាបនាពង្រីកកំណាត់ផ្លូវជាតិលេខ ៦ ប្រវែង ៤០,៤៨ គ.ម មាន ៤ គន្លងចាប់ពីគីឡូម៉ែត្រលេខ ៤ មុខក្រសួងសុខាភិបាលថ្មីដល់ថ្នល់កែង*

## ១_គម្រោងធំៗក្នុងក្របខណ្ឌជំនួយអន្តរជាតិកំពុងអនុវត្ត

### ក-គម្រោងជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន :

ផ្លូវជាតិលេខ ៥៧ បេ ប្រវែង ១៧៦,៣៥ គ.ម ពីថ្មគោល-បវេល-សំពៅលូន,បវេល-ភូមិសាមសិបភ្នំព្រឹកនិងភូមិសាមសិប-កំរៀង-សម្រេចបាន ១០០ ភាគរយ និងបានដាក់សម្ពោធក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន** កាលពីថ្ងៃទី ១០ ខែមីនា( ផ្លូវជាតិលេខ ៦២ ប្រវែង ៦,០៩ គ.មចាប់ពីជើងភ្នំប្រាសាទព្រះវិហារសម្រេចបាន៧៣,៨៧% ។ កំណាត់ផ្លូវជាតិលេខ ៦ ប្រវែង ៤០,៤៨ គ.ម មាន ៤ គន្លង ចាប់ពីគីឡូម៉ែត្រលេខ ៤ មុខក្រសួងសុខាភិបាលថ្មី-ថ្នល់កែង សម្រេចបាន ៦៥,៧២% ។ ស្ពានតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រវែង ៨៥៥ ម៉ែត្រសម្រេចបាន ៩៧,៩២% និងធ្វើពិធីចាក់បេតុងផ្ទឹម ប្រអប់ស្ពានតភ្ជាប់គ្នានៃប្រឡោះជើងទម្រនៅថ្ងៃទី ២ ខែមេសាខាងមុខ



*កំណាត់ផ្លូវជាតិលេខ ៤៤ ប្រវែង ១៣៩,៦១ គ.ម បំបែកពីផ្លូវជាតិលេខ ៤ ខេត្តកំពង់ស្ពឺ ឆ្ពោះទៅកាន់ស្រុកឧត្ដុង្គជាប់ផ្លូវជាតិលេខ ៥*



*កំណាត់ផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតឆ្ពោះទៅកាន់វាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ*



*ការដ្ឋានស្ថាបនាស្ពានជ្រោយចង្វាទី ២ រាជធានីភ្នំពេញ ប្រវែង ៧១៩ ម៉ែត្រ*



*ការដ្ឋានស្ថាបនាស្ពានមេគង្គ ខេត្តស្ទឹងត្រែងប្រវែង ១.៧៣១ ម៉ែត្រ*

ក្រោមអធិបតីភាពសម្តេចតេជោ។ ផ្លូវភ្ជាប់ស្ពានតាខ្មៅប្រវែង ១១,១ គ.ម សម្រេចបាន ៤៣,៣៥% ។ ផ្លូវជាតិលេខ ៤១ ប្រវែង ៩៥,២៨ គ.ម ចាប់ពីថ្នល់ទទឹងដល់ជុំគីរី ខេត្តកំពតសម្រេចបាន៩៧,១០% ។ស្ពានជ្រោយចង្វាទី ២ រាជធានីភ្នំពេញ ប្រវែង ៧១៩ ម៉ែត្រ សម្រេចបាន ៨៣.៩៥% និងធ្វើពិធីចាក់បេតុងផ្ទឹមប្រអប់ស្ពានតភ្ជាប់គ្នានៃប្រឡោះជើងទម្រនៅថ្ងៃទី៩ខែមេសាខាងមុខ ក្រោមអធិបតីភាពសម្តេចតេជោ។ផ្លូវជាតិ លេខ ៩ ប្រវែង ១៤១,៦៨ គ.មចាប់ពីត្បែងមានជ័យ ខេត្តព្រះវិហារ-ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង សម្រេចបាន ៩១,៥៨% ។ ស្ពានមេគង្គ ខេត្តស្ទឹង-ត្រែងប្រវែង ១.៧៣១ ម៉ែត្រ សម្រេចបាន ៩១,៩១ % ។ កំណាត់ផ្លូវជាតិលេខ ៧ បន្ត ប្រវែង ១៧១,៧៨ គ.ម ចាប់ពីសែនមនោរម្យ កោះញែក ខេត្តមណ្ឌលគីរី-លំផាត់ តាអង់ ខេត្តរតនគីរី សម្រេចបាន ៤៤,០៤% ។ ផ្លូវជាតិលេខ ៤៤ ប្រវែង ១៣៩,៦១គ.ម ចាប់ពីច្បារមន ឱរ៉ាល់ ឧត្តុង្គ ខេត្តកំពង់ស្ពឺសម្រេចបាន ៤៥,៨៥% ។ កំណាត់ផ្លូវជាតិលេខ ៥ ប្រវែង ៣០,១៤៥ គ.ម ចាប់ពីភ្នំពេញដល់ព្រែកក្តាម សម្រេចបាន ១៧,៥០% និងកំណាត់ផ្លូវជាតិលេខ ៦ ប្រវែង ២៤៨,៥២ គ.ម ថ្នល់កែង-អង្គ្រង ខេត្តសៀមរាប សម្រេចបាន ១១,៦១% ។

**ខ-គម្រោងជាជំនួយជប៉ុន :**

គម្រោងសាងសង់ស្ពានអ្នកលឿងប្រវែង ២,២២ គ.ម សម្រេចបាន ៧៣,៥០% ។ គម្រោងបង្ការគ្រោះមហន្តរាយដោយទឹកជំនន់ចាប់ផ្តើមសាងសង់ក្នុងឆ្នាំ២០១៣ គ្រោងនឹងបញ្ចប់នៅខែមករាឆ្នាំ២០១៥ រួមមាន : ការជួសជុលចាក់កៅស៊ូលើកំណាត់ផ្លូវជាតិលេខ ៥ ប្រវែង ២,២ គ.ម ផ្លូវក្នុងក្រុងប្រវែង ២,៤ គ.ម និងប្រព័ន្ធរំដោះទឹកជំនន់ប្រវែង ២,៦ គ.ម នៅខេត្តកំពង់ឆ្នាំង និងនៅលើកំណាត់ផ្លូវជាតិលេខ ១១ សាងសង់ស្ពានបេតុង ៨ កន្លែងនៅខេត្តព្រៃវែង សម្រេចបាន ៣៦,១០% ។

**គ- គម្រោងជំនួយកូរ៉េ :**

ផ្លូវជាតិលេខ ៣១ ប្រវែង ៥៤,៧៩ គ.ម ផ្លូវជាតិលេខ ៣៣ ប្រវែង ៣៦,២៧ គ.ម ផ្លូវខេត្តលេខ ១១៧ ប្រវែង ១១.២៥ គ.ម និងផ្លូវវាងទីរួមខេត្តកំពតប្រវែង ៣,៦៩ គ.ម សម្រេចបាន ៧៨,៨៧% ។ គម្រោងសាងសង់ប្រព័ន្ធលូនិងស្ថានីយចម្រោះទឹកកខ្វក់ខេត្តសៀមរាប សម្រេចបាន ៧៥% ។ ផ្លូវជាតិលេខ ៥៦ កំណាត់ទី ២ ប្រវែង ៨៤ គ.ម ពីស្វាយចេក សំរោង ខេត្តឧត្តរមានជ័យ សម្រេចបាន ៣៧,៥៨% ។

**ឃ-គម្រោងជំនួយធនាគារអភិវឌ្ឍន៍អាស៊ី ( ADB) :**

ផ្លូវជាតិលេខ ៣៣ ប្រវែង ១៥,៦ គ.ម ពីកំពង់ត្រាច ព្រែកចាក ខេត្តកំពត សម្រេចបាន ១០០% ។ សាងសង់អគារត្រួតពិនិត្យឆ្លងកាត់ព្រំដែនព្រែកចាក ខេត្តកំពតសម្រេចបាន ៦៨% ។ គម្រោងជួសជុល និងថែទាំផ្លូវជាតិលេខ ៣ ប្រវែង ៥២ គ.ម ពីកំពត-វាលរេញ ខេត្តព្រះសីហនុសម្រេចបាន ១០០% ។ ផ្លូវជាតិលេខ ៥៦ កំណាត់ទី ១ ប្រវែង ២៩ គ.ម ពីសិរី-សោភ័ណ ស្វាយចេក ខេត្តបន្ទាយមានជ័យ សម្រេចបាន ៦៤% ។





*ការដ្ឋានស្ថាបនាស្ពានអ្នកលឿងប្រវែង ២,២២ គ.ម ស្ថិតក្នុងស្រុកលើកដែក ខេត្តកណ្តាល និងក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង*



*ការដ្ឋានស្ថាបនាស្ពានតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាលប្រវែង ៨៥៥ ម៉ែត្រ*

**ង-គម្រោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់ (RAMP) ដោយថវិកា ADB, WB, AusAID, OPEC ,OFID និង KTF**

កំណាត់ផ្លូវជាតិលេខ៧ ប្រវែង៣៥ គ.ម ពីឃុំស្នួល ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ សម្រេចបាន ៩៣,៦៨% ។ ផ្លូវជាតិលេខ ១១ ប្រវែង ៩០ គ.ម ពីអ្នកលឿង ខេត្តព្រៃវែង ថ្នល់ទទឹង ខេត្តកំពង់ចាម សម្រេចបាន ៩៧,៧២% ។ កំណាត់ផ្លូវជាតិលេខ២ ប្រវែង៥១,១១ គ.ម ពីក្រុងដូនកែវ ភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ សម្រេចបាន ២៥,៧៦% ។

## ២_គម្រោងធំៗក្នុងក្របខណ្ឌជំនួយអន្តរជាតិដែលក្រសួងកំពុងរៀបចំ :

### ក-គម្រោងជំនួយសាធារណរដ្ឋប្រជាមានិតចិន :

គម្រោងសាងសង់ស្ពានកោះធំប្រវែង ៤២១ ម៉ែត្រ និងផ្លូវភ្ជាប់ស្ពានប្រវែងសរុប ៤០៩ ម៉ែត្រនឹងរៀបចំសាងសង់បន្ទាប់ពីធ្វើការដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋរួច ។

គម្រោងជួសជុលឡើងវិញកំណាត់ផ្លូវជាតិលេខ ៧ ពីខេត្តក្រចេះទៅស្ទឹងត្រែង បច្ចុប្បន្នក្រុមហ៊ុនសៀង ហៃកំពុងដំណើរការជួសជុល ។

### ខ-គម្រោងជំនួយជប៉ុន :

គម្រោងកែលម្អផ្លូវជាតិលេខ ១ ដំណាក់កាលទី ៤ ប្រវែង ៤ គ.ម ពីគល់ស្ពានព្រះមុនីវង្ស វត្តក្តីតាកុយ ខណ្ឌមានជ័យ រាជធានីភ្នំពេញ គ្រោងចាប់ផ្ដើមអនុវត្តនៅអំឡុងខែកញ្ញាឆ្នាំ២០១៤ ។គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ ៥ ប្រវែង ៤៧ គ.ម ពីបាត់ដំបងទៅដល់សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បច្ចុប្បន្នកំពុងដំណើរការជ្រើសរើសក្រុមហ៊ុនប្រឹក្សាបច្ចេកទេស ហើយគ្រោងអនុវត្តសាងសង់នៅឆ្នាំ ២០១៥ ។

គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ ៥ ប្រវែង ១៣៩ គ.ម ពីព្រែកក្តាម-ធ្លាម្អម ខេត្តពោធិ៍សាត់ បច្ចុប្បន្នបញ្ជូនឯកសារតាមនីតិវិធីនឹងគ្រោងចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលជប៉ុននៅខែមីនាឆ្នាំ ២០១៤ នេះ ហើយគ្រោងនឹងចាប់ផ្ដើមអនុវត្តសាងសង់នៅឆ្នាំ ២០១៦ ។

គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ៥ ប្រវែង១៣៣ គ.ម ពីធ្លាម្អម ទៅដល់បាត់ដំបង បច្ចុប្បន្នកំពុងសិក្សារបាយការណ៍វាយតម្លៃបឋមនឹងបញ្ចប់នៅខែវិច្ឆិកាឆ្នាំ ២០១៤ ហើយគ្រោងនឹងចាប់ផ្ដើមអនុវត្តសាងសង់



*កំណាត់ផ្លូវជាតិលេខ ៥៩ ប្រវែង ១៨៤,២៧ គ.ម បំបែកពីផ្លូវជាតិលេខ ៥ ក្រុងប៉ោយប៉ែត ភ្ជាប់ទៅផ្លូវជាតិលេខ ៥៧ ភូមិស្ទឹងកាច់ ខេត្តប៉ៃលិន*

នៅឆ្នាំ ២០១៧ ។

គម្រោងអភិវឌ្ឍន៍ចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ បច្ចុប្បន្នឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់បានទទួលគោលការណ៍ឯកភាពក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកភាពពីចៃកាជប៉ុន(JICA)ហើយ ។កំពង់ផែស្វយ័តកំពុងផ្សព្វផ្សាយលក់ឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ទាំងបួនដែលជាប់បុរេលក្ខណសម្បត្តិពីមុន ។ ចំពោះការងារជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់នាវាសណ្ដោង បច្ចុប្បន្នកំពុងរង់ចាំការសម្រេចលើការចរចាចុះកិច្ចសន្យាពីក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ ។

### គ-គម្រោងជំនួយវៀតណាម :

ការសាងសង់ស្ពានជ្រៃធំប្រវែង ៤២៨ ម៉ែត្រ (ស្រុកកោះធំ ខេត្តកណ្ដាល ប្រទេសកម្ពុជា-ឡុងប៊ិញ ខេត្តអាងយ៉ាង ប្រទេសវៀតណាម) បានបើកការដ្ឋានរួចហើយកាលពីថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ក្រោមអធិបតីភាពសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋ-មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងឯកឧត្តម**ង្វៀន តឹនយុង**នាយករដ្ឋ-មន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ បច្ចុប្បន្នក្រុមការងារបច្ចេកទេសកំពុងពិភាក្សាជាមួយទីប្រឹក្សាបច្ចេកទេស KCEC លើកិច្ចសន្យាសាងសង់ ។

### ឃ-គម្រោងជំនួយកូរ៉េ :

គម្រោងសាងសង់ផ្លូវជាតិលេខ ២១ ក្រាលកៅស៊ូ AC ប្រវែង ៦៥,៥ គ.ម បានបញ្ចប់ការសិក្សាលម្អិត និងកំពុងរៀបចំឯកសារដេញថ្លៃជ្រើស-រើសក្រុមហ៊ុនដែលគ្រោងចាប់ផ្ដើមអនុវត្តសាងសង់នៅអំឡុងខែមិថុនាឆ្នាំនេះ ។

តាមរយៈការអនុវត្តបណ្ដាគម្រោងខាងលើនេះ បានឆ្លុះបញ្ចាំងច្បាស់នូវការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចឱ្យបាននូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍មួយប្រទាក់ក្រឡានៅទូទាំងប្រទេសប្រកបដោយគុណភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច សំដៅជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពការធ្វើសមាហរណកម្មផ្ទៃក្នុងនិងសមាហរណកម្មក្នុងតំបន់ ព្រមទាំងការលើកកម្ពស់ជីវភាពរបស់ប្រជាជនទូទៅ ។/

# ឆ្នាំ ២០១៣ ការនាំចេញអង្ករបស់កម្ពុជាមានកំណើន ៨៤ %



*សកម្មភាពលើកដាក់អង្ករសម្រាប់នាំចេញទៅក្រៅប្រទេស*

តាមរបាយការណ៍របស់លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំអង្ករចេញបានបង្ហាញថានៅឆ្នាំ ២០១៣ កន្លងទៅនេះ ឧស្សាហកម្មអង្ករនៅកម្ពុជានៅតែបន្តការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលមានអត្រាកំណើនប្រចាំឆ្នាំរហូតដល់ ៨៥% ។

គិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣ កម្ពុជាបាននាំចេញអង្ករសរុប ៣៧៨ ៨៥៦ តោន គឺកើនឡើង ៨៤% ពីចំនួន ២០៥ ១៧១ តោន នៅឆ្នាំ ២០១២ ហើយក្នុងនោះការនាំចេញបីខែចុងក្រោយ នៅបន្តកើនឡើងខ្លាំងជាងខែមុនៗទៅទៀត ។

តាមការរំពឹងទុកការនាំចេញអង្កររបស់កម្ពុជានៅឆ្នាំ ២០១៤ នេះ នឹងបន្តដំណើរការល្អ ការនាំចេញអាចនឹងកើនឡើងដល់ ៦៥ ម៉ឺនតោន ។

នៅឆ្នាំ២០១៣ អង្ករកម្ពុជាបាននាំចេញទៅប្រទេសទាំងអស់ ៦៦ តាមរយៈក្រុមហ៊ុននាំចេញសរុបទាំងអស់ ៨៤ ក្រុមហ៊ុន ក្នុងនោះ ក្រុមហ៊ុនដែលបាននាំចេញអង្ករច្រើនជាងគេគឺក្រុមហ៊ុន khmer Food Co.Ltd ក្រុមហ៊ុនAmrurice Cambodia Co.Ltd និងក្រុមហ៊ុន Golden Rice Cambodia Co. Ltd ក្នុងចំណោមអង្ករ ដែលបាននាំចេញសរុប ការនាំចេញទៅទីផ្សារនៅសហគមអឺរ៉ុបមានប្រមាណ ៦០% ។

របាយការណ៍ក៏បានបង្ហាញផងដែរថា ប្រភេទអង្ករដែលនាំចេញច្រើនជាងគេ គឺប្រភេទអង្ករចម្រុះ បន្ទាប់មកគឺអង្ករផ្កាម្លិះ ហើយប្រទេសដែលកម្ពុជានាំអង្ករចូលច្រើនជាងគេបំផុតគឺប្រទេសប៉ូឡូញ បន្ទាប់មកមានប្រទេស បារាំង ម៉ាឡេស៊ី ថៃ ចិន និងអង់គ្លេស ។ ប្រទេសហ្គាបុង ហូឡង់ អាល្លឺម៉ង់ និងអេស្ប៉ាញ ស្ថិតក្នុងចំណោមប្រទេសទាំង ១០ ដែលបាននាំចូលអង្ករពីប្រទេសកម្ពុជាច្រើន ។

ចំពោះប្រភេទអង្ករដែលប្រទេសកម្ពុជាបាននាំចេញច្រើនជាងគេទៅកាន់ទីផ្សារអន្តរជាតិទាំងនោះគឺប្រភេទអង្ករចម្រុះ ដោយនាំចេញបានក្នុងបរិមាណ ១៩៤ ០០៣ តោន ចំណែកអង្ករផ្កាម្លិះជាប្រភេទអង្ករក្រអូបដ៏ល្បីឈ្មោះរបស់កម្ពុជា នោះក៏បាននាំចេញក្នុងបរិមាណដ៏ច្រើនផងដែរ គឺ ១៥៦ ៧៧០ តោន និងមានប្រភេទអង្ករផ្សេងៗទៀតក៏ត្រូវបាននាំចេញដូចជាអង្ករនាងម្លិះ អង្ករសូម៉ាលី អង្ករសែនក្រអូប ឬនាងខុន និងអង្ករ ផ្កាខ្ញីជាដើម ។

គួរកត់សម្គាល់ថា តាមការប៉ាន់ស្មានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញបានឱ្យដឹងថា នៅឆ្នាំ ២០១៣ ប្រទេសកម្ពុជានៅសល់ស្រូវចំនួនជិត ៥ លានតោន ដែលគិតជាអង្ករមានជាង ៣ លានតោន ។

ចំពោះលទ្ធផលការងារបង្កបង្កើនផលឆ្នាំ២០១៣នេះ ក្រសួងកសិកម្មបានឱ្យដឹងថាដំណាំស្រូវរដូវវស្សាមានចំនួន ២៥៦ ៧៧៦២ ហ.ត ស្មើនឹង ១០៧% លើសឆ្នាំមុន ៥៦ ០៦៨ ហ.ត ផ្ទៃដីអាចប្រមូលផលបានចំនួន ២ ៤៨៥ ៤៨៨ ហ.ត ហើយទិន្នផលជាមធ្យម ២ ៩២១ តោន ក្នុង ១ ហ.ត និងបរិមាណផលចំនួន ៧ ២៥៩ ៨២១ តោន លើសឆ្នាំមុន ១២៣ ៦៨២ តោន ។ ចំណែកឯស្រូវប្រាំងវិញ តាមការប៉ាន់ស្មានថា ផ្ទៃដីអាចប្រមូលផលមានចំនួន ៤៧១ ៦៤៧ តោន និងទិន្នផលជាមធ្យម ៤ ៤០៩ តោន ក្នុង ១ ហ.ត និងបរិមាណផលស្រូវ ២០ ៧៩៣ ៦៥៩ តោន ។ បរិមាណផលស្រូវសរុបទាំងស្រូវប្រាំង និងស្រូវវស្សានៅឆ្នាំ ២០១៣ មាន ៩ ៣៣៩ ១៩០ តោន ដោយទិន្នផលជាមធ្យម ៣ ១៥៨ តោន ក្នុង ១ ហ.ត ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានវាយតម្លៃការប៉ាន់ស្មានតុល្យភាពស្បៀងឆ្នាំ២០១៤ ដោយកាត់ចេញសម្រាប់ទុកពូជចំណីសត្វ និងបាត់បង់ដោយការប្រមូលផលចំនួន ១៣% ស្មើនឹង ១ ២១៤ ០៩៥ តោន យើងនៅសល់ស្រូវជាស្បៀងចំនួន ៨ ១២៥ ០៩៥ តោន គិតជាអង្ករ បរិមាណស្រូវជាអង្ករ (៦៤%) ស្មើនឹង ៥ ២០០ ០៦១ តោន ។ តម្រូវការអង្ករសម្រាប់ប្រជាពលរដ្ឋ ១៤ ៩៥០ ១៩៦ នាក់ ស្មើនឹង ២ ១៣៧ ៨៧៨ តោន ។ សរុបមកយើងនៅសល់អង្ករចំនួន ៣ ០៦២ ១៨៣ តោន (គិតជាស្រូវ ៤ ៧៨៤ ៦៦១ តោន) ។ ក្រសួងក៏បានបញ្ជាក់ផងដែរថា ទោះបីជានៅឆ្នាំ ២០១៣ នេះ ប្រទេសកម្ពុជាបានជួបប្រទះនឹងបញ្ហាគ្រោះទឹកជំនន់យ៉ាងណាក៏ដោយ ក៏បរិមាណផលស្រូវដែលទទួលបានគឺមានការកើនឡើងជាងឆ្នាំមុន ។

ជាមួយនឹងការវាយតម្លៃដូច្នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានសម្តែងនូវសុទិដ្ឋិនិយមថា អត្រាកំណើននៃនាំការចេញអង្កររបស់កម្ពុជាកន្លងមកនេះគឺជាសញ្ញាដ៏ល្អមួយដែលបង្ហាញថា ប្រទេសកម្ពុជាអាចសម្រេចបាននូវគោលដៅនាំចេញអង្ករដ៏សំខាន់មួយរបស់ខ្លួន ។ កម្ពុជាមានសក្តានុពលយ៉ាងច្រើនសម្រាប់ជំរុញកំណើននៃសកម្មភាពនាំចេញអង្ករ ។ ក្នុងឆ្នាំ ២០១៥ ព្រះរាជាណាចក្រកម្ពុជាអាចនឹងនាំចេញអង្ករបានមួយលានតោន ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាកំពុងតែជំរុញអនុវត្តយុទ្ធសាស្រ្តបម្រើឱ្យការនាំចេញអង្ករ ដែលមានធាតុទាំងបួនគឺ : ការបង្កើនបរិ-

មាណផលិតកម្មស្រូវ កិនស្រូវបន្ថែមទៀត ជំរុញការនាំចេញ និងការស្វែងរកទីផ្សារថ្មីៗបន្ថែមទៀតនៅលើពិភពលោក ។

ទោះបីមានសមិទ្ធផលគួរឱ្យកត់សម្គាល់បែបនេះក៏ដោយ នៅក្នុងវិស័យស្រូវអង្ករបស់កម្ពុជានៅជួបបញ្ហាប្រឈមមួយចំនួន ជាពិសេសបញ្ហាខ្វះទុនបង្វិលរបស់រោងម៉ាស៊ីនកិនស្រូវ ។ លោកឧកញ៉ា **គីម សាវុធ** ប្រធានសហព័ន្ធអ្នកនាំចេញអង្ករបានឱ្យដឹងថា ផែនការនាំចេញអង្ករឱ្យបាន ១ លានតោននៅឆ្នាំ ២០១៥ ពិបាកនឹងសម្រេចតាមគោលដៅ ។ ដោយបច្ចុប្បន្ននេះកំពុងតែប្រឈមទៅលើបញ្ហាមួយចំនួនដូចជាការដឹកជញ្ជូនស្រូវពូជ និងកម្ចីប្រាក់ពីធនាគារ ។ លោកឧកញ៉ាថា ការដឹកជញ្ជូន និងពូជស្រូវគឺយើងចង់ឱ្យក្រសួងកសិកម្មគិតពីគ្រាប់ពូជស្រូវជូនប្រជាពលរដ្ឋ ។ ឯចុងក្រោយនោះគឺការខ្ចីលុយពីធនាគារមួយចំនួនមានការប្រាក់ខ្ពស់ ។

តាមរបាយការណ៍ស្ថានភាពនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល ១ ខែដើមឆ្នាំ ២០១៤ ដែលបានចេញផ្សាយដោយលេខាធិការដ្ឋានច្រកកាលពីថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៤ ថា រាជរដ្ឋាភិបាលបាន និងកំពុងផ្តល់នូវកាលានុវត្តភាពដល់ប្រជាកសិករម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញទាំងឡាយផងដែរ ។

សម្តេចបានសម្តែងនូវការកោតសរសើរចំពោះបងប្អូនប្រជាកសិករ វិនិយោគិនក្នុងវិស័យម៉ាស៊ីនកិនស្រូវ និងនាំចេញអង្ករ និងតួអង្គដែលមានការពាក់ព័ន្ធទាំងអស់ ដែលបានចាប់ដៃគ្នាសម្រេចបាននូវលទ្ធផលដ៏ត្រចះត្រចង់ធ្វើឱ្យអង្ករខ្មែរយើងត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ តាមរយៈការឈ្នះពានរង្វាន់"អង្ករល្អបំផុតក្នុងលោក"ពីរឆ្នាំជាប់គ្នា ២០១២-២០១៣ នៅក្នុងវេទិកាអង្ករពិភពលោកនោះ ដែលការទទួលបានពានរង្វាន់ដ៏វិសេសវិសាលនេះ គឺជាមោទនភាពជាតិទាំងមូល ។

សម្តេចនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា ដើម្បីសម្រេចបានគោលដៅរបស់យើងក្នុងការនាំអង្ករចេញឱ្យបានមួយលានតោននៅឆ្នាំ ២០១៥ ខាងមុខនេះ សម្តេចបានអំពាវនាវដល់បងប្អូនប្រជាកសិករ និងតួអង្គដែលមាន





*រោងម៉ាស៊ីនកិនស្រូវ សម្រាប់នាំអង្ករសម្រាប់នាំចេញទៅក្រៅប្រទេស*

ចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករបានឱ្យដឹងថា បរិមាណអង្ករកម្ពុជាដែលបាននាំចេញទៅកាន់ទីផ្សារអន្តរជាតិមានចំនួនត្រឹមតែ ២១ ៥៣៦ តោនតែប៉ុណ្ណោះ ដោយចំនួននេះមានការធ្លាក់ចុះជាង ១៦% បើប្រៀបធៀបទៅនឹងខែមករា ឆ្នាំ ២០១៣ កន្លងទៅ ដែលមានចំនួនដល់ទៅ ២៥ ៧២៦ តោន ។

អ្នកជំនាញខាងវិស័យនាំចេញអង្ករបានអះអាងថា ការធ្លាក់ចុះនេះដោយសារតែអ្នកបញ្ជាទិញនៅអឺរ៉ុបបារម្ភពីបញ្ហាពន្ធនាំចូលពីកម្ពុជា បន្ទាប់ពីមានព័ត៌មានមួយចំនួនបានលេចឮថា ចាប់ពីឆ្នាំ ២០១៤ តទៅ ការនាំចេញរបស់កម្ពុជាទៅកាន់សហគមន៍អឺរ៉ុបត្រូវគិតពន្ធ និងហេតុផលមួយទៀតដោយសារតែតម្លៃអង្ករកម្ពុជាមានតម្លៃថ្លៃជាងអង្កររបស់ប្រទេសផ្សេងៗ ។

ដើម្បីបន្តជំរុញអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំអង្ករចេញនោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានប្រសាសន៍ក្នុងសន្និសីទកម្ពុជា-វៀតណាម លើកទី ៤ ស្តីពីសហប្រតិបត្តិការវិនិយោគ នៅវិមានសន្តិភាពការពាក់ព័ន្ធ ត្រូវរួមគ្នាខិតខំបន្ថែមទៀតជំរុញការផ្សព្វផ្សាយ ក៏ដូចជាការផលិតស្រូវ-អង្ករខ្មែរយើងឱ្យបានទាំងបរិមាណ និងគុណភាព ។ កំណើននៃការនាំចេញ និងកេរ្តិ៍ឈ្មោះដែលអង្ករយើងទទួលបានក្លាយជាគម្រូល្អសម្រាប់ការបើកផ្លូវដល់ដំណាំកសិកម្មផ្សេងទៀតដែលមានតម្រូវការខ្ពស់ ដូចជា កៅស៊ូ ដំឡូងមី ពោត សណ្តែកសៀង ស្វាយចន្ទី និងម្រេច ។ ដូច្នេះ វិស័យកសិ-ឧស្សាហកម្មដែលជាអាទិភាព រំពឹងថានឹងចាក់ឫសបន្ថែមទៀត និងឈានទៅរកការកសាងមូលដ្ឋានផលិតកម្មដ៏រឹងមាំមួយ ។

គួរបញ្ជាក់ដែរថា បច្ចុប្បន្នប្រទេសកម្ពុជាជាប្រទេសកសិកម្ម ហើយស្ទើរតែ ៨០% នៃប្រជាជនប្រកបរបរលើផ្នែកកសិកម្ម ជាពិសេសគឺផលិតកម្មស្រូវ ។ ការប្រឹងប្រែងអនុវត្តឱ្យទទួលបានលទ្ធផលខ្ពស់នូវយុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ(ឱ្យបាន ១ លានតោន នៅឆ្នាំ ២០១៥) មានអត្ថន័យយ៉ាងសំខាន់ដល់ការធានាសន្តិសុខស្បៀង បង្កើនការនាំចេញផលិតផលកសិកម្ម(ទាំងអង្ករនិងផលិតផលផ្សេងៗទៀត) និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។/



# ទំនៀមប្រពៃណីក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ

## ចុល្លសករាជ១៣៧៦ មហាសករាជ ១៩៣៦ ពុទ្ធសករាជ ២៥៥៨ គ្រឹស្តសករាជ ២០១៤ "ឆ្នាំមមីឆស័ក"

ឆ្នាំថ្មីឆ្នាំមមីនេះ សង្ក្រាន្តនឹងចូលមកនៅថ្ងៃច័ន្ទ ១៥ កើត ខែចេត្រ ត្រូវនឹងថ្ងៃទី ១៤ ខែមេសា គ.ស ២០១៤ វេលាម៉ោង ៨ និង ០៧ នាទីព្រឹក ។ ពេលនោះព្រះអាទិត្យចេញពីមីនរាសីទៅឋិតនៅឯមេសរាសីតាមផ្លូវគោវិថីគឺផ្លូវកណ្ដាលទើបមានទេវធីតាមួយព្រះអង្គ ជាមគ្គនាយិកាព្រះនាម **គោរាគៈទេវី** ជាបុត្រីទី២ នៃកបិលមហាព្រហ្មគង់នៅចាតុម្មហារាជិកាទ្រង់អម្ពរពណ៌លឿងលម្អនៅព្រះកាណ៌ ដោយសៀតផ្កាអង្គារបុស្សអភរណៈ ទ្រង់ពាក់កែវមុក្ដា ភក្សាហារ ទ្រង់សោយតេលំ( ប្រេង) ព្រះហស្ដស្ដាំទ្រង់ព្រះខ័ន្ធ ព្រះហស្ដឆ្វេងទ្រង់ឈើច្រត់ ទ្រង់គង់លើខ្នងព្យាគ្ឃ ( ខ្លា) ជាពាហនៈ ទើបនាំអស់ទេវបុត្រ ទេវធីតាទាំងមួយសែនកោដិហោះទៅកាន់គុហា កែវធម្មមាលីនាទីភ្នំកៃលាស ខេត្តហិមពាន្ដ ជាទីតម្កល់ទុកនូវព្រះសិរសាកបិលមហាព្រហ្ម ដែលតម្កល់លើពានមាសនាំមកដង្ហែប្រទក្សិណភ្នំព្រះសុមេរុរាជតាមផ្លូវព្រះអាទិត្យចរចំនួន ៦០ នាទី ទើបនាំយកទៅតម្កល់ទុកនៅកន្លែងដើមវិញ ។

## ឆ្នាំមមី សត្វសេះ

លោកអ្នកដែលកើតឆ្នាំមមីពង្សទេវតាស្រីនាមជាសត្វសេះធាតុភ្លើង ទន្សាកំណើតនៅថ្ងៃសៅរ៍ សិរីធ្លាក់មកពីដៃស្ដាំរបស់ព្រហ្មមូលព្រលឹងនៅនឹងដើមចេក ។ កាលណាទៅរស់នៅទីណា កន្លែងណាឱ្យយករំសេវ ឬដីខ្សាច់ ទៅដាក់ពូនគល់ចេក ត្រូវរកដើមចេកមកដាំខាងជើង និងខាងលិចផ្ទះដែលខ្លួនរស់នៅ ទើបនឹងមានសិរីមង្គលរស់នៅត្រជាក់ត្រជុំជាសុខសាន្ត ។

មនុស្សណាដែលកើតឆ្នាំនេះ រមែងជាមនុស្សមានឬកពារក្រអឺតក្រទម ប៉ុន្តែសន្ដាន ចិត្តល្អ ជាទីពឹងពាក់ពំនាក់អាស្រ័យនៃញាតិ មិត្តទាំងឡាយបាន ។ ពាក្យសំដីនិយាយច្រើនគ្រោតគ្រាតមិនសូវទន់ភ្លន់ សត្រូវកើតបានដោយសារសំដីរបស់ខ្លួន តែជាមនុស្សមានវាសនាខ្ពស់មិនអាចអ្នកណាប៉ុនប៉ងពាធាបានឡើយ ។

មនុស្សឆ្នាំមមី កាលពីនៅតូចច្រើនលំបាកវេទនា លុះទៅដល់វ័យចំណាស់ច្រើននឹងក្លាយជាអ្នកមានស្ដុកស្ដម្ភ ពីព្រោះជាមនុស្សមានសតិបញ្ញាឈ្លាសវៃ ប៉ិនប្រសប់ក្នុងការរកស៊ី និងយល់នូវជម្រៅល្បិចកលរបស់មនុស្សទាំងឡាយ ។ មានចំណូលចិត្តខាងភ្លេងភ្លាត់ និងល្បែងផ្សេងៗ ។ បើផ្លាស់លំនៅទៅទីដទៃនឹងល្អប្រសើរជាងនៅក្នុងទីកន្លែងកំណើត ។

ចំពោះមុខរបរដែលស័ក្តិសមនឹងមនុស្សដែលកើតឆ្នាំនេះគឺជាគ្រូពេទ្យ អ្នកវិទ្យាសាស្ត្រ មេធាវី និង

មហាសង្ក្រាន្តឆ្នាំថ្មី ចុល្លសករាជ ១៣៧៦ មហាសករាជ ១៩៣៦ ពុទ្ធសករាជ ២៥៥៨ គ្រឹស្តសករាជ ២០១៤ "ឆ្នាំមមីឆស័ក"



ជំនួញជួញដូរ ។ បើប្រកបការងារដោយកម្លាំងកាយដូចជាធ្វើស្រែចម្ការ និងបានផលតឹងតែង ។

### ចំណុចព្យាករណ៍រ័យលោកអ្នកដែលកើតឆ្នាំមមី

បើជាបុរសអាយុ : ៩-១៤-២១-២៦-៣៣-៣៨-៤៥-៥០-៥៧-៦២-៦៩-៧៤-៨១ ឆ្នាំ

បើជាស្ត្រីអាយុ : ១៤-១៩-២៦-៣១-៣៨-៤៣-៥០-៥៥-៦២-៦៧-៧៤-៧៦-៧៩ ឆ្នាំ

### ទំនាយថា

ជាឆ្នាំនាំមកនូវជោគលាភសក្ការៈ គិតប្រកបការងារអ្វីតែងបានសម្រេចដូចសេចក្ដីប្រាថ្នា លាភសក្ការៈនោះដូចជា :

-ជោគលាភ : នឹងបានទ្រព្យសម្បត្តិ លុយ កាក់ មាស ប្រាក់វត្ថុមានតម្លៃគ្រឿងប្រដាប់លម្អគេហដ្ឋានឡើងប្រាក់បំណាច់ និងរង្វាន់ផ្សេងទៀត ។

-កិត្តិយស : ការសិក្សានឹងបានប្រឡងជាប់ បើទំនេរនឹងបានការងារធ្វើ បើមានការងារធ្វើស្រាប់ហើយនឹងបានឡើងតំណែងខ្ពស់

-កេរ្តិ៍ឈ្មោះ : នឹងបានទទួលសេចក្ដីគោរពរាប់អានលើកតម្កើងមុខមាត់ពីមជ្ឈដ្ឋានមនុស្សរួមការងារ និងញាតិមិត្តសាច់សន្ដាន ។

-សេចក្ដីសុខ : នឹងបានជួបប្រទះស្នេហាបរិសុទ្ធ បើអ្នកមានគូគ្រងហើយ និងមានបុត្រជាទីពេញចិត្ត សេចក្ដីសុខនឹងមានទ្វេឡើង ។

រីឯបុរសណាដែលអាយុ ១០-១៣-២២-២៥-៣៥-៣៧-៤៦-៤៩-៥៨-៦១-៧៣-៨២ ឆ្នាំ

បើជាស្ត្រីអាយុ ៩-១២-២១-២៤-៣៣-៣៦-៤៥-៤៨-៥៧-៦០-៦៩-៧២ឆ្នាំ

### ទំនាយថា

ជាឆ្នាំនាំមកនូវគ្រោះកាច គួរប្រុងប្រយ័ត្នខ្លួនក្នុងករណីដូចជា :

-នឹងជួបប្រទះទុក្ខសោកខូចចិត្តដោយពួកពាលប៉ុនប៉ងព្យាបាទ គួរកុំធ្វើដំណើរទៅទីស្ងាត់ក្នុងពេលរាត្រី អាចនឹងមានចោរខ្ជួញគំរាមកំហែងដល់អាយុជីវិត ។

-មានរោគាបៀតបៀនកាយ សត្វអសិរ្ពឹសទិច ឬខាំបណ្ដាលឱ្យបាត់បង់នូវសេចក្ដីសុខ ។

-ប្រាក់កាសត្រូវចំណាយច្រើនទាំងក្នុងផ្លូវចាំបាច់ និងមិនចាំបាច់គឺជាឆ្នាំដែលចុះដើមទុនច្រើន បើរកស៊ីជួញដូរនឹងអាចបង់ខាតដើម ។

-សង្ឃឹមទៅលើផលប្រយោជន៍ច្រើនតែខុសភ្លាំងភ្លាត់ប្រាក់ចំណូលបានតិច តែប្រាក់ចំណាយច្រើន ។

-បងប្អូនដែលធ្លាប់ស្រឡាញ់អាចនឹងមានថ្នាំងថ្នាក់រហូតក្លាយជាសត្រូវ ។

-កន្លែងធ្វើការអាចនឹងផ្លាស់ប្ដូរទៅឆ្ងាយ បើមិនដូច្នេះក៏គង់មានអ្នកនៅផ្ទះចាកចេញឆ្ងាយពីផ្ទះ ។

-ទទួលរងការរិះគន់និងមានការយ៉ាប់យ៉ឺនកម្លាំងកាយនិងចិត្តត្រូវខំស៊ូទ្រាំអំណត់អត់ធន់ពេញមួយ ឆ្នាំ ។

-ធ្វើការងារជាមួយអ្នកដទៃមានគេឆបោក កន្លែងធ្លាប់រស់នៅសុខអាចក្លាយជាក្ដៅក្រហាយរស់នៅមិនបាន ឬក៏អាចមានគេបង្ខំចិត្តឬបណ្ដេញចេញទាំងគ្មានកំហុស ។

នេះជាជំនឿទៅតាមខែឆ្នាំដែលក្លាយជាទំនៀមប្រពៃណីបន្តតាំងពីសម័យបុរាណបន្សល់ជាក្បួនតម្រារហូតមកដល់សម័យបច្ចុប្បន្ននេះ ។/

# ប្រព័ន្ធ Online ថ្មីតាមដានអំពីការបាត់បង់ព្រៃឈើ "ក្នុងពេលវេលាពិតប្រាកដ"



*ប្រព័ន្ធ Online ត្រូវបានដាក់ឱ្យដំណើរការដែលអាចផ្ដល់នូវព័ត៌មានអំពី "ពេលវេលាពិតៗ"នៃការបំផ្លាញព្រៃឈើនៅជុំវិញពិភពលោក*

ប្រព័ន្ធត្រួតពិនិត្យថ្មីនៅលើផែនដីត្រូវបានដាក់ឱ្យដំណើរការដែលអាចផ្ដល់នូវព័ត៌មានអំពី "ពេលវេលាពិតៗ"នៃការបំផ្លាញព្រៃឈើនៅជុំវិញពិភពលោកយើងនេះ។ អង្គការឃ្លាំមើលព្រៃឈើពិភពលោក (GFW) ទទួលបានការគាំទ្រពីក្រុមហ៊ុន Google និងក្រុមយុទ្ធនាការរួមជាមួយក្រុមធុរកិច្ចជាង ៤០ទៀត។

អង្គការGFW នេះបានប្រើប្រាស់ពិត៌មានចេញពីផ្កាយរណបរាប់លានរូបភាព ក៏ដូចទិន្នន័យបានមកពី ប្រជាជននៅលើផែនដី ។ ក្រុមធុរកិច្ចបានស្វាគមន៍ចំពោះទិន្នន័យថ្មីនេះដែលអាចឱ្យពួកគេបង្ហាញឱ្យឃើញថា ផលិតផលរបស់ពួកគេមានចីរភាព។

ទោះបីមានការយល់ដឹងយ៉ាងទូលំទូលាយនៅជុំវិញពិភពលោកក៏ដោយ ក៏ឥទ្ធិពលនៃការបំផ្លាញព្រៃឈើ ទំហំនៃការបាត់បង់ព្រៃឈើចាប់តាំងពីឆ្នាំ ២០០០ រហូតមកមានទំហំធំនៅឡើយ ហើយទិន្នន័យពីGoogle និង ពីសាកលវិទ្យាល័យ Maryland បានបង្ហាញថា ពិភពលោកបានបាត់បង់ព្រៃឈើ ២៣០ លាន ហ.ត ចន្លោះពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១២។

បញ្ហាដ៏ធំមួយដែលជាប់ពាក់ព័ន្ធទៅនឹងការបាត់បង់ព្រៃឈើគឺកង្វះព័ត៌មានជាក់លាក់។ នៅក្នុងរយៈពេលដូចគ្នា ដើមឈើយ៉ាងច្រើនត្រូវបានកាប់បំផ្លាញក្នុងរង្វង់ ៨០០ ០០០ គីឡូម៉ែត្រការ៉េនៃដើមឈើថ្មីៗដែលបានដាំឡើងវិញ ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានវិទ្យាស្ថានប្រភពធនធានពិភពលោកដែលមានមូលដ្ឋាននៅអាមេរិក(WRI) បានដឹកនាំដំណើរការនៃ GFW ដោយប្រើប្រាស់រូបភាពវិភាគប្រមាណ ៥០០ លាន ពីកម្មវិធី Landsat របស់អង្គការណាសា ។

ប្រព័ន្ធវិភាគព័ត៌មាន ត្រូវបានប្រើប្រាស់ដើម្បីគណនាភាពស្មុគ ស្មាញនៃថាមពល Google Earth Engine, Google Maps Engine និងប្រព័ន្ធគណនាថ្មីដែលបង្កើតឡើងដោយសាកលវិទ្យាល័យ Maryland ។

រូបភាពស្ដីអំពីការបាត់បង់ព្រៃឈើ និងការដាំដើមឈើឡើងវិញ ត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំអំពីទិន្នន័យព្រៃឈើត្រូពិក។ អង្គការឃ្លាំមើលព្រៃឈើពិភពលោកកំពុងធ្វើការត្រួតពិនិត្យពេលវេលាពិតប្រាកដ ដែលវានឹងធ្វើឱ្យមានការផ្លាស់ប្ដូរជាមូលដ្ឋាននូវឥរិយាបថ និងការប្រព្រឹត្តរបស់ប្រជាជន រួមទាំងការគ្រប់គ្រងព្រៃឈើផងដែរ។ នេះជាប្រសាសន៍របស់លោកបណ្ឌិត Andrew Steer មកពីវិទ្យាស្ថានប្រភពធនធានពិភពលោក WRI ។

លោកបណ្ឌិតបានបន្តទៀតថា "ចាប់ពីពេលនេះទៅ មនុស្សអាក្រក់មិនអាចលាក់ខ្លួនបានឡើយ ហើយមនុស្សល្អនឹងត្រូវបានទទួលស្គាល់ចំពោះការគ្រប់គ្រង និងថែរក្សាព្រៃឈើ "។ បច្ចេកវិទ្យា GFW នឹងអនុញ្ញាតឱ្យអ្នកធ្វើយុទ្ធនាការ និងសហគមន៍ក្នុងស្រុកអាចដកយកព័ត៌មានទាំងនោះបានរួមមាន ទាំងប្រភព និងវីដេអូ ស្ដីអំពីតំបន់ព្រៃឈើដែលងាយរងគ្រោះនៅជុំវិញពិភពលោក។

បច្ចេកវិទ្យានោះត្រូវបានគេនិយាយថា វាមានភាពងាយស្រួលដើម្បីប្រើប្រាស់ និងបញ្ចូលព័ត៌មានដែលបង្ហាញអំពីតំបន់ព្រៃឈើត្រូវការពារការកាប់ព្រៃឈើ ការជីកយករ៉ែ និងដីសម្បទានដាំដូងប្រេង ព្រមទាំងព័ត៌មានអំពីភ្លើងឆេះព្រៃដែលត្រូវបានប្រាប់ឱ្យដឹងពីកម្មវិធីរបស់អង្គការណាសា ។ ព័ត៌មានទាំងនោះមានគោលបំណងតម្រង់ឆ្ពោះទៅរកអ្នកនយោបាយ អ្នកធ្វើសេចក្ដីសម្រេចចិត្ត និងក្រុមអន្ដោគ្រាមជាដើម។

នៅក្នុងប្រទេសប្រេស៊ីល ប្រជាជនជាតិ Paiter Surui បានប្រើប្រាស់រួចមកហើយទូរស័ព្ទ Smart Phones និង GPS Software ដើម្បីត្រួតពិនិត្យ ការកាប់ឈើខុសច្បាប់។

សម្រាប់រដ្ឋាភិបាលនៅក្នុងប្រទេសមួយចំនួនដូចជា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ និងឥណ្ឌូនេស៊ីជាដើម បច្ចេកវិទ្យានេះអាចប្រើប្រាស់ដើម្បីជួយនៅក្នុងការអនុវត្តច្បាប់ស្ដីពីព្រៃឈើដែលតែងតែត្រូវបានរំលោភបំពាន ។

នៅពេលព្រៃឈើដែលបាត់បង់ត្រូវបានរកឃើញប្រព័ន្ធប្រាប់ឱ្យដឹងជាមុននេះត្រូវបញ្ជូនព័ត៌មានទៅកាន់បណ្ដាញជាដៃគូទៅកាន់ប្រជាជននៅជុំវិញពិភពលោកដែលអាចធ្វើសកម្មភាពបាន ។ GFW ក៏បានទទួលការគាំទ្រពីក្រុមហ៊ុនធំៗ រួមមាន Nestle និង Unilever ។

ក្រុមហ៊ុនផ្គត់ផ្គង់មួយចំនួន ដូចជា ក្រុមហ៊ុនចម្ការដូងប្រេង ចម្ការសណ្ដែកសៀង និងផលិតផលកៅស៊ូ អាចប្រើប្រាស់ប្រព័ន្ធទិន្នន័យប្រព័ន្ធ Online នេះដើម្បីបង្ហាញថា ផលិតផលរបស់ពួកគេចេញពីប្រភពស្របច្បាប់ និងមានអាជ្ញាប័ណ្ណ។

លោក Paul Polman មកពីក្រុមហ៊ុន Unilever បាននិយាយថា "ការកាប់បំផ្លាញព្រៃឈើបង្កឱ្យមានគ្រោះថ្នាក់ចំពោះធុរកិច្ចដែលពឹងផ្អែកជាមួយព្រៃឈើ។ គ្រោះថ្នាក់នេះមានសក្ដានុពលខ្លាំងចំពោះអនាគតនៃធុរកិច្ច។ ប្រព័ន្ធ Online នេះមិនគ្រាន់តែអនុញ្ញាតឱ្យអ្នកធ្វើយុទ្ធនាការកាន់កាប់សាជីវកម្មធំៗដើម្បីទទួលបាននូវផលិតផលប្រកបដោយចីរភាពប៉ុណ្ណោះទេ ប៉ុន្តែក៏នៅអាចជួយបង្កើនជំនឿទុកចិត្តរវាងក្រុមហ៊ុននឹងក្រុមហ៊ុន ដែលនៅមន្ទិលសង្ស័យគ្នាផងដែរ" ។/

# ផ្លែខ្នុរជួយបញ្ចុះសម្ពាធឈាម និងថែរក្សាស្បែក



អ្នកលក់ផ្លែខ្នុរនៅក្នុងផ្សារ

ផ្លែខ្នុរគឺជាផ្លែឈើដែលមានក្លិនក្រអូប និងមានដើមកំណើតចេញពីភាគខាងលិចនិងខាងត្បូងប្រទេសឥណ្ឌា បង់ក្លាដេស ហ្វីលីពីន និងស្រីលង្កា។ កម្ពុជាយើងក៏សម្បូរខ្នុរដែរ។ មនុស្សជាច្រើននិយមបរិភោគផ្លែខ្នុរ ដោយសារតែរសជាតិដ៏ឆ្ងាញ់របស់វា ប៉ុន្តែមានមនុស្សតិចតួចណាស់ដែលបានយល់ដឹងអំពីប្រយោជន៍នៃផ្លែខ្នុរចំពោះសុខភាពរបស់យើង។

ផ្លែខ្នុរផ្ទុកទៅដោយវីតាមីន A .C Thiamin . Riboflavin កាល់ស្យូម , ប៉ូតាស្យូម,ជាតិដែក , សូដ្យូម,ស័ង្កសីនិងNiacin ។ប្រយោជន៍មួយផ្សេងទៀតសម្រាប់មនុស្ស គឺថាខ្នុរមានកាឡូរីទាប (ផ្លែខ្នុរ ១00 ក្រាម មានតែ ៩៤ កាឡូរី) ទេ។

ផ្លែខ្នុរសម្បូរទៅដោយជាតិប៉ូតាស្យូមរហូតដល់ ៣0៣ មីលីក្រាមក្នុងចំនួនផ្លែខ្នុរ ១00 ក្រាម ។ ការសិក្សាបានឱ្យដឹងថា អាហារដែលសម្បូរទៅដោយជាតិប៉ូតាស្យូមអាចជួយបញ្ចុះសម្ពាធឈាមបាន ។ ដូច្នេះហើយ ផ្លែខ្នុរមានប្រយោជន៍ក្នុងការបំបាត់បញ្ហាលើអ្នកដែលមានជំងឺលើសសម្ពាធឈាម។



ផ្លែខ្នុរជាទីចូលចិត្តពិសានៃជនគ្រប់រូប

ផ្លែខ្នុរផ្ទុកទៅដោយសារធាតុ Phytonutri-ents : Lignans. Isoflavones និង Saponins ដែលមានប្រយោជន៍ចំពោះសុខភាពយ៉ាងធំធេង។ សារធាតុ Phytonutrients មានសមាសធាតុជាថ្នាំប្រឆាំងនឹងជំងឺមហារីក ប្រឆាំងនឹងជំងឺលើសសម្ពាធឈាម ប្រឆាំងនឹងការមានដំបៅ និងប្រឆាំងនឹងការចាស់ទៅតាមអាយុ។ ដូច្នេះហើយវាពិតជាអាចជួយការពារកោសិកាមហារីកកុំឱ្យកើតមានក្នុងខ្លួន បន្ថយសម្ពាធឈាម ប្រឆាំងនឹងបញ្ហាដំបៅក្រពះ និងបន្ថយការងាប់របស់កោសិកា ដែលធ្វើឱ្យស្បែកមើលទៅនៅក្មេង។

# ផ្លែទទឹមផ្ដល់ប្រយោជន៍អ្វីខ្លះដល់សុខភាព





ផ្លែទទឹមផ្ដល់ប្រយោជន៍
ដល់សុខភាពមនុស្សគ្រប់វ័យ

*ដើមទទឹមគឺជាប្រភេទរុក្ខជាតិម្យ៉ាងបែកមែកច្រើននិងមានដុះជាបន្លាផង រីឯស្លឹកវាដុះឆ្លាស់គ្នាខ្លះទៀតដុះសឹងទល់ទងទាំងអស់។ ចំណែកផ្កាទទឹមមានពណ៌ក្រហមស្រស់ មានដុះតែមួយ ឬបែកជាខ្នែងដុះចេញពីចន្លោះស្លឹកទាំងសង្ខាង។ ផ្លែទទឹមមានសំបកក្រាស់រឹង មាន៨ក្លែប គ្រាប់ទទឹមមានច្រើនគ្រាប់រាងមូលដូចពងក្រពើ ខ្លះទៀតមានរាងជ្រុងដូចគ្រាប់ពោជ្រ។ ដើមទទឹមគេសង្កេតឃើញមានដាំដុះនៅពាសពេញបណ្ដាប្រទេសនៅតំបន់ឥណ្ឌូចិនក្នុងលក្ខណៈដាំជាចម្ការ ឬលម្អផ្ទះ។ ផ្លែទទឹមមានប្រភពដើមមកពីប្រទេសអាហ្វហ្គានីស្ថាន ប៉ាគីស្ថាន ឥណ្ឌា និងអ៊ីរ៉ង់។ ផ្លែទទឹមសម្បូរទៅដោយវីតាមីន C និង B ៥ ប៉ូលីផេណុលប៉ូតា-ស្យូម និងសារធាតុចិញ្ចឹមរាងកាយផ្សេងៗទៀត ហើយគេប្រើវាដើម្បីព្យាបាលជំងឺផ្សេងៗ ដូចជាសម្ពាធឈាមឡើងខ្ពស់ និងជំងឺតម្រងនោមជាដើម។ ចំណែកសមាសភាពជាតិគីមីនៅក្នុងសំបកដើមមែកទទឹម គេស្រាវជ្រាវរកឃើញមានជាតិតាណាំង TANNIN និងជាតិអាល់កាឡូអ៊ីត ALCA-LOIDES ៤ យ៉ាង គឺប៉ែលលើថេរីន PELLE TIER INE អ៊ីសូប៉ែលលើថេរីន ISOPELLETI ERINE ម៉េទីលប៉ែលលើថេរីន METHYLPEL LETIER INE និងជាតិបឺសដូប៉ែលលើថេរីន PS EUDOPE LLETIERINE ។ អត្រាជាតិគីមីទាំងនេះមានតិចឬច្រើនទៅតាមរបៀបយកផល និងវិធីថែរក្សាគ្រប់គ្រង។ ក្រុមអ្នកស្រាវជ្រាវរកឃើញថាជាតិប៉ែលលើថេរីន PELLETIERINE មានឥទ្ធិពលសម្លាប់តេនញ៉ាTENIA និងពពួកព្រូនឈ្មោះ អង់គីឡូស្តូមANKYLOSTOME ។ក្រុមអ្នកស្រាវជ្រាវរកឃើញទៀតថា ការហូបផ្លែ ទទឹមអាចជួយព្យាបាលស្បែកដែលរងការខូចពីកម្ដៅព្រះអាទិត្យ ជួយទប់ស្កាត់ភាពចាស់ជរានៃស្បែក និងកាត់បន្ថយស្លាកស្នាមផ្សេងៗលើស្បែក ។ការសិក្សាស្រាវជ្រាវជាច្រើនទៀតបានបង្ហាញថា ប្រេងគ្រាប់ទទឹមអាចជួយព្យាបាលស្បែកដែលមានស្លាកស្នាមមុត របួសស្នាមផ្សេងៗយ៉ាងមានប្រសិទ្ធភាព។ ម្យ៉ាងទៀតមុខកើតមុនដោយសារអតុល្យភាពនៃអរម៉ូន និងបញ្ហារំលាយអាហារ គេអាចជួយទប់ស្កាត់ និងព្យាបាលការកើតមុន និងសម្លាប់បូសគល់ដែលធ្វើឱ្យកើតមុនដោយទទួលទានផ្លែទទឹមជាប្រចាំ ។ សារជាតិក្នុងផ្លែទទឹមវាអាចចូលទៅជួយកែសម្រួលបញ្ហាប្រព័ន្ធរំលាយអាហារ និងសម្រួលដំណើរឈាមរត់បានល្អ ។/*

# ប្រជាជនស្រុកជលគិរី តាំងចិត្តរក្សាមហិច្ឆតានៃការអភិវឌ្ឍ

*ការអភិវឌ្ឍន៍ទាមទារការបោះជំហានទៅមុខដោយ សន្សឹមៗ ។ មួយជំហានម្តងៗនឹងឆ្ពោះទៅដល់គោលដៅចុងក្រោយយ៉ាងពិតប្រាកដ ។ និយាយពីការអភិវឌ្ឍន៍គឺមិនមែនប្រដូចបានទៅនឹងការយល់សប្តិបានទេ ប៉ុន្តែគឺមានគោលការណ៍ មានផែនការជាដំណាក់ៗច្បាស់លាស់ណាស់ ។ ស្រុកជនគិរីកំពុងស្ថិតក្នុងស្ថានភាពនេះ ។ ដំណើរការអភិវឌ្ឍរបស់ស្រុកនេះចាប់ផ្តើមចេញពីបាតដៃទទេ ក្រោយឆ្នាំ ១៩៧៩ ប៉ុន្តែជាង ៣៥ ឆ្នាំ ក្រោយមក មានសមិទ្ធផលលេចធ្លោរជាច្រើនដែលយើងបានឃើញច្បាស់ផ្ទាល់ភ្នែក ។ អភិវឌ្ឍមិនមែនជាការយល់សប្តិ ប៉ុន្តែកាលពី ៣៥ ឆ្នាំមុន អ្នកស្រុកជលគិរីសូម្បីតែយល់សប្តិក៏មិនអាចនឹកឃើញថាខ្លួនកសាងបាននូវសមិទ្ធផលដ៏ច្រើនបែបនេះដែរ ។ មែនហើយ មហិច្ឆតានៃការអភិវឌ្ឍរបស់ប្រជាជននៅស្រុកជលគិរីមិនបានបញ្ចប់ត្រឹមនេះទេ ប៉ុន្តែត្រូវធ្វើដំណើរទៅមុខទៀតក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា ។*



ទិដ្ឋភាពទីរួមស្រុកជលគិរី ខេត្តកំពង់ឆ្នាំង



ភោគផលស្រូវរបស់ប្រជាកសិករស្រុកជលគិរី ខេត្តកំពង់ឆ្នាំង

យើងក្រឡេកមើលទៅអតីតរបស់ស្រុកជលគិរី ហើយប្រៀបធៀបមកនឹងអ្វីដែលមានក្នុងពេលបច្ចុប្បន្ន ទើបយើងដឹងថា តើមានអ្វីថ្មីបានកើតឡើងនៅក្នុងស្រុកមួយនេះ។ ស្រុកជលគិរីជាស្រុកមួយបង្កើតឡើងក្នុងជំនាន់អតីតសាធារណរដ្ឋប្រជាមានិតកម្ពុជានាឆ្នាំ ១៩៨៨ ហើយទីរួមស្រុកស្ថិតនៅប៉ែកខាងកើតនៃទីរួមខេត្តកំពង់ឆ្នាំង ដែលមានចម្ងាយប្រមាណ ៤៨ គីឡូម៉ែត្រ។ ស្រុកនេះស្ថិតនៅក្នុងភូមិសាស្ត្រឃុំព្រៃគ្រីដែលបំបែកចេញពីស្រុកកំពង់លែង ជាប់ព្រំប្រទល់ស្រុកបាធាយ ខេត្តកំពង់ចាម និងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ជលគិរីជាស្រុកដែលមានលក្ខណៈភូមិសាស្ត្រពិសេស ហើយក៏បង្ហាញនូវទេសភាពដ៏ស្រស់ត្រកាលរបស់ខ្លួនទៅតាមរដូវកាល គឺរដូវវស្សាហ៊ុមព័ទ្ធដោយទឹក និងរដូវប្រាំងឃើញតែព្រៃលិចទឹកខៀវស្រងាត់នៅតាមភូមិសាស្ត្រជាច្រើនក្នុងស្រុកនេះ។ស្រុកជលគិរីមានឃុំ៥ស្ថិតនៅតាមដងទន្លេ និងដៃទន្លេសាប ហើយមានប្រជាជន ៨០% ប្រកបរបររកស៊ីនេសាទ។ស្រុកនេះប្រៀបបានទៅនឹងកោះមួយនៅក្នុងរដូវវស្សា ព្រោះទឹកហ៊ុមព័ទ្ធជុំវិញ។ ស្ថានភាពភូមិសាស្ត្រស្រុកសណ្តូកតាមដងទន្លេមានទទឹងប្រវែង ៧០០ ម៉ែត្រ និងបណ្តោយប្រមាណ ២០០០ ម៉ែត្រ។ ប្រជាជនរស់នៅតាមជើងភ្នំ ជ្រលងភ្នំ និងចង្កេះភ្នំដែលស្ថិតនៅក្នុងប្រជុំភ្នំចំនួន ១១ ។ បើយើងនិយាយឬបានស្គាល់ពីភូមិសាស្ត្ររបស់ស្រុកនេះ ហើយយើងក៏ត្រូវតែគិតទៅដល់ពីភាពលំបាកសម្រាប់ជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសគឺបញ្ហាផ្លូវគមនាគមន៍នេះតែម្តង។ រដូវវស្សាទឹកឡើងត្រូវធ្វើដំណើរតាមទូក រដូវប្រាំងផ្លូវដែលត្រូវលិចលង់រៀងរាល់រដូវវស្សាក៏ខូចខាត។ ប៉ុន្តែទម្លាប់រស់នៅជាក់ស្តែងសម្រាប់ប្រជាជននៅស្រុកជលគិរីវាហាក់ដូចជាធម្មតា។ លើសពីនេះទៅទៀត ដោយសារការអភិវឌ្ឍផ្លូវគមនាគមន៍តាមភូមិ ឃុំ ដែលមិនលិចទឹក បានបង្កលក្ខណៈងាយស្រួលកាន់តែច្រើនឡើង។គួររំឭកថា កាលពីអតីតកាលប្រជាជននៅតំបន់នេះត្រូវធ្វើដំណើរតាមផ្លូវទឹកតែមួយគត់ឆ្ពោះទៅទីរួមខេត្ត ឬពីខេត្តមកស្រុកដោយត្រូវចំណាយពេលមួយថ្ងៃទល់ល្ងាច។ សូម្បីតែការធ្វើដំណើរពីភូមិមួយទៅភូមិមួយ ពីឃុំមួយទៅឃុំមួយក៏សែនលំបាកណាស់ទៅហើយ ។ ខែវស្សាធ្វើដំណើរតាមទូកកាត់លើផ្ទៃទឹកដ៏ធំល្វឹងល្វើយដូចកូនសមុទ្រ ឯខែប្រាំងក៏ធ្វើដំណើរតាមទូកកាត់ព្រែកកាត់អូរកន្លែងណារាក់ត្រូវចុះរុញ ចំណាយពេលវេលាធ្វើដំណើររាប់ម៉ោងរាប់ថ្ងៃ។ នេះជាការលំបាក។ការដឹកជញ្ជូនអ្នកជំងឺទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តក៏លំបាក ទំនាក់ទំនងរវាងប្រជាជននឹងប្រជាជនក៏លំបាក។



ផ្លូវលំមួយខ្សែក្នុងស្រុកជលគិរី ខេត្តកំពង់ឆ្នាំង

លោក *យិន សារវេន* អភិបាលនៃគណៈអភិបាលស្រុកជលគិរីបានមានប្រសាសន៍ថា ដោយកង្វះខាតផ្លូវគមនាគមន៍នេះហើយ និងម្យ៉ាងដោយស្រុកនេះស្ថិតនៅចុងកាត់មាត់ញក ទើបធ្វើឱ្យគេពុំសូវមានការចាប់អារម្មណ៍។ប៉ុន្តែក្នុងអំឡុងឆ្នាំ២០០០ ស្រុកជលគិរីចាប់ផ្តើមមានការរីកចម្រើនយ៉ាងឆាប់រហ័ស មានផ្លូវមានស្ពានឆ្លងកាត់មាត់ទន្លេ និងព្រែក។ ប្រជាជនធ្វើដំណើរពីភូមិទៅភូមិមួយ ពីឃុំមួយទៅឃុំមួយ រហូតទៅដល់ទីរួមខេត្តកំពង់ឆ្នាំងទៀតផងនៅរដូវប្រាំង ដោយឆ្លងតាមសាឡង់ទន្លេមួយតែប៉ុណ្ណោះ ដែលខុសពីអតីតកាលសូម្បីតែដើរឆ្លងពីភូមិមួយទៅភូមិមួយក៏ពុំរួចផង។បច្ចុប្បន្ននេះស្រុកជលគិរីមានផ្លូវគោកមួយជាសរសៃឈាមដ៏សំខាន់របស់ស្រុក។ ប្រជាជនក៏អាចធ្វើដំណើរបានទាំងរដូវវស្សា និងរដូវប្រាំងឆ្ពោះទៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា តាមរយៈផ្លូវលំមួយខ្សែលើទំនប់ប្រព័ន្ធធារាសាស្ត្រតាកុយដែលតភ្ជាប់ពីស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ទៅស្រុកបាធាយ ខេត្តកំពង់ចាម ចេញត្រង់ផ្សារផ្អាវផ្លូវជាតិលេខ ៦ ។ ប្រជាជនមានរថយន្តតូចទំនើប រថយន្តឈ្នួល



*ប្រឡាយមេនាំទឹកស្រោចស្រពស្រែប្រជាកសិករស្រុកជលគីរី*



*អគារសិក្សានៅក្នុងស្រុកជលគីរី ខេត្តកំពង់ឆ្នាំង*

តូច ធំ រថយន្តដឹកជញ្ជូនអ្នកដំណើរ និងភោគផលទាំងឡាយទៅកាន់ទីប្រជុំជន និងទីផ្សារនានាបានយ៉ាងងាយស្រួល។ ដោយសារមានប្រព័ន្ធគមនាគមន៍ភ្ជាប់ទំនាក់ទំនងបែបនេះ ធ្វើឱ្យស្រុកជលគីរីលែងជាស្រុកដែលស្ងប់ស្ងាត់ កណ្ដោចកណ្ដែង និងឯកកោពីគេឯងទៀតហើយ។ ទីរួមស្រុក ជលគីរីបានក្លាយទៅជាទីប្រជុំជនដ៏មមាញឹក ។ អ្នកស្រុកជលគីរីមានជីវភាពរស់នៅសមរម្យ។ លោក *យិន សាវេន*បានឱ្យដឹង ទៀតថា ក្រៅពីការកសាងផ្លូវថ្នល់ អាជ្ញាធរស្រុកបានសហការជាមួយមន្ទីរជំនាញជួសជុល និងកសាងប្រព័ន្ធធារាសាស្ត្រជាច្រើនទៀត ដើម្បីបំពេញតម្រូវការ និងជំរុញការអភិវឌ្ឍវិស័យកសិកម្មដំណាំស្រូវឱ្យមានការរីកចម្រើន។ ប៉ុន្តែមានការកត់សម្គាល់ថា ក្នុងចំណោមឃុំទាំង ៥ មានឃុំតែមួយប៉ុណ្ណោះដែលអាចធ្វើស្រែបាន គឺឃុំព្រៃគ្រីដែលមានផ្ទៃដីបង្កបង្កើនផលស្រូវទំហំ៦ហ.ត ។ប្រជាជនរស់នៅឃុំក្រៅពីនោះគឺសុទ្ធតែជាអ្នកនេសាទ។ ការងារនេសាទគឺជាការងារអាទិភាពចម្បងរបស់ស្រុកជលគីរី។ ដោយហេតុនេះអាជ្ញាធរស្រុកបានព្យាយាមខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្តសហការជាមួយជំនាញរដ្ឋបាលជលផលទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់អំពើល្មើសច្បាប់នានា តាមរយៈការប្រជុំ អប់រំ ផ្សព្វផ្សាយអំពីច្បាប់ជលផលដូចជាភ្លៀងរលឹម។ លោក *យិន សាវេន* បានបញ្ជាក់ទៀតថា យើងធ្វើការងារនេះដោយមិនមានដកដៃឡើយ ពីព្រោះថាបើយើងធ្វេសប្រហែស បទល្មើសនេសាទងាយនឹងកើតឡើង វានឹងបំផ្លាញភោគផលត្រីធម្មជាតិរបស់យើង។ ប្រជាជននៅទីនេះប្រកបរបរនេសាទជីវិតពឹងផ្អែកទាំងស្រុងទៅលើមុខរបរនេះ ដូច្នេះយើងត្រូវតែការពារទោះដោយតម្លៃណាក៏ដោយ។ ប្រជាជននៅទីនេះប្រកបរបរនេសាទតាមលក្ខណៈគ្រួសារ គឺនៅពេលដែលគេនេសាទបាន អ្នកខ្លះយកទៅលក់ឯទីផ្សារ ខ្លះធ្វើត្រីឆ្អើរ ឬត្រីងៀត ផ្អក ប្រហុក ទើបយកទៅលក់ដោះដូរជាប្រាក់កាសទិញស្រូវ អង្ករមកហូបវិញ។ បងប្រុស *ហ៊ីម ចំរុង* អាយុ ២៥ ឆ្នាំ រស់នៅភូមិកំពង់ស្រូវ ឃុំជលសារ ស្រុកជលគីរី ដែលកំពុងជិះទូកបណ្ដែតមងលើផ្ទៃទឹកនៅទន្លេធំ ឃុំពាមឆ្កោកបាននិយាយថា មុខរបរនេសាទរបស់គាត់បានផ្ដល់ផលប្រយោជន៍សម្រាប់ជីវភាពរស់នៅសមបង្គួរដែរ។ ក្នុងមួយថ្ងៃៗគាត់នេសាទបានយកមកឆ្អើរខ្លួនឯង រួចទើបលក់ជាក្រោយ ក្នុងមួយចង្កាក់លក់បានតម្លៃពី ៤០០ រៀល ទៅ ៦០០ រៀល សម្រាប់ត្រីតូចៗ ហើយរដូវត្រីត្រូវក្នុងមួយខែៗគាត់អាចឆ្អើរបានពី៤០០០ទៅ៥០០០ចង្កាក់ឬច្រើនជាងនេះ។ ប៉ុន្តែក្រៅពីរដូវត្រីត្រូវ ក៏គាត់អាចនេសាទបានក្នុងមួយថ្ងៃ ៤ ទៅ ៥ គីឡូ សម្រាប់លក់នៅឯទីផ្សារ។ ប៉ុន្តែគាត់ទទួលស្គាល់ថា ត្រីឆ្នាំនេះតូចៗមិនដូចឆ្នាំកន្លងទៅទេ។ បងស្រី *គង់ ឡាយ* ជាអ្នកនេសាទរស់នៅភូមិពាម-ឆ្កោក ឃុំពាមឆ្កោក ស្រុកជលគីរី បានទទួលស្គាល់ថា អាជ្ញាធរស្រុក និងជលផល ពិតជាបានខ្នះខ្នែងខ្លាំងណាស់ក្នុងការទប់ស្កាត់បទល្មើសនេសាទប៉ុន្តែវានៅតែកើតមានដោយលួចលាក់។ ជនខិលខូចតែងឆ្លៀតឱកាសឆក់ល្វែងរបស់អាជ្ញាធរមានសមត្ថកិច្ច លួចប្រព្រឹត្តបទល្មើសនៅតាមដែននេសាទសាធារណៈ និងនៅតំបន់អភិរក្ស។ ប៉ុន្តែក៏ធ្លាប់ឃើញអាជ្ញាធរចាប់ខ្លួនបានធ្វើការអប់រំ ព្រមានផាកពិន័យផងដែរ។

បញ្ហាដែលគួរចាប់អារម្មណ៍មួយនៅស្រុកជលគីរី គឺវិស័យសុខាភិបាល។ យើងទទួលស្គាល់ថា ផ្លូវគមនាគមន៍ដែលកើតមាននៅក្នុងស្រុកនេះបង្កលក្ខណៈងាយស្រួលសម្រាប់ដឹកជញ្ជូនអ្នកជំងឺ ប៉ុន្តែមណ្ឌលសុខភាពស្រុកជលគីរីជួបការលំបាកច្រើនណាស់។ លោក *ជួន ធុល* ប្រធានមណ្ឌលសុខភាពស្រុកជលគិរី បានមានប្រសាសន៍ថា មណ្ឌលសុខភាពនេះមាន ១ អគារ។ បន្ទប់សម្រាប់អ្នកជំងឺសម្រាកមានតែមួយបន្ទប់។ បង្កើតកូនក៏នៅក្នុងបន្ទប់មួយហ្នឹង អ្នកជំងឺផ្សេងៗដេកសម្រាកព្យាបាល ក៏នៅក្នុងបន្ទប់ហ្នឹង ។បុគ្គលិក និងមន្ត្រីមណ្ឌលសុខភាពនេះបានបរិច្ចាគថវិកា តសំយាបចេញពីអគារសម្រាប់បង្កលក្ខណៈឱ្យអ្នកជំងឺដែលមកព្យាបាលច្រើនដេកសម្រាកនៅតាមទីនោះ។ លោក *យិន សាវេន* អភិបាលស្រុកបានបញ្ជាក់ថា បច្ចុប្បន្ននេះមណ្ឌលសុខភាពស្រុកជលគីរីដែលជាអតីតមន្ទីរពេទ្យស្រុកចាស់នោះកំពុងជួបប្រទះកង្វះអគារឱ្យអ្នកជំងឺសម្រាកព្យាបាល ។ខ្វះសម្ភារៈបរិក្ខារ ជាពិសេសមធ្យោបាយដឹកជញ្ជូនអ្នកជំងឺធ្ងន់ទៅសង្គ្រោះនៅមន្ទីរពេទ្យនានា ដូចជាមន្ទីរពេទ្យខេត្ត ឬទៅរាជធានីភ្នំពេញជាដើម។ លោក *ជួន ធុល* បានសំណូមពរដល់ក្រសួងសុខាភិបាល និងអង្គការនានាមេត្តាជួយឧបត្ថម្ភដល់មណ្ឌលសុខភាពស្រុកជលគីរី ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ជួយព្យាបាលជំងឺជូនប្រជាជនឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

វិស័យសន្តិសុខ សណ្ដាប់ធ្នាប់សង្គម ក៏គួរជាទីចាប់អារម្មណ៍ពីព្រោះថា ស្រុកកម្រកើតមានអំពើចោរកម្មឆក់ប្លន់ណាស់ ដោយសារតែកត្តាភូមិសាស្ត្ររួមផ្សំជាមួយនឹងការខិតខំរបស់សមត្ថកិច្ចអាជ្ញាធរដែនដីផងនោះ ធ្វើឱ្យពួកជនទុច្ចរិតពិបាកយកតំបន់នេះប្រព្រឹត្តអំពើឧក្រិដ្ឋណាស់ ។ គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ត្រូវបានបញ្ជ្រាបចូលទៅដល់គ្រប់ភូមិ ឃុំ និងដល់ក្រុមគ្រួសារនីមួយៗ។ ប្រជាជនរួមសហការគ្នាបានល្អ ទប់ស្កាត់នូវការប្រព្រឹត្តសកម្មភាពមិនត្រឹមត្រូវរបស់ជនទុច្ចរិត។

ជីវភាពរស់នៅដ៏សុខក្សេមក្សាន្តរបស់ប្រជាជននៅស្រុកជលគីរី ធ្វើឱ្យពួកគាត់កាន់តែមានជំនឿចិត្តទៅលើការគ្រប់គ្រងរបស់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងទៅលើការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្ដេចតេជោ **ហ៊ុន សែន** ជាប្រមុខ។ លោក *យិន សាវេន* បានឱ្យដឹង ថាគណបក្សប្រជាជនកម្ពុជាបានរួមចំណែកយ៉ាងធំធេងក្នុងការបង្កើតសមិទ្ធផលដ៏ច្រើនលើសលប់នៅស្រុកជលគីរី។ ប្រជាជននៅតែមានជំនឿជាក់ទៅលើគណបក្សប្រជាជនកម្ពុជា ។ ជាមួយគ្នានេះ អាជ្ញាធរស្រុក និងគណៈកម្មាធិការគណបក្សស្រុកក៏បានខិតខំលាងសម្អាតនូវទង្វើមិនល្អនានាដែលកើតមានឡើងពីអតីតកាលដែលធ្វើឱ្យប្រជាជនថ្នាំងថ្នាក់ ជួសជុលនូវទង្វើមិនល្អទាំងនោះ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ប្រជាជនមកលើគណបក្សប្រជាជនកម្ពុជា និងបន្តបោះឆ្នោតគាំទ្រគណបក្សឱ្យដឹកនាំប្រទេសឆ្ពោះទៅកាន់ការអភិវឌ្ឍថ្មីថែមទៀតក្នុងពេលអនាគត ។/

# កុំកាប់បំពង់រង់ចាំទឹកភ្លៀង

*( បទពាក្យ ៧)*

- កុំកាប់បំពង់រង់ចាំទឹកភ្លៀង　　ពាក្យពេចន៍សំនៀងលោកចងឃ្លា
  ចាស់ផ្ដាំប្រដៅរាល់វេលា　　ឱ្យពិចារណាផ្លូវជីវិត ។
- កុំដេករង់ចាំព្រេងវាសនា　　កុំចោលកិច្ចការផ្សេងលាភពិត
  កុំឆោតវង្វេងឆ្វេងគំនិត　　ចោលការមកគិតពឹងសំណាង ។
- កុំឮផ្គរលាន់រួសរាន់អរ　　ចាក់ចោលឈ្នួរទឹកក្នុងអាង
  ចាំត្រងទឹកថ្មីដាក់ប៉ោតពាង　　គ្រោះកាចគ្រាប់ភ្លៀងវាងមិនធ្លាក់ ។
- នោះឯងរមែងខូចប្រយោជន៍　　ទ្រព្យផងហិនហោចព្រោះជឿជាក់
  ផ្គរភ្លៀងមិនទៀងទេនាងអ្នក　　ចាស់លោកបញ្ជាក់មិនលាក់ភរ ។
- យើងធ្វើស្រែច្បារប្រាថ្នាទឹក　　កុំសង្ឃឹមនឹកពឹងភ្លៀងផ្គរ
  ការពាររាំងជល់កុំឈប់ឈរ　　ទើបផលកើនគរជាក់ជាបាន ។
- កុំរំពឹងមេឃក្រែងខាតខក　　ស្រូវស្រែបែរស្កកនាំរំខាន
  មានវិធានការទើបថាថ្កាន　　កុំខឹងជេងក្រានបើបាយឆៅ ។
- ធ្វើស្រែនឹងទឹកសឹកនឹងស្បៀង　　ពាក្យពីរបីព្យាង្គចាស់ប្រដៅ
  ផ្សងព្រេងប្រវាស់ច្បាស់ជាខ្លៅ　　ក្រែងពូជមួយតៅនៅមួយក្ដាប់ ។
- ញាតិអើយកុំផ្អែកអំរែកគេ　　កុំស្ងៀមទំនេរចាំផលស្រាប់
  កុំឲ្យគេជួយលែងព្រួយយ៉ាប់　　រីករាយចំណាប់ភ្លេចកិច្ចការ ។
- លុះយល់គេបោកគេមិនគាប់　　ចាយវាយអស់ទ្រព្យទើបឆ្លេឆ្លា
  បន្ទោសថាព្រោះព្រេងវាសនា　　ខ្វះក្ដីមេត្តាដល់ជីវិត ។
- នោះហើយប្រៀបបាននឹងភ្លៀងផ្គរ　　មិនអាចនឹងនទេញាតិមិត្ត
  ខ្លួនត្រូវពឹងខ្លួនស្ងួនគួរគិត　　នោះទើបជីវិតមានរស្មី ។
- កុំជឿពួកពាលដៀលបំពង　　ដូចខ្មោចលបលងលួចបំភ័យ
  ក្អែកពាក់ស្បែកហង្សចង់ក្រញី　　បំផ្លើសបំភ្លៃបំផ្លាញជាតិ ។/

*ដោយ : សុខ សុធន*



## បុរសមានសុជីវធម៌

ថ្ងៃមួយ នាង ច្រែត បានទៅតុលាការប្ដឹងសុំលែងលះប្ដីដោយចោទប្រកាន់ថា នាយ ច្រែង មានចរិតអន់ ។ លោកចៅក្រមសួរ នាយ ច្រែង:

- ប្រពន្ធលោកត្អូញត្អែរថា ប៉ុន្មានឆ្នាំហើយ តាំងពីរៀបការគ្នាជាប្ដីប្រពន្ធលោកមិនដែលនិយាយរកនាងសោះ តើការចោទប្រកាន់នេះយ៉ាងម៉េចដែរ?
- ជម្រាបលោកចៅក្រម គឺជាការពិតមែន!
- ម៉េចក៏មានរឿងបែបហ្នឹង?
- បាទ! ព្រោះខ្ញុំជាបុរសមានសុជីវធម៌ មិនចង់កាត់សំដីអ្នកដទៃ។ រៀងរាល់លើកដែលខ្ញុំចូលដល់ផ្ទះជួបមុខគ្នា ប្រពន្ធខ្ញុំនិយាយដូចកាំភ្លើងបើករ៉ាហ្វាល់ មិនទុកពេលឱ្យខ្ញុំនិយាយម្ដងណាទេ ។

## ខ្ញុំដាក់ឱ្យនាងទេតើ!

បានអង្គុយមើលទូរទស្សន៍ចំពេលកម្មវិធីឃោសនាអំពីថ្នាំដុសធ្មេញ នាយជក់និយាយទៅកាន់នាយជុច អង្គុយក្បែរ :

- ជុចអ្ហា...ថ្នាំដុសធ្មេញហ្នឹងប្រហែលល្អមែនហើយមើលចុះធ្មេញនារីសើច ដែលកាន់ប្រអប់ថ្នាំដុសធ្មេញ ស្អាតមែនទែន។
- អេហ៍ ធ្មេញរបស់ខ្ញុំតើ!
- ឯងនិយាយស្អីហ្នឹង?
- គឺថាធ្មេញខ្ញុំដាក់ឱ្យនាងតើ។ តាមពិតធ្មេញកំណើតរបស់នាងពុកបាក់អស់ហើយ ។

## ម៉េចខឹងខ្លាំងម្ល៉េះ?

ពេលត្រឡប់ពីធ្វើការចូលដល់ផ្ទះ នាយស្មាញប្រាប់ប្រពន្ធ :

-អូនអ្ហា...អម្បាញ់មិញនៅតាមផ្លូវមានមនុស្សពីរនាក់វាយតប់គ្នាមុនដំបូងប្រើដៃនិងជើង បន្ទាប់មកស្ទុះទៅយកកាំបិតរៀង១ខ្លួន ប៉ុន្តែសំណាងណាស់ ខណៈនោះមានអ្នកទី៣ រត់មកឃាត់ទាន់ កុំអីមានម្នាក់ស្លាប់មិនខាន ហើយបើទោះបីជាមិនស្លាប់ក៏រងរបួសធ្ងន់ធ្ងរដែរ ។ គិតទៅតួនាទីអ្នកទី៣សំខាន់បំផុត។ អ្នកទី៣ ប្រៀបបានជាអាជ្ញាកណ្ដាល ឬជាសាក្សីនៅចំពោះមុខតុលាការ ។ តើអូនយល់អ៊ីចឹងទេ?

- ចាស....បងនិយាយត្រូវហើយ!
- អើ បើអ៊ីចឹង ហេតុម៉េច ពេលបងមានអ្នកទី៣ អូនខឹងខ្លាំងម្ល៉េះ? ។

## នៅក្នុងប្រឡាយទឹក

ព្រឹកមួយ នាង ទែន បានទូរស័ព្ទប្រាប់នាយ ទក ជាប្ដីដែលកំពុងធ្វើការនៅឯការិយាល័យ :

- ពុកវ៉ា! ពុកវ៉ា! ម៉ូតូយើងទឹកចូលម៉ាស៊ីនពេញអស់ហើយ ។
- យីអើ..ម៉េចក៏មានរឿងបែបហ្នឹងទៅកើត? ចុះពេលនេះម៉ូតូកំពុងនៅផ្ទះឬនៅកន្លែងជាងជួសជុល?
- ចាំះ..ចាំះ វាអត់មាននៅផ្ទះ ហើយវាក៏អត់នៅកន្លែងជាងជួសជុលដែរ គឺវាកំពុងដេកនៅបាតប្រឡាយទឹក ព្រោះតែកូនយើងជិះភ្លាវចង្កូតចុះប្រឡាយទឹកទាំងម៉ូតូទាំងមនុស្សហ្នឹងណាំ ។/

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៥៤

| | | | | |
|---|---|---|---|---|
| ១- | ឯ.ឧ | **កែ គឹមយ៉ាន** | *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ* | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **ចម ប្រសិទ្ធ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោកជំទាវ* | ២០០ ដុល្លារ |
| ៣- | ឯ.ឧ | **មិន ឃិន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ* ***ខួន ឆួន*** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ត្រាំ អ៊ីវតឹក** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន* | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ថោង ខុន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍* | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **លន់ លឹមថៃ** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម* | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **ជៀង អំ** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង* | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **ស្បោង សារ៉ាត** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ* | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **ខុយ សុខា** | *អនុប្រធានគណៈកម្មាធិការគណបក្សខេត្តពោធិសាត់* | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **អ៊ូស្មាន ហាស្សាន់** | *ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា* | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **សរ ចំរ៉ុង** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ* | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ផា សុជាតិវង្ស** | *ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ* | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ម៉ម ប៊ុននាង** | *សមាជិកព្រឹទ្ធសភា* | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ប្រាក់ ចំរើន** | *សមាជិកព្រឹទ្ធសភា* | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **គង់ វិបុល** | *ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **អ៊ឹុន វីរជាតិ** | *រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី* | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | **យូ តិរម្យ** | *សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់* | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ៥០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ៥០ ដុល្លារ |
| ២២- | ឯ.ឧ | **លឹម គានហោ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក* | ២០០.០០០ ៛ |
| ២៣- | ឯ.ឧ | **ឃឹម សារិទ្ធ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ* | ៥០ដុល្លារ |
| ២៤- | ឯ.ឧ | **ម៉ម ប៊ុនហេង** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ២៥- | ឯ.ឧ | **ថា យ៉ាវ** | *អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា* | ២១៣.៤៧០៛ |
| ២៦- | ឯ.ឧ | **ជូ យិនស៊ីម** | *រដ្ឋលេខាធិការក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ២៧- | ឯ.ឧ | **អ៊ុក ប្រាថ្នា** | *រដ្ឋលេខាធិការក្រសួងព័ត៌មាន* | ២០០.០០០ ៛ |
| ២៨- | ឯ.ឧ | **ប៉ាវ ហមផាន** | *អនុប្រធានគណៈកម្មាធិការគណបក្សខេត្តរតនគិរី* | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **សូ ជុងហួរ** | *ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ* | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **ចាយ បូរិន្ទ** | *អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម* | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | **នរះ រតនៈវឌ្ឍនោ** | *រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា* | ២០០.០០០ ៛ |
| ៣២- | ឯ.ឧ | **ឃួន រ៉ានីន** | *រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* | ៥០ ដុល្លារ |
| ៣៣- | ឯ.ឧ | **ប៊ុន លឹមហេង** | *អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី* | ២០០.០០០៛ |
| ៣៤- | ឯ.ឧ | **សេង នៀង** | *ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** | ២០០.០០០៛ |
| ៣៥- | ឧកញ៉ា | **ម៉ក់ គឹមហុង** | *ប្រធានអគ្គនាយកចំការកៅស៊ូជប់* | ២០០.០០០៛ |
| ៣៦- | ឯ.ឧ | **ម៉ៅ ប៊ុនណារិន** | *សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា* | ១០០.០០០៛ |
| ៣៧- | ឯ.ឧ | **ម៉ែន ស៊ំផាន់** | *សមាជិកព្រឹទ្ធសភា* | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | **សុន គន្ធរ** | *រដ្ឋមន្ត្រីប្រតិភូអមសម្ដេចនាយករដ្ឋមន្ត្រី* | ១០០.០០០៛ |
| ៣៩- | ឯ.ឧ | **ប៉ាន ប៊ុនធឿន** | *រដ្ឋលេខាធិការក្រសួងផែនការ* | ១០០.០០០៛ |
| ៤០- | លោកជំទាវ | **ស៊ឹង ស៊ុំយុត** | | ១០០.០០០៛ |
| ៤១- | ឯ.ឧ | **គឹម ឆា** | *ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង* | ១០០.០០០៛ |
| ៤២- | ឯ.ឧ | **គាំម កុសល** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | **ប៊ិច សុវណ្ណ** | | ១០០.០០០៛ |
| ៤៤- | ឯ.ឧបណ្ឌិត | **មាស ប៉ូ** | *អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* | ១០០.០០០៛ |
| ៤៥- | លោកជំទាវ | **ឆិត្យ ច័ន្ទតារីន** | *អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **ឆា ច័ន្ទលីដា** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | **ម៉ែន វិបុល** | *ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង* | ១០០.០០០៛ |
| ៤៨- | លោក | **អោម ចន** | *ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ* | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | **ជួន ថេរ៉ាវ៉ាត** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន* | ១០០.០០០៛ |
| ៥០- | ឯ.ឧ | **ម៉ៅ ឡាំង** | *ទីប្រឹក្សាឯកឧត្ដម* ***ខួន ញឹល*** *អនុប្រធានទី ១ រដ្ឋសភា* | ១០០.០០០៛ |
| ៥១- | ឯ.ឧ | **ឆាយ ឬទ្ធិសែន** | *អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់* | ១០០.០០០៛ |
| ៥២- | លោក | **សាំ ពិសិដ្ឋ** | *ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ* | ១០០.០០០៛ |
| ៥៣- | ឯ.ឧ | **អ៊ុន ឆាលី** | *អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង* | ១០០.០០០៛ |
| ៥៤- | លោក | **សុខ វិសាលសម្បត្តិ** | *អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំព្នៅ១ ស្រុកស៊ិធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល ...* | ១០០.០០០៛ |
| ៥៥- | ឯ.ឧ | **សៀង សុខឃុនឌី** | *អគ្គនាយករងនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* | ៥០.០០០៛ |
| ៥៦- | ឯ.ឧ | **សាយ បូរិន** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ៥០.០០០៛ |
| ៥៧- | ឯ.ឧ | **សេង គឹមសាន** | *ជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល* ***ជា ស៊ីម*** | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | **ពត ចាន់នី** | *សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម* | ៥០.០០០៛ |
| ៥៩- | ឯ.ឧ | **ហេង វណ្ណារ** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៦០- | លោក | **ជា វុទ្ធី** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៦១- | លោកជំទាវ | **ស៊ឿ ច័ន្ទថា** | | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៥៤

| | | | | | |
|---|---|---|---|---|---|
| ៦២- | លោក | ហួត | ពៅ | ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានវដ្ឋសភា | ៥០.០០០៛ |
| ៦៣- | កញ្ញា | ផាង | និតហ្វើរ៍ | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៦៤- | លោក | ង៉ោ | ម៉េងថ្នន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៦៥- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៦- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៦៧- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៨- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៩- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ | ៥០.០០០៛ |
| ៧០- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៧១- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧២- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧៣- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | | ៤០.០០០៛ |
| ៧៤- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៥- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៦- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៧៧- | លោក | ចាន់ | ស៊ុណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៨- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៩- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ | ៣០.០០០៛ |
| ៨០- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២៥.០០០៛ |
| ៨១- | ឯ.ឧ | ចុង | ផេត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨២- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៣- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៤- | លោក | លឹម | វីរក្ស | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៥- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៦- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨៧- | លោក | ឡឹក | សន | អនុប្រធានមន្ទីរគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ២០.០០០៛ |
| ៨៨- | លោក | ជា | គឹមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៨៩- | ឯ.ឧ | ទេស | ចំនូគីរី | សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប | ២០.០០០៛ |
| ៩០- | លោក | ទូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩១- | លោក | ហ្វាង | ថ្វិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ៩២- | លោក | ម៉ុ | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៩៣- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៤- | លោក | អ៊ឹក | ទូច | ប្រជាជនភូមិអូររអិល ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន | ២០.០០០៛ |
| ៩៥- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ៩៦- | លោក | អ៊ុច | សាវ័ន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ៩៧- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៩៨- | ឯ.ឧ | ប៉ូញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៩- | លោក | ម៉ុ | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ១០០- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០១- | លោក | ម៉ម | ប្រុស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០២- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៣- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៤- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៥- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៦- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៧- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៨- | លោក | ទិត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៩- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១១០- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១១- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១២- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៣- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៤- | លោក | ណុប | រឿមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៥- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៦- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៧- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៨- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៩- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១២០- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២១- | លោក | ឡុង | ចន្ធា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២២- | លោក | ឡាច | គីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៣- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |






វេទិការាជរដ្ឋាភិបាល និងវិស័យឯកជនលើកទី ១៧ ក្រោមប្រធានបទ "សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ...........

៦



សម្តេចតេជោ : ការនិយាយរបស់នាយករដ្ឋមន្ត្រីក្នុងតំណែង វាខុសពីនាយករដ្ឋមន្ត្រីឧទាហរណ៍ : ទន្រ្ទាំជើងមួយកន្លែងជាសត្រូវរបស់វប្បធម៌

៩



សម្តេចក្រឡាហោម **ហោង សិរិន** អញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសម៉ារ៉ុក និងប្រទេសកូឌីវ័រ

១២



**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី

២. លោក អ៊ុម សុន្ទរៈ

៣. លោក វង្ស សារ៉ុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារ៉ុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

**Address :**

**No 203 Preah Norodom Bld.**

**Phnom Penh Cambodia**

**Tel : 023 219 065**


## ក្របមុខ

សម្តេចអគ្គមហាសេនាបតីតេជោ

**ហ៊ុន សែន**

ក្នុងឱកាសអញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវជាតិលេខ ៥៧ បេ ដែលតភ្ជាប់ពីស្រុកបវេល ខេត្តបាត់ដំបង ទៅតំបន់ព្រំដែន កម្ពុជា-ថៃ

( ថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១៤ )




ឯកឧត្តម **សាយ ឈុំ** ជួបសវនាការជាមួយគណៈប្រតិភូសភាសហភាពអឺរ៉ុប

១៣


# មាតិកា

# Contents


*វិចារណកថា : ឆន្ទៈរបស់ប្រជាជនគឺស្ថិតនៅក្នុងសន្លឹកឆ្នោត មិនមែននៅតាមដងផ្លូវទេ........................ ៣*

*Editorial : People's Will Expressed in Ballots, not in Street ..........................................*

⇨ *តើអ្នកដឹកនាំនៃគណបក្សប្រឆាំង មានឆន្ទៈចង់ដោះស្រាយបញ្ហាក្រោយការបោះឆ្នោតនៅកម្ពុជាពិតប្រាកដដែរឬទេ ?........................................................................ ៥*

⇨ *សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៥*

⇨ *លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច.................................................................. ១៨*

⇨ *វិស័យអគ្គិសនីកម្ពុជា បានបង្ហាញពីការរីកចម្រើនយ៉ាងរឹងមាំ ទាំងប្រភពអគ្គិសនី បណ្តាញអគ្គិសនី និងតម្លៃប្រើប្រាស់ .................................................................. ១៩*

⇨ *ការអភិវឌ្ឍវិស័យគមនាគមន៍នៅកម្ពុជាក្រោមគម្រោងជំនួយអន្តរជាតិ................................. ២១*

⇨ *ឆ្នាំ ២០១៣ ការនាំចេញអង្ករបស់កម្ពុជាមានកំណើន ៨៤ % ............................................. ២៤*

⇨ *វប្បធម៌ : ទំនៀមប្រពៃណីក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ "ឆ្នាំមមីឆស័ក"...................................... ២៦*

⇨ *ចំណេះដឹងទូទៅ : ប្រព័ន្ធ Online ថ្មីតាមដានអំពីការបាត់បង់ព្រៃឈើ "ក្នុងពេលវេលាពិតប្រាកដ"........................................................................ ២៧*

⇨ *វិទ្យាសាស្ត្រ សុខភាព : ផ្លែខ្នុរជួយបញ្ចុះសម្ពាធឈាម និងថែរក្សាស្បែក......ផ្លែទទឹម............... ២៨*

⇨ *ទឹកដីមាតុភូមិ : ប្រជាជនស្រុកជលគីរីតាំងចិត្តរក្សាមហិច្ឆតានៃការអភិវឌ្ឍ........................... ២៩*

⇨ *កំណាព្យ : កុំកាប់បំពង់រង់ចាំទឹកភ្លៀង ........................ សំណើច .................................. ៣១*

ទស្សនាវដ្ដី

# ប្រជាជន

THE PRACHEACHUN MAGAZINE



ឆ្នាំទី១៣ លេខ ១៥៤ ខែមីនា ឆ្នាំ ២០១៤



ស្ថានីយវារីអគ្គិសនីស្ទឹងអាតៃ មានអានុភាព ១២០ មេហ្គាវ៉ាត់ និងអនុស្ថានីយអូរសោម
ស្ថិតក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ (សម្ពោធថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៤)

